ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៦ លេខ ២ | មេសា - មិថុនា ឆ្នាំ២០១២ | តម្លៃ ១.៥០០៛

# នគរូបនីយកម្មនៅកម្ពុជា៖ និន្នាការសំខាន់ៗ និងអាទិភាពគោលនយោបាយ[1]

លោក Ban Ki-moon អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ បាននិយាយថា មនុស្សជាតិ បានឈានចូលដល់សតវត្សរ៍នៃទីក្រុងហើយ។ ប្រជាជនលើពិភពលោកជាង ៥០% រស់នៅក្នុងតំបន់ទីក្រុង។ តាមការប៉ាន់ស្មាន តួលេខអ្នករស់នៅតំបន់ទីក្រុងនៅអាស៊ីអាគ្នេយ៍ នឹងកើនដល់ ៧៣% នៅឆ្នាំ២០៥០ (UN-HABITAT 2008: 12)។ ការផ្លាស់ប្តូរយ៉ាងគំហុក នៃកន្លែងរស់នៅរបស់មនុស្សនេះ ផុសចេញពីកំណើនសារៈសំខាន់នៃទីក្រុង ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចពិភពលោក។ កន្លែងទីក្រុង ជាចំណុចស្នូលនៃឧស្សាហកម្ម ហើយបណ្តាញទីក្រុង គឺជាប្រព័ន្ធខួរក្បាលនៃសេដ្ឋកិច្ចពិភពលោក។ លំហទីក្រុងនៅកម្ពុជា ជាច្រកចេញចូលកាន់តែសំខាន់ឡើង ទៅកាន់បណ្តាញសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក ដែលសំខាន់បំផុតក្នុងការជួយសម្រួលវិនិយោគ និងពាណិជ្ជកម្មឆ្លងកាត់ប្រទេស។ តំបន់ទីក្រុងនៅកម្ពុជា មានប្រជាជនកើនឡើងយ៉ាងលឿន ក្នុងអត្រាប្រចាំឆ្នាំជាមធ្យម ៤,៣៤% ពីឆ្នាំ២០០០ ដល់ ២០១០ (World Bank 2012)។ ពិតមែនតែនគរូបនីយកម្មតែងផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍ វាក៏តែងមានវិសមភាព និងភាពខ្វះខាតផងដែរ ហើយកម្ពុជាដែលស្ថិតក្នុងចំណោមប្រទេសមាន អត្រាភាពក្រីក្រនៅទីក្រុងកម្រិតខ្ពស់បំផុតនៅក្នុងតំបន់ ក៏ជួបបញ្ហានេះដែរ។ អន្តរាគមន៍ទាន់ពេលវេលារបស់រដ្ឋាភិបាល គឺចាំបាច់បំផុត ដើម្បីញ៉ាំងឲ្យនគរូបនីយកម្មវាបម្រើឲ្យគ្រប់គ្នា មានចីរភាព អាចហុចផលចំណេញបានច្រើនបំផុត និងបានទៅដល់គ្រប់ស្រទាប់សង្គម។ ដោយផ្អែកលើទស្សនៈខាងលើ ឯកសារនេះពិនិត្យពីតួនាទីនៃតំបន់ទីក្រុងក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ធ្វើការវាយតម្លៃពីបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងកំណើនតំបន់ទីក្រុងទៅថ្ងៃខាងមុខ ព្រមទាំងកំណត់ពីគោលនយោបាយសំខាន់ៗដែលត្រូវមាន ដើម្បីដោះស្រាយបញ្ហាទាំងនោះ។ នៅផ្នែកខាងចុងនៃឯកសារនេះ មានការគូសបញ្ជាក់ពីកំណើនតម្រូវការកម្មវិធីស្រាវជ្រាវដ៏សកម្មមួយ ពីតំបន់ទីក្រុង ដើម្បីផ្តល់ជាព័ត៌មានឲ្យបានគ្រប់គ្រាន់ដល់ការកសាងគោលនយោបាយតំបន់ទីក្រុងនៅពេលអនាគត។



ទីក្រុងនៅប្រទេសកម្ពុជា បានរីកលូតលាស់យ៉ាងលឿនក្នុងពីរទសវត្សរ៍ចុងក្រោយនេះ៖ ភ្នំពេញ ខែឧសភា ឆ្នាំ២០១២។

## តំបន់ទីក្រុងនៅកម្ពុជា

តាំងពីយូរលង់មកហើយគេតែងយល់ថា តំបន់ទីក្រុងជាកន្លែងដែលមនុស្ស ធ្វើការទាក់ទងគ្នា រៀនសូត្រ ច្នៃប្រឌិត និងរីកចម្រើនឡើង គឺតាំងពីទីក្រុងនៅប្រទេសក្រិចដែលជាទីកំណើតនៃលទ្ធិប្រជាធិបតេយ្យ រហូតដល់ទីក្រុងនៅប្រទេសអង់គ្លេស

## មាតិកា

នគរូបនីយកម្មនៅកម្ពុជា៖ និន្នាការសំខាន់ៗ និងអាទិភាពគោលនយោបាយ ..... ១
មូលធនសង្គមក្នុងសហគមន៍នៅតំបន់ទីក្រុង និងជនបទនៅកម្ពុជា ..... ៦
អភិបាលកិច្ចទីប្រជុំជនក្នុងបរិបទវិមជ្ឈការនៅកម្ពុជា៖ ប្រធានបទមិនសូវមានគេស្រាវជ្រាវ? ..... ១១
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ..... ១៥
— ស្ថានភាពក្នុងប្រទេស ..... ១៧
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ..... ២៤

[1] អត្ថបទនេះរៀបរៀងដោយលោក B. C. R. Flower ជានិស្សិតថ្នាក់បណ្ឌិតនៃសាកលវិទ្យាល័យ UCL និងជាកម្មសិក្សាការីផ្នែកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

នៅសតវត្សរ៍ទី១៩ ដែលនៅទីនោះប្រព័ន្ធឧស្សាហកម្មបាន រីងប៉ឹងឡើង ឆ្លងតាមការបង្កើតរោងចក្រស្លដែក និងការនាំចេញ ទៅទូទាំងពិភពលោក។ ទីក្រុងបង្ហាញឲ្យឃើញជាក់ស្តែងថា សង្គមវាយ៉ាងដូចម្តេចកាលពីមុន នៅពេលនេះ និងទៅអនាគត ចង់ក្លាយជាអ្វី។ ក្នុងប្រវត្តិសាស្រ្តកម្ពុជា ទីក្រុងជាកន្លែងដែលរដ្ឋ និងសង្គម បានព្យាយាមកសាងចក្ខុវិស័យរបស់ខ្លួនអំពី ពិភពលោក។ រដ្ឋបាលអាណានិគម បានព្យាយាមកសាងអារ្យធម៌ តំបន់ទីក្រុង តាមរយៈការសាងសង់អគារធំៗ ការរៀបចំកម្មសិទ្ធិ ដីធ្លីដោយដាក់អនុវត្តប្រព័ន្ធសិទ្ធិកាន់កាប់ដីធ្លីបែបអឺរ៉ុប និងការ កសាងហេដ្ឋារចនាសម្ព័ន្ធទំនើបៗដើម្បីសម្រួលដល់ពាណិជ្ជកម្ម។ ក្រុងបាត់ដំបង និងភ្នំពេញ ត្រូវបានអភិវឌ្ឍជាមជ្ឈមណ្ឌល សេដ្ឋកិច្ចដែលតភ្ជាប់ផលិតកម្មកសិកម្ម (ក្នុងទម្រង់ជាដីសម្បទាន គ្រប់គ្រងដោយបារាំង) ទៅទីផ្សារក្នុងតំបន់ និងក្នុងពិភពលោក។ នៅក្រោយរបបអាណានិគម ទីក្រុងនៅកម្ពុជាបានតំណាងឲ្យ សម័យកាលថ្មីមួយនៃទីក្រុងខ្មែរ។ គំនិតជាតិនិយម បានជ្រាប ចូលទៅក្នុងការកសាងទីក្រុង តាមរយៈស្ថាបត្យករខ្មែរឈានមុខ មួយក្រុម ដែលមានលោក វណ្ណ មូលីវណ្ណ ជាចម្បង។ សាកលវិទ្យាល័យ វិមានឯករាជ្យ ក្រសួង និងបណ្ណាល័យជាច្រើន ត្រូវបានកសាងឡើងយ៉ាងលឿន ដើម្បីព្យាយាមប្រែក្លាយទីក្រុង និងអនាគតរបស់កម្ពុជា ឲ្យទៅជារបស់ខ្មែរវិញ។ យុគសម័យ ដ៏ភ្លឺត្រចះនៃនគរូបនីយកម្មនៅកម្ពុជានេះ បានស្ទះដំណើរទៅវិញ ដោយសារសង្គ្រាមស៊ីវិលមួយ ដែលបាននាំមកនូវការអនុវត្ត មនោគមវិជ្ជាដ៏ឃោរឃៅបំផុតនៅក្នុងបរិស្ថានទីក្រុង ពោលគឺ គោលគំនិតប្រឆាំងទីក្រុងរបស់ពួកខ្មែរក្រហម ដែលបានសម្លាប់ រង្គាលប្រជាជននៅទីក្រុង និងបញ្ឈប់ដំណើរការនគរូបនីយកម្ម។ នាបច្ចុប្បន្ន គេបាននិងកំពុងរៀបចំទីក្រុងជាថ្មីម្តងទៀត ទុកជា កន្លែងនាំមុខគេក្នុងការអភិវឌ្ឍប្រទេស។ ទីក្រុងនេះ ក៏ជាកន្លែង មួយដែលមូលធននិយមពិភពលោក វាស្តែងចេញក្រោមរូបភាព ជាដំណើរការផ្នែកវប្បធម៌ និងសេដ្ឋកិច្ចសង្គមកិច្ចផ្សារភ្ជាប់នឹង មូលដ្ឋានច្រើនបែបយ៉ាង។

ទីក្រុងដែលតំណាងឲ្យបណ្តាញក្នុងតំបន់ និងក្នុងពិភព លោកនោះ បានក្លាយជាចំណុចស្នូលនៃគំរូកំណើនសេដ្ឋកិច្ច របស់កម្ពុជាក្នុងរយៈពីរទសវត្សរ៍កន្លងមកនេះ។ មូលធនបរទេស បានដើរតួនាទីស្នូលក្នុងការជំរុញឧស្សាហកម្មកាត់ដេរ សំណង់ និងទេសចរណ៍ ដែលជាមូលដ្ឋានគ្រឹះសម្រាប់កំណើនសេដ្ឋកិច្ច កម្ពុជា។ បើសម្លឹងទៅអនាគត មជ្ឈមណ្ឌលទីក្រុងនឹងដើរតួនាទី សំខាន់បំផុត ដើម្បីសម្រេចឲ្យបានតាមចក្ខុវិស័យរបស់រដ្ឋនៃការ ធ្វើពិពិធកម្មសេដ្ឋកិច្ចចេញពីវិស័យស្នូលមួយចំនួនតូច ឆ្ពោះទៅ កាន់ផលិតផលថ្មីៗទៀតនៃ កម្មន្តសាលកម្ម សេវាកម្ម និង កសិកម្ម និងចក្ខុវិស័យនៃការចាក់ឫសចូលយ៉ាងជ្រៅទៅក្នុង បណ្តាញសេដ្ឋកិច្ចក្នុងតំបន់។ប៉ុន្តែរដ្ឋាភិបាលត្រូវបង្កើនសមត្ថភាព ទាំងខាងហេដ្ឋារចនាសម្ព័ន្ធរឹង (ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត) និងទន់ (ក្របខ័ណ្ឌច្បាប់) ប្រសិនបើចង់ឲ្យតំបន់ទីក្រុងកម្ពុជា ជាពិសេស ទីក្រុងភ្នំពេញ អាចជួយឲ្យចក្ខុវិស័យខាងលើក្លាយជាការពិត។ ចំពោះហេដ្ឋារចនាសម្ព័ន្ធទន់ ការប្រកាសប្រើក្របខ័ណ្ឌច្បាប់ និង បទបញ្ញត្តិដែលរលូនគ្នាល្អជាមួយប្រទេសឯទៀតក្នុងតំបន់ និង ពិភពលោក ដូចជា កំណែទម្រង់ជាច្រើនស្របតាមផែនទីបង្ហាញ ផ្លូវឆ្នាំ២០១៥ របស់សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) បានរួមចំណែកច្រើនណាស់ ក្នុងការជួយឲ្យតំបន់ទីក្រុងទទួល បានផលចំណេញពីវិនិយោគផ្ទាល់ពីបរទេស សមាហរណកម្ម ចូលទៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ក្នុងតំបន់ និងការផ្លាស់ប្តូរចំណេះដឹង ជាមួយក្រុមហ៊ុនពហុជាតិ ស្ថាប័នស្រាវជ្រាវ និងបណ្តាញ ពាក់ព័ន្ធនានា។ ទោះយ៉ាងនេះក្តី ក៏នៅមានបញ្ហាច្រើនទៀតខាង សមត្ថភាពស្ថាប័ន ដែលកំពុងរាំងដល់ការធ្វើសមាហរណកម្ម ស៊ីជម្រៅនាពេលសព្វថ្ងៃ។ ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋាភិបាល បានប្តេជ្ញាចិត្តធ្វើកំណែទម្រង់បណ្តាស្ថាប័ននៅទន់ខ្សោយ ដូចជា ប្រព័ន្ធតុលាការជាដើម ព្រមទាំងបង្កើតរចនាសម្ព័ន្ធតាមស្តង់ដារ ពិភពលោកថ្មីៗ ដែលមានតម្លាភាព និងគណនេយ្យភាព (ឧ. ក្រុមប្រឹក្សាអាជ្ញាកណ្តាល) ដើម្បីបំបាត់ការចែកចាយមិនស្មើភាព នូវព័ត៌មានទីផ្សារដែលកំពុងរាំងដល់ពាណិជ្ជកម្ម និងវិនិយោគ។

ដើម្បីទាញយកអត្ថប្រយោជន៍បានច្រើនបំផុត ពីទំនាក់ទំនង តភ្ជាប់គ្នាក្នុងតំបន់ និងក្នុងពិភពលោកនោះ ការកសាងស្ថាប័ន និង កំណែទម្រង់បទបញ្ញត្តិ ត្រូវបំពេញឲ្យគ្នាទៅវិញទៅមក និងត្រូវ មានការកែលំអហេដ្ឋារចនាសម្ព័ន្ធរឹង ឲ្យបានសមស្របផង។ Harvey (2004) លើកថា ទីក្រុងគឺជាសមាសភាគដ៏សំខាន់បំផុត មួយនៃលទ្ធិមូលធននិយម ដើម្បីព្យាយាមបំបាត់ចម្ងាយ និង គម្លាតពេល រវាងផលិតផល និងទីផ្សារ។ ដើម្បីបំពេញមុខងារនេះ ត្រូវមានការរីកចម្រើនធំៗខាងទូរគមនាគមន៍ ដឹកជញ្ជូន និង សមត្ថភាពផ្នែកផ្គត់ផ្គង់ (logisticalcapacity) ហើយជាថ្មីម្តងទៀត តំបន់ដែលត្រូវផ្តោតការយកចិត្តទុកដាក់ភ្លាមៗ គឺ ទីក្រុងភ្នំពេញ។ អន្តរាគមន៍គោលនយោបាយខាងផ្នែកនេះ អាចកាត់បន្ថយ ចំណាយផលិតកម្ម ជួយប៉ះប៉ូវដល់កំណើនចំណាយបៀវត្សរ៍ និងជំរុញវិនិយោគ។ មជ្ឈមណ្ឌលទីក្រុង ដែលមានហេដ្ឋា រចនាសម្ព័ន្ធតាមស្តង់ដារពិភពលោក ក៏នឹងជួយសម្រួលដល់ ការអភិវឌ្ឍកសិកម្មដែរ តាមការកាត់បន្ថយចម្ងាយរវាងស្រែចំការ នៅខេត្តបាត់ដំបង និងកន្លែងហូបចុកនៅក្រុង ភ្នំពេញ បាងកក ឬស៊ីដនី។ រដ្ឋាភិបាល ដោយមានជំនួយគាំទ្រពីដៃគូ អភិវឌ្ឍន៍នានា បាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងការងារនេះ។ កន្លងមក មានការបង្កើតកម្មវិធីជាច្រើនសម្រាប់ពង្រីកទំនាក់ទំនង តភ្ជាប់គ្នាក្នុងតំបន់ នៅក្រោមគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ នៅមហាអនុតំបន់មេគង្គ ដែលទ្រទ្រង់ដោយធនាគារអភិវឌ្ឍន៍ អាស៊ី (ADB)។ ម្យ៉ាងទៀត ក៏ត្រូវគិតគូរជាសំខាន់ដែរពីតម្រូវការ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈទៅអនាគត ដោយមានធ្វើផែនការ អភិវឌ្ឍន៍ទីក្រុងដ៏សមស្រប ជាពិសេសការរក្សាតុល្យភាពរវាង សេវាសាធារណៈ និងការអភិវឌ្ឍវិស័យឯកជន។ នាបច្ចុប្បន្ន រដ្ឋាភិបាលកំពុងបង្កើតផែនការមេសម្រាប់ទីក្រុងភ្នំពេញ ហើយ ទៅអនាគតទើបឃើញច្បាស់ពីឥទ្ធិពលនៃផែនការនេះ។

## ការអភិវឌ្ឍទីក្រុងសម្រាប់គ្រប់គ្នា

ភាពក្រីក្រនៅទីក្រុង គឺជាទិដ្ឋភាពលេចធ្លោ និងគួរឲ្យបារម្ភ ខ្លាំងមួយនៃនគរូបនីយកម្មនៅកម្ពុជា។ នាបច្ចុប្បន្ន កន្លែងស្នាក់នៅ យ៉ាប់យ៉ឺន អសន្តិសុខក្នុងការកាន់កាប់ និងអវត្តមានយន្តការ

រូបភាព ១៖ ប្រេវ៉ាឡង់នៃអ្នករស់នៅក្នុងសង្កាត់តោកយ៉ាក[២] នៅតាមប្រទេសអាស៊ីអាគ្នេយ៍




*ប្រភព៖ UN-HABITAT (2008: 180)*

ទ្រទ្រង់សង្គមគ្រប់គ្រងដោយរដ្ឋ ជាកត្តាចម្បងដែលបង្ក និងរក្សាអត្រាភាពក្រីក្រនៅតាមទីក្រុងកម្ពុជា ឲ្យស្ថិតក្នុងចំណោមតួលេខខ្ពស់ៗបំផុតក្នុងតំបន់ (រូបភាព ១)។ ប្រសិនបើមិនមានអន្តរាគមន៍ខាងគោលនយោបាយទេនោះ បញ្ហានឹងចោទកាន់តែខ្លាំងឡើងទៀតក្នុងប៉ុន្មានឆ្នាំទៅមុខ។ គេព្យាករថា ពីឆ្នាំ២០០៥ ដល់ ២០១២ ប្រជាជននៅទីក្រុងភ្នំពេញ នឹងកើនឡើងមួយជាពីរ ដល់ ២,៩១លាននាក់ (UN-HABITAT 2008: 167) ហើយប្រជាជនក្រីក្រនៅទីក្រុង នឹងមានចំណែកយ៉ាងធំក្នុងកំណើននេះ។ ប្រសិនបើរដ្ឋាភិបាលមិនធ្វើសកម្មភាពនៅពេលនេះ ដើម្បីអនុវត្តគោលនយោបាយជំរុញឲ្យការរីកចម្រើន ខាងសេដ្ឋកិច្ច និងសង្គមមានលក្ខណៈរាប់បញ្ចូល ពោលគឺ អត្ថប្រយោជន៍នៃកំណើននឹងចែកចាយទៅដល់គ្រប់ស្រទាប់សង្គម និងញ៉ាំងឲ្យនិន្នាការអភិវឌ្ឍន៍ទីក្រុងនៅកម្ពុជា វាមានសមធម៌ និងនិរន្តរភាពនោះទេ ស្ថិរភាពសេដ្ឋកិច្ច និងសង្គមនាពេលអនាគត ពិតជានឹងមានការប៉ះពាល់ធ្ងន់ធ្ងរ។

ប្រវត្តិសាស្ត្របង្ហាញថា ចម្លើយតបរបស់រដ្ឋាភិបាលចំពោះភាពក្រីក្រនៅតំបន់ទីក្រុង អាចបែងចែកជាពីរប្រភេទធំៗ គឺ៖ ១) ចាត់វិធានការសម្រាលភាពក្រីក្រ និងដាក់បញ្ចូលជនក្រីក្រទៅក្នុងរចនាសម្ព័ន្ធទីក្រុង និង ២) ញែកពួកគេចេញពីពិភពទីក្រុង ហើយចាត់ទុកជាក្រុមអន់ថយមួយ ឬជាករណីមិនប្រក្រតីមួយនៃការអភិវឌ្ឍ។ ការផ្លាស់ប្តូរពីគោលនយោបាយនគរូបនីយកម្មប្រឆាំងជនក្រីក្រ ទៅជាគោលនយោបាយនគរូបនីយកម្មគាំទ្រជនក្រីក្រ ត្រូវផ្អែកជាសំខាន់លើការយល់ឃើញរបស់រដ្ឋ និងសង្គម ចំពោះភាពក្រីក្រនៅទីក្រុង ហើយរឿងនេះមួយចំណែកស្ថិតលើការផ្លាស់ប្តូរក្នុងការនិយាយស្តី និងឥរិយាបថផ្នែកវប្បធម៌។ ឧទាហរណ៍ ក្នុងអំឡុងបដិវត្តន៍ឧស្សាហកម្មនៅប្រទេសអង់គ្លេស ទាំងរដ្ឋាភិបាល និងប្រជាជនដែលមានសិទ្ធិបោះឆ្នោតភាគច្រើន ដើមឡើយយល់ឃើញថា ជនក្រីក្រនៅទីក្រុងជា "មនុស្សចម្លែក គ្មានសមត្ថភាព គំរាមកំហែងគេ អសីលធម៌ ដែលតាំងពីដើមរៀងមក រដ្ឋតែងមានគោលនយោបាយភាពក្រីក្រប្រឆាំងនឹងពួកនេះ" (Moore & Putzel 1999: 23)។ រហូតមកដល់លោក Charles Booth ដែលបានលើកទស្សនៈស្តីពី "ជនក្រីក្រដែលគួរជួយ" (deserving poor) (ដែលផ្ទុយពីទស្សនៈជនក្រីក្រមិនគួរជួយ") ទើបមានការរើកញែកពីវណ្ណៈនៃអ្នកខំធ្វើការដែលគួរទទួលបានការជួយទ្រទ្រង់ ហើយទស្សនៈនេះធ្វើឲ្យមានការផ្លាស់ប្តូរគោលនយោបាយផាត់ចេញ ប្រឆាំងនឹងជនក្រីក្រទៅជាគោលនយោបាយរាប់បញ្ចូល ដើម្បីប្រឆាំងនឹងភាពក្រីក្រ។ ការផ្លាស់ប្តូរផ្នែកវប្បធម៌នេះ បានត្រួសត្រាយផ្លូវសម្រាប់គោលនយោបាយសុខមាលភាពសង្គមសម្រាប់គ្រប់គ្នាទាំងអស់ ដូចជាការធានារ៉ាប់រងរបស់ជាតិជាដើម។ តាំងពីដើមរៀងមកនៅកម្ពុជា ការយល់ឃើញជាទូទៅពីជនក្រីក្រនៅទីក្រុង មិនសូវជំរុញឲ្យមានគោលនយោបាយនគរូបនីយកម្មគាំទ្រជនក្រីក្រឡើយ។ ឯកសារយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រចុងក្រោយបំផុត របស់កម្ពុជា (RGC 2002: 85-86) បានកត់សំគាល់ថា៖

> *ទាំងអាជ្ញាធរ និងអ្នកជួរជាវដែលរស់នៅទីក្រុង ច្រើនតែដាក់កំហុសលើជនក្រីក្រ ចំពោះស្ថានភាពដ៏លំបាករបស់ពួកគេ និងចាត់ទុកជនក្រីក្រ ថាជា មនុស្សបង្កគ្រោះថ្នាក់ដល់សង្គម ចូលចិត្តប្រព្រឹត្តអំពើមានទោស ឬក៏មានបញ្ហាខាងខួរក្បាលទៀតផង។ ចម្លើយតបទូទៅពីប្រជាជនថ្នាក់កណ្តាល និងមន្ត្រីនានា គឺជនក្រីក្រនៅទីក្រុង គួរតែបញ្ជូនទៅតំបន់ជនបទដែលពួកគេធ្លាប់រស់នៅនោះវិញ។*

ចំណុចនេះ អាចពិនិត្យឃើញក្នុងគោលនយោបាយផាត់ចេញផ្សេងៗ ដូចជា ការបណ្តេញ និងផ្លាស់ប្តូរកន្លែងទីតាំងសហគមន៍ក្រីក្រនៅទីក្រុង ជាដើម។

នាបច្ចុប្បន្នមានមានសញ្ញាបង្ហាញថា ការយល់ឃើញអវិជ្ជមានពីជនក្រីក្រនៅទីក្រុង អាចកំពុងផ្លាស់ប្តូរ ដោយសារជាសំខាន់ សកម្មភាពបែបថ្មីរបស់អង្គការសង្គមស៊ីវិល ដូចជាមូលនិធិអភិវឌ្ឍន៍ជនក្រីក្រនៅទីក្រុង (UPDF)[៣] ជាដើម។ UPDF ជួយជនក្រីក្រកែលំអកន្លែងតាំងលំនៅ តាមរយៈគម្រោងហេដ្ឋារចនាសម្ព័ន្ធដឹកនាំដោយសហគមន៍ ដោយបានផ្តល់ប្រាក់កម្ចីដល់ជនក្រីក្រ និងជំរុញការចូលរួម និងកិច្ចសហការរវាងសហគមន៍ក្រីក្រ រដ្ឋាភិបាល និងវិស័យឯកជន ដើម្បីព្យាយាមដោះស្រាយបញ្ហាផ្សេងៗ ដូចជា លក្ខខណ្ឌរស់នៅគ្មានអនាម័យ

---

[២] UN-HABITAT (2008: 33) ឲ្យនិយមន័យគ្រួសារនៅសង្កាត់តោកយ៉ាកថា ជាបុគ្គល ឬមនុស្សមួយក្រុម ដែលរស់នៅក្រោមដំបូលផ្ទះតែមួយ នៅក្នុងតំបន់ទីក្រុង ហើយខ្វះខាតគ្រឿងសម្រួលការមួយ ឬច្រើន ក្នុងចំណោមប្រាំមុខដូចតទៅ៖ ផ្ទះជាប់លាប់ កន្លែងរស់នៅមានទំហំគ្រប់គ្រាន់ លទ្ធភាពប្រើប្រាស់ទឹកបានកែលំអគុណភាព លទ្ធភាពប្រើសេវាអនាម័យបានកែលំអគុណភាព និងការកាន់កាប់មានសន្តិសុខ។ ដោយសារនៅតាមប្រទេសភាគច្រើន គេមិនអាចរកបានព័ត៌មានស្តីពី ការកាន់កាប់មានសន្តិសុខ ដូច្នេះមានតែសូចនាករបួនខាងដើមប៉ុណ្ណោះ ដែលបានយកមកប្រើដើម្បីកំណត់និយមន័យគ្រួសារនៅសង្កាត់តោកយ៉ាក។

[៣] មាន NGOs នៅទីក្រុងជាច្រើនទៀត ដែលបាននិងកំពុងធ្វើការងារដើម្បីផ្តល់សិទ្ធិអំណាចដល់ជនក្រីក្រនៅទីក្រុង ជាអាទិ៍ ក្រុមការងារផ្នែកទីក្រុង (USG) (បច្ចុប្បន្ន បានរំសាយហើយ) និងអង្គការអភិវឌ្ឍស្ត្រីក្រីក្រនៅទីក្រុង (UPWD ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៧ និងទ្រទ្រង់ដោយ អង្គការ ActionAid International-Cambodia) ជាដើម។ UPDF បង្កើតឡើងនៅឆ្នាំ១៩៩៨។

ការកាន់កាប់គ្មានសន្តិសុខ និងកង្វះហេដ្ឋារចនាសម្ព័ន្ធសេវាកម្ម (e.g. Phonphakdee *et al.* 2009)។ នៅឆ្នាំ២០០៩ UPDF ជួយទ្រទ្រង់ក្រុមសន្សំប្រាក់បានដល់ ២០០០ក្រុម (ក្នុង ២៦ក្រុង) ដែលមានសមាជិក ២៤.០០០នាក់ និងអះអាងថា សន្សំប្រាក់បានលើសពី ៧០០.០០០ដុល្លារ ដូច្នេះបើគិតចាប់ពីពេលកកើតឡើង មូលនិធិនេះផ្តល់កម្ចីបានជាង ២.០០០.០០០ដុល្លារ ទៅឲ្យសហគមន៍ក្រីក្រនៅទីក្រុង (Mitlin *et al.* 2011:37)។ UPDF បានជួយសម្រួលសកម្មភាពសមូហភាពរបស់ប្រជាជនសាមញ្ញ ដែលកែលំអផលប៉ះពាល់របស់ជនក្រីក្រទៅលើទីក្រុង ទាំងផ្នែកសោភ័ណភាព និងផ្នែកសេដ្ឋកិច្ចសង្គមកិច្ច។ តាមសកម្មភាពនេះ UPDF បានទប់ទល់នឹងគំនិតចាក់ឫសតាំងពីដើម ដែលថា អ្នកក្រជាមនុស្សខ្ជិល និងជាដើមហេតុនៃភាពក្រីក្ររបស់ខ្លួន។ UPDF ក៏បានជំរុញការតភ្ជាប់រវាង អង្គការជនក្រីក្រនៅទីក្រុង និងរដ្ឋាភិបាល ហើយតាមនេះ បានបង្កើនការទទួលស្គាល់ជាផ្លូវការនូវសិទ្ធិរបស់ជនក្រីក្រក្នុងការតាំងទីលំនៅក្នុងតំបន់ទីក្រុង។ ប្រសិនបើអាចបញ្ចុះបញ្ចូលរដ្ឋាភិបាល និងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត ឲ្យយល់ពីតម្រូវការអន្តរាគមន៍គាំទ្រដល់ជនក្រីក្រនោះ ខាងផ្នែកគោលនយោបាយ ក៏នឹងដើរតាមនោះដែរ។

ការអភិវឌ្ឍទីក្រុងសម្រាប់គ្រប់គ្នា មិនត្រឹមតែជាកាតព្វកិច្ចផ្នែកសីលធម៌ប៉ុណ្ណោះទេ វាក៏ជាបុព្វលក្ខខណ្ឌសម្រាប់នគរូបនីយកម្មមានចីរភាពល្អដែរ ទាំងផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច។ តួយ៉ាង Ha (2001) បានកត់សម្គាល់ថា នៅទសវត្សរ៍១៩៧០ គោលនយោបាយអាជ្ញាធរក្រុងសេអ៊ូល គឺ ការផាត់ជនក្រីក្រចេញពីទីក្រុង ទៅកាន់តំបន់ជាយក្រុង។ ក្នុងការស្វែងរកឱកាសចិញ្ចឹមជីវិត គ្រួសារក្រីក្រនានា ក៏តាំងលំនៅបែបអនាធិបតេយ្យជាថ្មីនៅក្នុងទីក្រុង ដែលជារឿយៗមានស្ថានភាពកាន់តែយ៉ាប់យ៉ឺនជាងមុនទៀត។ ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋបានបង្កើតក្របខ័ណ្ឌគម្រោងអភិវឌ្ឍន៍ឡើងវិញរួមគ្នា ដែលជួយសម្រួលដល់កិច្ចសហការជាដៃគូរវាង សហគមន៍ក្រីក្រនៅទីក្រុង និងវិស័យឯកជន ដើម្បីអភិវឌ្ឍឡើងវិញនូវតំបន់អនាធិបតេយ្យ។ ក្របខ័ណ្ឌនេះបានវិវត្តទៅមុខ ហើយទោះបីមានការមិនឯកភាពគ្នាខ្លះអំពីជោគជ័យក្នុងបញ្ហានេះក្តី (e.g. Shin 2008) ក៏គោលនយោបាយសម្រាប់ការស្នាក់នៅរយៈពេលវែង ពិតជាបានផ្លាស់ប្តូរពីការផាត់ចេញ ទៅជាការរាប់បញ្ចូលវិញ ហើយបានជះឥទ្ធិពលល្អទៅលើគន្លងនៃការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចនៅទីក្រុង។ ក្នុងអំឡុងពីរបីទសវត្សរ៍ចុងក្រោយនេះ គោលនយោបាយរដ្ឋាភិបាលកម្ពុជា មានលក្ខណៈដូចគ្នានឹងគោលនយោបាយក្រុងសេអ៊ូលនៅទសវត្សរ៍១៩៧០ ដែរ៖ ការបណ្តេញចេញ ជាគោលនយោបាយសម្រាប់ដោះស្រាយជាទូទៅ ចំពោះការតាំងលំនៅមិនផ្លូវការ ហើយគ្រួសារជាច្រើនបានផ្លាស់ទីពីតំបន់ជាយៗនោះចូលមកក្នុងទីក្រុងវិញ (Khemro & Payne 2004)។ ប៉ុន្តែនាពេលថ្មីៗនេះ មានករណីជាច្រើនដែលរដ្ឋាភិបាលបានជួយសម្រួលការកែលំអតំបន់ តាមការលើកទឹកចិត្តឲ្យសហគមន៍ ចូលពាក់ព័ន្ធជាមួយនឹងវិស័យឯកជន។ តួយ៉ាង សម្រាប់សហគមន៍នៅបុរីកីឡា ដំណោះស្រាយធ្វើការអភិវឌ្ឍឡើងវិញ ដោយមានការបែងចែកដីគ្នា និងការចូលរួមជាដៃគូជាមួយវិស័យឯកជន បាននាំឲ្យមានការសាងសង់នូវប្លុកផ្ទះល្វែង ផ្តល់ទៅឲ្យគ្រួសារដែលរស់នៅកន្លែងនោះ ហើយយកដីដែលនៅសល់ ទុកសម្រាប់ប្រើការផ្សេងទៀត។ ការអនុវត្តគម្រោងនេះ បានជួបបញ្ហាធ្ងន់ធ្ងរជាច្រើន ប៉ុន្តែយ៉ាងហោចណាស់ក៏ជាសញ្ញាបង្ហាញថា រដ្ឋាភិបាលបានផ្លាស់ប្តូរវិធីសាស្រ្ត និងមានបំណងដាក់បញ្ចូលអ្នកដែលកំពុងរស់នៅទីនោះ ទៅក្នុងគម្រោងអភិវឌ្ឍន៍នាថ្ងៃអនាគត៖ គំរូនេះ គួរត្រូវចម្លងតាម និងពង្រឹងបន្ថែមទៅថ្ងៃខាងមុខ។

នៅមានផលចំណេញខាងសេដ្ឋកិច្ចជាច្រើនទៀត ក្នុងការរាប់បញ្ចូលជនក្រីក្រនៅទីក្រុងនេះ៖ សេដ្ឋកិច្ចមិនផ្លូវការ អាចជាប្រភពចំណូលរដ្ឋាភិបាល និងជាប្រភពកំណើនសេដ្ឋកិច្ចមានសក្តានុពលធំធេងតែមិនទាន់ប្រើការ។ De Soto (2000) បានអះអាងថា នាបច្ចុប្បន្ន ប្រាក់រាប់ពាន់លានដុល្លារ កំពុងដេកស្ងៀមដូច "មូលធនងាប់" នៅក្នុងសេដ្ឋកិច្ចមិនផ្លូវការរបស់ប្រទេសកំពុងអភិវឌ្ឍ។ Beall and Fox (2009) បានលើកថា វិស័យមិនផ្លូវការនៅកម្ពុជាមានទំហំធំ ដោយសារមានបែបបទការិយាធិបតេយ្យច្រើនរាំងបុគ្គលនានា នៅក្នុងវិស័យមិនផ្លូវការក្នុងការចុះបញ្ជីអាជីវកម្មរបស់ខ្លួនជាផ្លូវការ ឲ្យក្លាយទៅជាអាជីវកម្មស្របច្បាប់ ហើយចាកផុតពីស្ថានភាពមិនផ្លូវការនេះ ដែលនាំឲ្យមានបន្ទុកចំណាយខ្ពស់ និងជួបហានិភ័យច្រើន។ ការលុបបំបាត់ឧបសគ្គទាំងនេះ អាចជួយជំរុញគំនិតច្នៃប្រឌិតសហគ្រិនភាព កំណើនសេដ្ឋកិច្ចសម្រាប់គ្រប់គ្នា ព្រមទាំងផ្តល់ឲ្យរដ្ឋាភិបាលនូវចំណូលជាច្រើនទៀត សម្រាប់ដោះស្រាយតម្រូវការបង្កើនចំណាយសាធារណៈ។

## ការធ្វើផែនការសម្រាប់អនាគត - តម្រូវការរបៀបវារៈស្រាវជ្រាវពីទីក្រុង

នគរូបនីយកម្ម ជាទិដ្ឋភាពមួយនៃការអភិវឌ្ឍនៅកម្ពុជា ដែលមានការស្រាវជ្រាវតិចតួចណាស់។ ភាគច្រើននៃរបៀបវារៈស្រាវជ្រាវ បានផ្តោតលើវិស័យកសិកម្ម ដែលតាំងពីដើមរៀងមកគេតែងយល់ថា វាសំខាន់បំផុតសម្រាប់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រទៅថ្ងៃអនាគត។ ការពិនិត្យត្រួសៗទៅលើផលិតផលរបស់ស្ថាប័នស្រាវជ្រាវធំៗនៅកម្ពុជា របៀបវារៈសន្និសីទ និងការបោះពុម្ពផ្សាយរបស់ដៃគូអភិវឌ្ឍន៍ បានបង្ហាញពីភាពលំអៀងខ្លាំងទាក់ទងនឹងការស្រាវជ្រាវនេះ។ របៀបវារៈស្រាវជ្រាវផ្តោតលើទីជនបទ វាផុសចេញមួយផ្នែកពីរចនាសម្ព័ន្ធផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ និងតំណាងឲ្យមនោគមវិជ្ជាបន្សល់ទុកពីសម័យសេរីនិយមបែបថ្មី ជាពិសេសទ្រឹស្តី "លំអៀងទីក្រុង (urban bias)" ដែលពេញនិយមនៅពេលនោះ និងលំអៀងទៅខាងអន្តរាគមន៍គោលនយោបាយនៅជនបទ ជាជាងនៅទីក្រុង។ ដោយពិភពលោកបានឈានចូលក្នុងសតវត្សរ៍នគររូបនីយកម្ម ដូច្នេះត្រូវតែទទួលស្គាល់ពីតួនាទីដ៏សំខាន់បំផុតនៃតំបន់ទីក្រុងក្នុងដំណើរការអភិវឌ្ឍន៍។

របៀបវារៈស្រាវជ្រាវពីទីក្រុង ក៏ជួបឧបសគ្គដែរ ដោយសារការជជែកវែកញែកពីរបៀបវារៈនេះ ត្រូវជួបរហូតនឹងបញ្ហាសិទ្ធិ

កាន់កាប់ដីធ្លីដែលអង្គការសិទ្ធិមនុស្ស តែងលើកឡើងតទល់នឹងរដ្ឋ។ ជាលទ្ធផល កិច្ចសន្ទនាពីការអភិវឌ្ឍទីក្រុងបានបង្កជាការបែងចែកជាបក្សពួក ភាគច្រើនគ្រាន់តែជាការនិយាយយកឈ្នះ ហើយអាចរួមចុះមកផ្តោតតែលើបញ្ហាមួយនៃការជជែកវែកញែកពីសិទ្ធិមនុស្ស និងមានឥទ្ធិពលតិចតួចខាងគោលនយោបាយ។ កិច្ចសន្ទនាមានកម្រិតបែបនេះ មិនអំណោយផលដល់របៀបវារៈស្រាវជ្រាវរស់រវើក ដែលអាចរកឃើញបញ្ហាច្រើនបែបយ៉ាង និងផ្តល់មតិពីដំណោះស្រាយផ្សេងៗខាងគោលនយោបាយនោះទេ។ ម្យ៉ាងទៀត ទោះបីការសន្ទនារវាង NGOs ខាងសិទ្ធិមនុស្ស និងរដ្ឋ គឺជាយន្តការដ៏សំខាន់សម្រាប់លើកស្ទួយសិទ្ធិរបស់ជនក្រីក្រនៅទីក្រុងក្តី ក៏វាមិនគួររារាំង NGOs ជាច្រើនទៀត ក្នុងការចូលរួមជាមួយរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាផ្សេងទៀត ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍទីក្រុងសម្រាប់គ្រប់គ្នានោះទេ។ Phonphakdee *et al.* (2009: 579) បានគូសបញ្ជាក់ពីបញ្ហាប្រឈមរបស់អង្គការ ដូចជា UPDF ជាដើម ដែលព្យាយាមចូលរួមធ្វើការជាមួយរដ្ឋ ដោយកត់សម្គាល់ថា "គោលគំនិតចូលរួមធ្វើការជាមួយរដ្ឋាភិបាលនេះ មិនងាយទទួលយកបានទេ សម្រាប់សកម្មជន ឬ NGO ជាច្រើន ដែលតែងយល់ឃើញជាយូរមកហើយថា រដ្ឋាភិបាលជាភាគីមិនល្អនោះ"។ ទោះយ៉ាងនេះក្តី វិធីសាស្ត្រធ្វើការរួមគ្នាលើបញ្ហាភាពក្រីក្រនៅទីក្រុងនេះ ពិតជាសំខាន់បំផុត ដើម្បីលើកកម្ពស់ការយល់ដឹងពីតំបន់ទីក្រុងនៅកម្ពុជា និងកែលំអជីវភាពជនក្រីក្រនៅទីក្រុង។

ទាក់ទងនឹងអាទិភាព ខាងគោលនយោបាយទីក្រុងវិញ ក្នុងវិធានការរយៈពេលខ្លី ដោយពុំមានកម្មវិធីប្រព័ន្ធសុវត្ថិភាពសង្គមសម្រាប់គ្រួសារក្រីក្រនៅទីក្រុង ដែលឧបត្ថម្ភដោយរដ្ឋនោះ រដ្ឋាភិបាល គួរផ្តល់ការគាំទ្របន្ថែមទៀតដល់ក្រុមសង្គមស៊ីវិល ដូចជា UPDF ជាដើម។ នៅក្នុងរយៈពេលមធ្យម ទៅរយៈពេលវែង ក្របខ័ណ្ឌសកម្មភាពផ្តួចផ្តើមឡើងដោយ UPDF អាចផ្តល់ជាមេរៀន និងយន្តការសំខាន់ៗសម្រាប់សកម្មភាពរបស់រដ្ឋទៅអនាគត។ ការតភ្ជាប់រវាងសហគមន៍ និងរដ្ឋាភិបាល ផ្តល់នូវច្រកទាក់ទងផ្តល់ព័ត៌មានដ៏មានប្រយោជន៍មួយរវាង តម្រូវការនៃពួកគ្រួសារក្រីក្រនៅទីក្រុង និងអ្នកធ្វើគោលនយោបាយ។ វាក៏ជួយកាត់បន្ថយចំណាយប្រតិបត្តិការ ដោយធានាថាអន្តរាគមន៍គោលនយោបាយទៅថ្ងៃអនាគត ពិតជាស្របតាមការពិតជាក់ស្តែង។ ការតភ្ជាប់នេះ អាចបង្កើនឥទ្ធិពលនៃគោលនយោបាយគាំទ្រជនក្រីក្រទៅថ្ងៃអនាគត បានយ៉ាងច្រើន។ ដោយមើលឲ្យហួសពីភាពក្រីក្រនៅទីក្រុង ដែលមានច្រើនពាសពេញនេះ រដ្ឋាភិបាលគួរផ្តោតកម្លាំងលើការពង្រឹងហេដ្ឋារចនាសម្ព័ន្ធរឹង និងទន់ ដើម្បីអាចជួយសម្រួលវិនិយោគ និងពាណិជ្ជកម្មក្នុងតំបន់បានកាន់តែប្រសើរ។ គោលដៅនេះ មានលក្ខណៈពាក់ព័ន្ធល្អ ជាពិសេសក្នុងឆ្នាំនេះ ដែលប្រទេសកម្ពុជាកំពុងទទួលវេណធ្វើជាប្រធានអាស៊ាន។ បញ្ហាជាទូទៅនៅពេលនេះ គឺ ការពង្រឹងសមត្ថភាពស្ថាប័នដើម្បីអនុវត្តគោលនយោបាយមានស្រាប់ ដែលលើកទឹកចិត្តដល់ពិពិធកម្មវិនិយោគ និងពាណិជ្ជកម្មនៅទីក្រុង។ ដូច្នេះ បណ្តាញស្ថាប័នស្រាវជ្រាវនៅកម្ពុជា ត្រូវតែជំរុញរបៀបវារៈស្រាវជ្រាវសព្វគ្រប់ និងមានតុល្យភាពល្អមួយពីទីក្រុង ហើយតាមនេះ អាចជួយដល់រដ្ឋាភិបាល ក្នុងការជំរុញឲ្យមានការរីកចម្រើនទីក្រុងប្រកបដោយចីរភាព និងសម្រាប់គ្រប់គ្នា។

## ឯកសារយោង


Beall, J. & S. Fox (2009), *Cities and Development* (London: Routledge)

De Soto (2000), *The Mystery of Capital: Why Capitalism Triumphs in the West and Fails Everywhere Else* (New York: Basic Books)

Ear, S. (1995), *Cambodia's Economic Development in Historical Perspective: A Contribution to the Study of Cambodia's Economy,* available at: http://www.csua.berkeley.edu/~sophal/econ.pdf (accessed 4 June 2012)

Ha, S.K. (2001), "Developing a community-based approach to urban redevelopment", *GeoJournal*, Vol. 53, pp. 39-45

Harvey, D. (2004), *The Condition of Postmodernity: An Inquiry into the Origins of Cultural Change* (Oxford: Blackwell)

Helmers, K. (1997), "Rice in the Cambodian Economy: Past and Present", in H.J. Nesbitt (ed.), *Rice Production in Cambodia* (Manila: IRRI) pp. 1-14

Khemro, B.H.S. & G. Payne (2004),"Improving tenure security for the urban poor in Phnom Penh, Cambodia: an analytical case study", *Habitat International*, Vol. 28, No. 2, pp. 181-201

Mitlin, D., D. Satterthwaite & S. Barlett (2011), *Capital, Capacities and Collaboration: The Multiple Roles of Community Savings in Addressing Urban Poverty,* International Institute for Economic Development Human Settlements Working Paper (London: IIED)

Moore, M. & J. Putzel (1999), *Thinking Strategically about Politics and Poverty,* Institute of Development Studies Working Paper 101 (Brighton: IDS)

Phonphakdee, S., S. Visal & G. Sauter (2009), "The Urban Poor Development Fund in Cambodia: supporting local and citywide development", *Environment and Urbanization,* Vol. 21, No. 2, pp. 569-586

Royal Government of Cambodia (2002), *National Poverty Reduction Strategy Paper 2003-2005* (Phnom Penh: RGC)

Shin, H.B. (2008), "Living on the edge: financing post-displacement housing in urban redevelopment projects in Seoul", *Environment and Urbanization,* Vol. 20, No. 2, pp. 411-426

UN-HABITAT (2008), *State of the World's Cities 2010/2011: Bridging the Urban Divide* (London: Earthscan)

World Bank (2012), World Development Indicators (WDI) [online], available at: http://databank.worldbank.org/ddp/home.do (accessed 4 June 2012)

# មូលធនសង្គមក្នុងសហគមន៍នៅតំបន់ទីក្រុង និងជនបទ នៅកម្ពុជា[១]

## សេចក្តីផ្តើម

សង្គមវិទូ James Coleman (1988) និងអ្នកវិទ្យាសាស្ត្រនយោបាយ Robert Putnam (1993) នាពេលថ្មីៗនេះ បានសិក្សា និងផ្សព្វផ្សាយបង្កើនប្រជាប្រិយភាពនៃទស្សនៈមូលធនសង្គមក៏ពិតមែន ប៉ុន្តែមានអ្នកឈានមុខជាច្រើននាក់ទៀត ដូចជា Lyda Judson Hanifan (1920), Jane Jacobs (1961), Pierre Bourdieu and Jean-Claude Passeron (1970) និង Glenn Loury (1977) ដែលបានយកទស្សនៈនេះមកបញ្ចូលក្នុងមុខវិជ្ជាវិទ្យាសាស្ត្រសង្គមតាំងពីមុននោះម្លេះ (cited in Sen 2010)។ Putnam បានកំណត់និយមន័យមូលធនសង្គមជា "លក្ខណៈនៃរចនាសម្ព័ន្ធសង្គម ដូចជា បណ្តាញ បទដ្ឋាន និងទំនុកចិត្តជាដើម ដែលផ្តល់ភាពងាយស្រួលដល់ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការដើម្បីផលចំណេញទៅវិញទៅមក" (Putnam 1993: 36) ហើយស្នាដៃរបស់គាត់ បានជួយបំផុសឲ្យមានការសរសេរឯកសារជាច្រើនអំពីទស្សនៈនេះ (Maloney *et al.* 2000; Lowndes & Wilson 2001; Wallis 2002)។

Putnam (1993) បានលើកថា ប្រពៃណីអំពីតួនាទីពលរដ្ឋនៅក្នុងសហគមន៍ មានឫសគល់នៅក្នុងប្រវត្តិសាស្ត្រ និងវប្បធម៌។ អ្នកនិពន្ធផ្សេងទៀត ក៏បានសិក្សាពីឥទ្ធិពលនៃមូលធនសង្គម ទៅលើការឆ្លើយតប និងប្រសិទ្ធភាពនៃបណ្តាស្ថាប័ននៅមូលដ្ឋាន (Newton 2001) ភាពជាសមាជិកនៃសមាគម និងអាកប្បកិរិយា និងសីលធម៌ជាពលរដ្ឋ (Wollenbxk & Selle 2003) ឥទ្ធិពលនៃបទពិសោធន៍ចងជាសមាគម (Hooghe 2003; Molenaers 2003; Stolle 2003; Veenstra 2003) និងឥទ្ធិពលនៃដង់ស៊ីតេការចូលជាសមាគម (de Hart & Dekker 2003)។

ធនាគារពិភពលោក មើលឃើញថា មូលធនសង្គមជាកត្តាដ៏សំខាន់មួយ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចរបស់សង្គម៖ "មូលធនសង្គមនៃសង្គមមួយ រួមមាន ស្ថាប័ននានា ទំនាក់ទំនងអាកប្បកិរិយា និងតម្លៃសីលធម៌ដែលគ្រប់គ្រងអន្តរកម្មរវាងប្រជាជន ហើយរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម" (Krishnamurthy 1999)។ មូលធនសង្គមវាផ្សារភ្ជាប់ខ្លួននៅក្នុងរចនាសម្ព័ន្ធស្ថាប័ន សង្គម និងវប្បធម៌របស់សង្គមមួយ។

រូបភាព ១៖ មូលធនសង្គមជាភាពផ្សារភ្ជាប់ ស្ពានចម្លង និងភាពតភ្ជាប់ចុះឡើង




*ប្រភព៖ Pellini & Ayres, (2005: 8)*

មូលធនសង្គមមានបីផ្នែក៖ ភាពផ្សារភ្ជាប់ ស្ពានចម្លង និងភាពតភ្ជាប់ទំនាក់ទំនងចុះឡើង។ ផ្នែកទី១ (ចំណងតភ្ជាប់ខ្លាំង) សំដៅដល់ "ការពង្រឹងចំណងទាក់ទងទៅវិញទៅមករវាងបុគ្គលនានាក្នុងសហគមន៍" រីឯផ្នែកទី២ (ចំណងតភ្ជាប់ខ្សោយ) សំដៅដល់ "ការចងជាសមាគមរបស់ក្រុមផ្សេងៗក្នុងសង្គម" (Halpern & Granovetter cited in Bouka 2008: 11)។ មូលធនសង្គមជាភាពផ្សារភ្ជាប់ វាមានលក្ខណៈផ្ទៃក្នុង និងមានប្រយោជន៍សម្រាប់ "ការកសាងអត្តសញ្ញាណសហគមន៍យ៉ាងរឹងមាំ" ហើយមូលធនសង្គមជាស្ពានចម្លង វាមានឥទ្ធិពលទៅខាងក្រៅ និងអាច "កសាងនូវបណ្តាញនៃបណ្តាញផ្សេងៗ" (Shopeju & Ojukwu 2008:6)។ រីឯផ្នែកទី៣ គឺភាពតភ្ជាប់ទំនាក់ទំនងចុះឡើង (ឬថាមពលចម្រុះ - synergy) សំដៅដល់ "ទំនាក់ទំនងរវាងស្រទាប់ផ្សេងៗនៃសង្គម ដូចជា ទំនាក់ទំនងរវាងរដ្ឋ និងសហគមន៍ ឬទំនាក់ទំនងរវាងសហគមន៍ ឬស្ថាប័ននានា ដែលមានធនធាន ឬអំណាចមិនស្មើគ្នា" (Bouka 2008: 13)។ ដោយសង្ខេប មូលធនសង្គមជាភាពផ្សារភ្ជាប់ និងស្ពានចម្លង សំដៅដល់ទំនាក់ទំនងតាមខ្សែផ្តេក រីឯមូលធនសង្គមជាភាពតភ្ជាប់ចុះឡើង វាសង្កត់ធ្ងន់លើទំនាក់ទំនងតាមខ្សែបញ្ឈរ (រូបភាព១)។

អង្កេតនេះបានធ្វើឡើងសំដៅកំណត់ពីការពិតជាក់ស្តែង និងសក្តានុពលនៅតាមមូលដ្ឋាន ដើម្បីបង្កើតយន្តការសង្គមឲ្យបានកាន់តែប្រសើរ តាមរយៈការពិនិត្យពីសង្គម សេដ្ឋកិច្ច និងអ្នកពាក់ព័ន្ធនានា នៅតាមតំបន់ជនបទ និងទីក្រុងនៅកម្ពុជា។ អង្កេតនេះផ្តោតលើប្រធានបទបួនសំខាន់ៗ គឺទំនុកចិត្តក្នុងសង្គម ការថែទាំនិងកែលំអជីវភាព ហានិភ័យនិងប្រព័ន្ធសុវត្ថិភាពសង្គម និងទម្លាប់/ពិធីក្នុងសង្គម។ អង្កេតបានធ្វើឡើង នៅភូមិជនបទមួយក្នុងខេត្តព្រៃវែង និងភូមិតំបន់ទីក្រុងមួយក្នុងខេត្តសៀមរាប ព្រមទាំង

---

[១] អត្ថបទនេះរៀបរៀងឡើងដោយលោក សែន វិចិត្រ ជាអ្នកស្រាវជ្រាវ និង កញ្ញា ហៀង ធីរ៉ាភមរី ជាជំនួយការកម្មវិធី ក្នុងកម្មវិធីអភិវឌ្ឍន៍សង្គមនៃវិទ្យាស្ថាន CDRI ។ អត្ថបទនេះសង្ខេបពីលទ្ធផលសំខាន់ៗបានមកពីអង្កេតលើស្ថានភាពមូលធនសង្គមនៅកម្ពុជា ដែលទទួលបានហិរញ្ញប្បទានពីមជ្ឈមណ្ឌលសម្រាប់ការសិក្សាមូលធនសង្គម នៃវិទ្យាស្ថានដើម្បីការអភិវឌ្ឍចំណេះដឹងសង្គម នៃសាកលវិទ្យាល័យ Senshu នៅប្រទេសជប៉ុន។ អង្កេតបានធ្វើឡើងពីខែកញ្ញា ២០១១ ដល់ មករា ២០១២។

បានជ្រើសរើសតាមលក្ខណៈជាប្រព័ន្ធនូវ សំណាកបានទាំងអស់ ៤០០គ្រួសារ (២០០គ្រួសារក្នុងមួយភូមិៗ)។

## លទ្ធផលសំខាន់ៗ

### *ទំនុកចិត្តក្នុងសង្គម*

ក្នុងសង្គមកម្ពុជា ទំនុកចិត្តតាំងពីដើមរៀងមកផ្តោតលើការជាប់សាច់ឈាមជាគ្រួសារ និងស្ថិតក្នុងក្រុមតូចមួយនៃសាច់ញាតិជិតៗ (Grahn 2006)។ ភូមិកម្ពុជានានាតែងរៀបចំឡើងនៅជុំវិញសាច់ញាតិនេះ និងខ្វះខាតលក្ខណៈ "សមាគមផ្សេងៗនៃប្រជាជនដើមជាប្រពៃណី និងមានការរៀបចំល្អ ក្លឹបផ្សេងៗ បក្សពួក ឬក្រុមផ្សេងទៀតដែលត្រូវបានបង្កើតឡើងដោយឈរលើគោលការណ៍មិនមែនសាច់ញាតិ" (Ebihara 1968: 181)។ ដូចក្នុងសង្គមឯទៀតនៅអាស៊ីដែរ គ្រួសារជា "គំរូដើមនៃអង្គការសង្គមទាំងអស់"។ គំនិតចម្បង គឺមនុស្សម្នាក់មិនមែនជាបុគ្គលម្នាក់ទេ ប៉ុន្តែជាសមាជិកម្នាក់ក្នុងគ្រួសារ" (Hofstede cited in Pearson 2005: 3)។ គ្រួសារជាឯកតាមូលដ្ឋាននៃសង្គម ដែលជាប្រភព និងដែនកំណត់នៃទំនុកចិត្ត ពោលគឺ ទំនុកចិត្តមានកម្រិតព្រំដែនតែត្រឹមគ្រួសារតែប៉ុណ្ណោះ (UNICEF 1996)។ ទំនុកចិត្តមានកំណត់នេះ ជាលទ្ធផលនៃរដ្ឋបាលប្រមូលផ្តុំ និងសេដ្ឋកិច្ចប្រើរូបិយវត្ថុ ដែលអាណានិគមបារាំងបានយកមកអនុវត្ត និងដែល "បានសង្កត់ធ្ងន់លើជំហរបុគ្គលនិយម និងបានកាត់បន្ថយស្មារតីសាមគ្គីភាពរវាងបុគ្គលនានា" (Pellini 2005: 8)។ ក្នុងសម័យមុនអាណានិគម ភូមិនៅកម្ពុជាមានលក្ខណៈជា សង្គមមួយដែលជីវិតរស់នៅពឹងផ្អែកលើ "និមិត្តរូបវប្បធម៌ សាសនា បែបបទសីលធម៌ និងសកម្មភាពសហគមន៍រួមគ្នា" (Gyallay- Pap cited in Pellini 2005: 8)។

បន្ទាប់ពីបានឯករាជ្យរហូតដល់ឆ្នាំ១៩៧០ កម្ពុជាមានស្មារតីសាមគ្គី និងស្មារតីសហគមន៍យ៉ាងរឹងមាំ៖ "ប្រជាជនមានធនធានគ្រប់គ្រាន់សម្រាប់ជីវភាពរស់នៅ ដូច្នេះអាចមានសប្បុរសធម៌ជាមួយសមាជិកគ្រួសារដែលមិនសូវធូរធារ និងប្រជាជនក្រីក្រផ្សេងទៀត" (UNICEF 1996: 41)។ បែបបទនៃសាមគ្គីភាព និងការជួយគ្នាទៅវិញទៅមកទាំងនេះ បានផ្លាស់ប្តូរយ៉ាងលឿននៅពេលដែលកម្ពុជាធ្លាក់ចូលក្នុងសង្គ្រាមរ៉ាំរ៉ៃយូរឆ្នាំ ជាពិសេសរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ជម្លោះរ៉ាំរ៉ៃបានបង្កការខូចខាតមិនអាចស្តារឡើងវិញបាន ដល់វប្បធម៌ដ៏យូរលង់របស់កម្ពុជា។ ទោះបីអ្នកស្រាវជ្រាវមួយចំនួន (Krishnamurthy 1999; Kim 2001; Ledgerwood & Vijghen 2002; Pellini 2005) យល់ថា មូលធនសង្គមនៅកម្ពុជាបានទទួលរងការខូចខាត ប៉ុន្តែមិនមែនបំផ្លាញខ្ទេចដោយសង្គ្រាមស៊ីវិល និងរបបខ្មែរក្រហមក្តី ក៏លក្ខណៈនៃមូលធនសង្គម និងអន្តរកម្មក្នុងសង្គមនៅកម្ពុជានាបច្ចុប្បន្ន បានឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីផលប៉ះពាល់នៃសង្គ្រាម៖ "កង្វះទំនុកចិត្ត ការភ័យខ្លាច និងការបាក់បែកទំនាក់ទំនងក្នុងសង្គម នៅកម្ពុជាក្នុងពេលសព្វថ្ងៃ" (O'Leary & Meas 2001: 64)។

នៅកម្ពុជាក្រោយសម័យសង្គ្រាមនេះ ទំនុកចិត្តបានក្លាយជាកត្តាខ្វះខាតមួយ (UNICEF 1996)។ តម្លៃសីលធម៌សង្គមជាប្រពៃណី ដូចជា ស្មារតីរួបរួមគ្រួសារ និងគោរពសាសនា ត្រូវបានបំផ្លិចបំផ្លាញជាប្រព័ន្ធ (Pellini 2005: 9)។ សង្គមកម្ពុជានាពេលបច្ចុប្បន្នមានលក្ខណៈជាការបូកផ្សំនូវបុគ្គលជាច្រើនដែលយល់ថា "គ្មាននរណាម្នាក់អាចទុកចិត្តបានទាំងស្រុងនោះទេ។ ការយកចិត្តទុកដាក់ថែទាំដល់ខ្លួនឯង សំខាន់ខ្លាំងណាស់សម្រាប់ការរស់រានជីវិត" (UNICEF 1996: 41)។ កត្តាមួយដែលបង្កកង្វះធ្ងន់ធ្ងរនូវទំនុកចិត្តក្នុងសង្គម គឺ "ការរាំងស្ទះ និងការបំផ្លិចបំផ្លាញដល់ដំណើរការសហគមន៍តាមលំនាំចាស់ ដែលពឹងផ្អែកជាចម្បងលើបណ្តាញសាច់ញាតិ" ( Pearson 2011: 38)។

លទ្ធផលអង្កេតបានបញ្ជាក់គាំទ្រដល់ការកត់សំគាល់ខាងលើ ដែលថា ប្រជាជនទាំងនៅតំបន់ជនបទ និងទីក្រុង មានទំនុកចិត្តកម្រិតទាបលើអ្នកដទៃ ដែលភាគច្រើនស្តែងចេញជាជំហរស៊ូត្រ ចិត្តកម្រិតទាប។ ក្នុងភូមិសិក្សានៅជនបទ ប្រជាជនបានបង្ហាញពីទំនុកចិត្តកម្រិតខ្ពស់តែចំពោះសមាជិកគ្រួសារ សាច់ញាតិ មិត្តភក្តិ និងអ្នកជិតខាងរបស់ខ្លួន។ ក្នុងភូមិនៅទីក្រុង មូលធនសង្គមជាភាពផ្សារភ្ជាប់ បានរួមចុះកាន់តែខ្លាំងថែមទៀត ដោយទំនុកចិត្តកម្រិតខ្ពស់ក្នុងសង្គម ឃើញមានបង្ហាញតែក្នុងរង្វង់សមាជិកគ្រួសារ និងសាច់ញាតិប៉ុណ្ណោះ។ រឿងនេះអាចមកពីសកម្មភាពសេដ្ឋកិច្ចមានសន្ទុះខ្លាំងនៅតំបន់ទីក្រុង។ អ្នកស្រាវជ្រាវខ្លះបានជជែកវែកញែកថា ការជ្រៀតចូលរបស់មូលធននិយមមកក្នុងប្រទេសកម្ពុជា ដោយសារការធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ចនៅដើមទសវត្សរ៍១៩៩០ បាននាំឲ្យមានការថយចុះទំនុកចិត្ត សាមគ្គីភាពក្នុងសង្គម និងការជួយគ្នាទៅវិញទៅមក (UNICEF 1996; Krishnamurthy 1999; Hughes 2001; Ovesen *et al.* 1996)។

ទំនុកចិត្តក្នុងសង្គមកម្រិតទាបនៅកម្ពុជា អាចជាប់ទាក់ទងនឹង "កត្តាខាងអារម្មណ៍ ការយល់ដឹង និងប្រវត្តិសាស្ត្រ" ច្រើនបែបយ៉ាង (Pearson 2011: 37)។ Meas Nee (cited in Pearson 2011: 38) បានសង្ខេបគំនិតនេះយ៉ាងប្រសើរ ដោយកត់សំគាល់ថា "កេរ្តិ៍តំណែលពីអតីតកាល កម្រិតអំពើហិង្សានិងភាពនិទោសពេលបច្ចុប្បន្ន របៀបដឹកនាំផ្តាច់ការ និងការមិនទុកចិត្តគ្នាដ៏ជ្រាលជ្រៅ និងឥតស្រាកស្រាន្ត រវាងគណបក្សនយោបាយផ្សេងៗនៅកម្ពុជា នឹងអ្នកដឹកនាំនានា មិនបានជួយអ្វីដល់ប្រជាជនទូទៅ ក្នុងការបំបាត់កង្វះទំនុកចិត្តរបស់ខ្លួន ចំពោះអ្នកដឹកនាំ ឬចំពោះប្រជាជនផងគ្នានោះទេ"។ ដូច្នេះលក្ខណៈមានឋានានុក្រមនៃសង្គម ដែលមានការតភ្ជាប់ទំនាក់ទំនងតាមខ្សែបញ្ឈរធូររលុង និងមូលធនសង្គមជាភាពផ្សារភ្ជាប់ដ៏តូចចង្អៀតបានត្រឹមតែបណ្តាញដ៏ជិតស្និទ្ធបំផុតនោះ គឺត្រូវតែយកមកគិតគូរនៅពេលផ្តួចផ្តើមធ្វើការអភិវឌ្ឍប្រកបដោយសមធម៌ និងលក្ខណៈប្រជាធិបតេយ្យ (Pellini 2005)។

### *ការថែទាំ និងកែលំអជីវភាព*

សង្គមមួយដែលមានមូលធនសង្គមកម្រិតខ្ពស់ តែងមានប្រព័ន្ធទ្រទ្រង់យ៉ាងរឹងមាំ នោះគឺការទ្រទ្រង់ដែលប្រជាជនទទួលបាននៅពេលប្រឈមមុខនឹងការលំបាក។ លទ្ធផលអង្កេតបង្ហាញថា ប្រព័ន្ធទ្រទ្រង់សង្គមនៅកម្ពុជាភាគច្រើន មានលក្ខណៈ

ក្រៅផ្លូវការ។ នៅពេលត្រូវប្រឈមនឹងបញ្ហាប្រចាំថ្ងៃ ប្រជាជនតែងងាកទៅរកបណ្តាញផ្សារភ្ជាប់របស់ខ្លួនដើម្បីទទួលបានជំនួយទ្រទ្រង់ ជាពិសេសសមាជិកគ្រួសារ និងសាច់ញាតិ ក៏ដូចជាអ្នកចងការប្រាក់ក្រៅផ្លូវការនៅមូលដ្ឋាន និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ដែលកាន់តែមានតួនាទីសំខាន់ឡើង។ នៅតាមតំបន់ជនបទ អ្នកចងការប្រាក់ ហាក់ដូចជាសកម្មជាងក្នុងការផ្តល់ប្រាក់កម្ចីនៅពេលប្រជាជនជួបការលំបាកក្នុងជីវភាពប្រចាំថ្ងៃ។ ដោយសារតាមធម្មតា អ្នកចងការប្រាក់ក្រៅផ្លូវការតែងយកការប្រាក់ខ្ពស់ណាស់ ដូច្នេះប្រព័ន្ធទ្រទ្រង់នេះ បានក្លាយជាបន្ទុកមួយសម្រាប់ប្រជាជនមូលដ្ឋាន ហើយមិនមានប្រព័ន្ធទ្រទ្រង់សង្គមជាផ្លូវការសម្រាប់ជួយទេនៅពេលពួកគាត់ជួបការលំបាក។

ដោយសារកង្វះស្ថាប័នទ្រទ្រង់សង្គម និងដោយយល់ឃើញថាបណ្តាញជិតស្និទ្ធរបស់គាត់ក៏ជួបការលំបាកដូចគ្នា ប្រជាជនភាគច្រើនទាំងនៅតំបន់ជនបទ និងទីក្រុងជឿថា គាត់ត្រូវតែពឹងផ្អែកលើខ្លួនឯងក្នុងការដោះស្រាយជីវភាពរស់នៅ។

ព័ត៌មានដើរតួនាទីសំខាន់បំផុតសម្រាប់ឲ្យ ប្រជាជនទទួលបានឱកាសល្អដែលអាចជួយលើកកម្ពស់ជីវភាពរស់នៅ។ ប៉ុន្តែនៅកម្ពុជា ការផ្លាស់ប្តូរព័ត៌មាន ជាពិសេសនៅតំបន់ជនបទច្រើនតែ "កើតមានក្នុងបណ្តាញសង្គមដែលភាគច្រើនកើតមានឡើងដោយខ្លួនឯង មានលក្ខណៈក្រៅផ្លូវការ និងមិនទៀងទាត់" (Krishnamurthy 1999: 3)។ ភស្តុតាងបានមកពីអង្កេតទាំងនៅតំបន់ជនបទ និងទីក្រុង បានបង្ហាញថា ប្រភពព័ត៌មានចម្បងរបស់ប្រជាជន គឺមាន សមាជិកគ្រួសារ សាច់ញាតិ មិត្តភក្តិ និងអ្នកជិតខាង។ ទោះបីអាជ្ញាធរមូលដ្ឋាន និងប្រព័ន្ធផ្សព្វផ្សាយហាក់មានតួនាទីកាន់តែច្រើនឡើងក្តី ក៏ពួកគេហាក់ដូចធ្វើការផ្សព្វផ្សាយតែព័ត៌មានប្រភេទខ្លះៗប៉ុណ្ណោះ។

## *ហានិភ័យ និងសុវត្ថិភាពសង្គម*

លក្ខណៈសំគាល់មួយនៃសង្គមកម្ពុជា គឺបែបបទជាក្រឹត្យក្រមរឹងប៉ឹងដែលសាច់ញាតិត្រូវជួយគ្នាទៅវិញទៅមក នៅពេលជួបការលំបាក ហើយ "ក្រឹត្យក្រមនេះជួយបង្កើនទំនុកចិត្ត និងភាពអាចពឹងផ្អែកលើគ្នាបានក្នុងរង្វង់សាច់ញាតិ" (Krishnamurthy 1999: 61)។ សមាជិកគ្រួសារ និងសាច់ញាតិ ដើរតួនាទីជាបណ្តាញសុវត្ថិភាពក្រៅផ្លូវការដ៏រឹងមាំ ដូចអាចមើលឃើញក្នុងលទ្ធផលអង្កេតដែល ប្រជាជនភាគច្រើននៅតែចាត់ទុកគ្រួសារ និងសាច់ញាតិជាប្រព័ន្ធទ្រទ្រង់ក្រៅផ្លូវការដ៏សំខាន់ ទោះបីគំនិតនេះហាក់ដូចកំពុងផ្លាស់ប្តូរក្តី។ អ្នកឆ្លើយសម្ភាសន៍ជាច្រើននាក់នៅតំបន់ជនបទលើកឡើងថា គាត់អាចពឹងផ្អែកលើសមាជិកគ្រួសារ សាច់ញាតិ មិត្តភក្តិ និងអ្នកជិតខាងបាន នៅពេលជួបការលំបាក ឬហានិភ័យ។ នៅតំបន់ទីក្រុង បណ្តាញសុវត្ថិភាពសង្គមក្រៅផ្លូវការនៅតែរឹងមាំខ្លាំង ទោះបីវាហាក់ដូចបានរួមចុះមកត្រឹមសមាជិកគ្រួសារ និងសាច់ញាតិក្តី។

នៅកម្ពុជា បណ្តាញក្រៅផ្លូវការដើរតួនាទីយ៉ាងសំខាន់ក្នុងការបំពេញចន្លោះខ្វះខាតដែលបណ្តាស្ថានប័ន និងទីភ្នាក់ងារផ្លូវការនានា មិនបានគ្របដណ្តប់ ជាពិសេសនៅតំបន់ជនបទ (Krishnamurthy 1999)។ "បណ្តាញក្រៅផ្លូវការបានរីកលូតលាស់ដោយសារទំនុកចិត្ត និងភាពអាចពឹងផ្អែកលើគ្នាបាន ដែលតែងកើតមានជាធម្មតាក្នុងចំណោមសាច់ញាតិ អ្នកជិតខាង និងមិត្តភក្តិ។ ទំនុកចិត្ត និងភាពអាចពឹងផ្អែកលើគ្នាបាននេះ បានផ្តល់បណ្តាញសុវត្ថិភាពដ៏សំខាន់បំផុតមួយដល់អ្នកភូមិ នៅពេលមានបញ្ហាកើតឡើង" (ibid: 63)។ នៅកម្ពុជា បណ្តាញក្រៅផ្លូវការដើរតួនាទីជាប្រព័ន្ធទ្រទ្រង់សង្គមដ៏រឹងមាំ ដោយសារពុំមានប្រព័ន្ធទ្រទ្រង់សង្គមផ្លូវការអ្វីច្បាស់លាស់។ បណ្តាញក្រៅផ្លូវការទាំងនេះផ្តល់ឲ្យបុគ្គលនានានូវ យន្តការជួយទ្រទ្រង់ដ៏មានតម្លៃនៅក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គមរបស់ពួកគេ (ibid)។

នៅប្រទេសកម្ពុជា ក្រោយពេលបញ្ចប់សង្គ្រាម បណ្តាញក្រៅផ្លូវការ និងបែបបទជួយគ្នាទៅវិញទៅមក ទំនងទទួលរងឥទ្ធិពលពីកម្លាំងទីផ្សារ និងហាក់បានផ្លាស់ប្តូរទៅកាន់ពលកម្មយកប្រាក់កម្រៃ និងទម្រង់នៃការដោះដូរផ្អែកលើទីផ្សារ (Kim 2001; Fitzgerald *et al.* 2007)។ កម្លាំងទីផ្សារ និងសេដ្ឋកិច្ចប្រើប្រាក់កាស បានធ្វើឲ្យបណ្តាញសុវត្ថិភាពក្រៅផ្លូវការផ្អែកលើការជួយគ្នាទៅវិញទៅមកត្រូវចុះខ្សោយជាបណ្តើរៗ ហើយជំរុញឲ្យប្រជាជនដាក់តម្រូវការ និងបញ្ហាផ្ទាល់ខ្លួនជារឿងសំខាន់ទី១ នៅក្នុងបរិយាកាសមានការប្រកួតប្រជែងខ្លាំងនេះ (Krishnamurthy 1999)។ នៅកម្ពុជាសម័យនេះ ប្រជាជនបានក្លាយជា "អាត្មានិយម លោភលន់ និងត្រៀមជួយតែចំពោះគ្រួសារនៅជិតខ្លួនគាត់ប៉ុណ្ណោះ។ ពួកគាត់មិនសូវមានឆន្ទៈចូលរួមក្នុង សកម្មភាពរួមដែលធ្វើឡើងសម្រាប់ជាប្រយោជន៍ដល់សហគមន៍ទាំងមូលនោះទេ" (UNICEF 1996: 41)។ នេះជានិន្នាការគួរឲ្យបារម្ភ ក្នុងស្ថានភាពបច្ចុប្បន្ននៅប្រទេសកម្ពុជា ដែលពុំទាន់មានប្រព័ន្ធទ្រទ្រង់សង្គមផ្លូវការ ហើយយុទ្ធសាស្ត្រការការពារសង្គមជាផ្លូវការ ក៏ទើបចាប់ផ្តើមកសាងឡើង។

## *ទម្លាប់/ពិធីក្នុងសង្គម*

ក្រៅពីគ្រួសារដែលជាឯកតាសង្គមជាមូលដ្ឋាន និងដែលដើរតួនាទីជាប្រព័ន្ធទ្រទ្រង់សង្គមក្រៅផ្លូវការជាមូលដ្ឋាន នៅកម្ពុជា បុណ្យទានរបស់សហគមន៍និងសម្រាប់ទូទាំងភូមិ ក៏ផ្តល់ជាវេទិកាមួយសម្រាប់ឲ្យប្រជាជនក្នុងសហគមន៍ ធ្វើអន្តរកម្មចុះឡើង ព្រមទាំងកសាងនិងពង្រឹងបណ្តាញរបស់ពួកគាត់។ Krishnamurthy (1993: 3) បានសង្ខេបថា "បុណ្យទានក្នុងសហគមន៍អាចបង្កើនស្មារតីសាមគ្គីភាព និងដើរតួជាស៊ីម៉ងត៍ផ្សារភ្ជាប់ប្រជាជនជាមួយគ្នា។ ព្រឹត្តិការណ៍ទាំងនោះបង្កើតបានជាសំណាញ់នៃស្មារតីសមូហភាព ឆ្លងតាមបទពិសោធន៍រួមគ្នា។ ព្រឹត្តិការណ៍ក្នុងសហគមន៍ អាចជួយដាស់ស្មារតីប្រជាពលរដ្ឋល្អ និងលើកកម្ពស់ជំហរគិតគូរដល់សុខទុក្ខរបស់អ្នកដទៃ"។

លទ្ធផលអង្កេតបានបង្ហាញថា ការចូលរួមនៅក្នុងព្រឹត្តិការណ៍សហគមន៍នៅមានសន្ទុះខ្លាំង ជាពិសេសនៅតាមតំបន់ជនបទ ហើយគេក៏អាចពិនិត្យឃើញតាមរយៈសមាសភាពអ្នកចូលរួមនៅក្នុងពិធីផ្សេងៗដូចជា មង្គលការ និងបុណ្យសព ជាដើម។ សមាជិកគ្រួសារ សាច់ញាតិ មិត្តភក្តិ និងអ្នកជិតខាង គឺជាអ្នកចូលរួមនៅក្នុងពិធីប្រពៃណីទាំងនោះ ទាំងនៅតាមតំបន់ជនបទ និងនៅតាមទីក្រុង។ ប៉ុន្តែ ទោះបីជាព្រឹត្តិការណ៍ប្រភេទនេះរួមចំណែកលើក

កម្ពស់សាមគ្គីភាពក្នុងសហគមន៍ក្ដី ក៏ការចូលរួមក្នុងពិធីទាំងនេះ អាចមានលក្ខណៈទៅវិញទៅមក គឺមិនមែនសុទ្ធតែបង្ហាញពីទំនាក់ទំនងក្នុងសង្គមនោះទេ។

នៅតាមភូមិនានានៅតំបន់ជនបទ ការចូលរួមក្នុងពិធីប្រពៃណីផ្សេងៗនៅមានច្រើនណាស់។ ពិធីប្រពៃណីរបស់សហគមន៍មានសារៈសំខាន់ក្នុងការ "លើកកម្ពស់អត្តសញ្ញាណរបស់សហគមន៍ និងសាមគ្គីភាព" (Krishnamurthy 1999: 63)។ ផ្ទុយទៅវិញ ព្រឹត្តិការណ៍នៅក្នុងសហគមន៍បែបនេះ ហាក់ដូចជាពុំឃើញមានទេក្នុងភូមិនៅតាមទីក្រុង ហើយនេះបានប៉ះពាល់ដល់សាមគ្គីភាព និងស្មារតីសហគមន៍ដែលត្រូវរងឥទ្ធិពលថែមទៀត ពីសន្ទុះនៃកម្លាំងទីផ្សារ និងការប្រកួតប្រជែងនៅតំបន់ទីក្រុង។

នាបច្ចុប្បន្ន ទាំងតាមមតិរបស់របស់ស្ត្រីខ្លួនឯង និងរបស់បុរស គឺហាក់ដូចមានការផ្លាស់ប្ដូរតួនាទីរបស់ស្ត្រី ជាពិសេសនៅតំបន់ទីក្រុង។ សង្គមកម្ពុជា បានក្លាយជារចនាសម្ព័ន្ធមួយដែលលើកបុរសជាធំ ហើយលក្ខណៈនេះអាចមើលឃើញច្បាស់តាមការគួបផ្សំគ្នាជាធម្មតា រវាងការងាររបស់បុរស និងការងាររបស់ស្ត្រី ដោយបុរសជាប្រពៃណី តែងមានតួនាទីចម្បងគេនៅក្នុងគ្រួសារ និងទទួលបន្ទុកលើការងារធ្ងន់ៗ ឬការងារមានគ្រោះថ្នាក់ច្រើន ហើយស្ត្រីជាទូទៅទទួលបន្ទុកលើការងារនៅក្នុងផ្ទះ។ ភស្តុតាងបានពីអង្កេតនៅតាមតំបន់ជនបទ ហាក់ដូចជាបានបញ្ជាក់គាំទ្រដល់ចំណុចនេះ ទោះបីជាប្រជាជនមួយចំនួន ជាពិសេសស្ត្រី បានផ្លាស់ប្ដូរគំនិតខ្លះហើយ ដោយបានគិតថា ស្ត្រីគួរទទួលបន្ទុកលើការងារដែលជាការងាររ៉ាប់រងដោយបុរស និងគួរបង្កើនការចូលរួមក្នុងក្រុមសកម្មភាពសហគមន៍មូលដ្ឋាន។ ការផ្លាស់ប្ដូរកាន់តែឃើញមានច្បាស់ឡើងថែមទៀតនៅតាមតំបន់ទីក្រុង។ បុរស និងស្ត្រីក្នុងចំនួនស្ទើរស្មើគ្នាយល់ឃើញថា ស្ត្រីគួរបំពេញការងារដូចគ្នានឹងបុរសដែរ ដូចជា ការគ្រប់គ្រងអាជីវកម្មរបស់ខ្លួនផ្ទាល់ និងការចូលរួមនៅក្នុងសកម្មភាពសេវាកម្ម។ គំនិតនេះអាចបណ្ដាលមកពីនៅតាមតំបន់ទីក្រុង តែងមានសកម្មភាពសេដ្ឋកិច្ចមមាញឹក និងឱកាសច្រើន។

សាសនាដើរតួនាទីសំខាន់បំផុត ក្នុងការកំណត់បែបបទក្រឹត្យក្រមនៃការជួយគ្នាទៅវិញទៅមកក្នុងសង្គម។ ក្នុងសង្គមកម្ពុជាក៏ដូច្នោះដែរ ដោយព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ បានទូន្មានឲ្យលើកកម្ពស់ ការចូលរួមក្នុងសកម្មភាពសហគមន៍ (Kim 2001; Pellini 2005)។ អ្នកឆ្លើយសម្ភាសន៍ក្នុងអង្កេតទាំងអស់ ទាំងនៅតំបន់ជនបទ និងទីក្រុង សុទ្ធតែជាអ្នកកាន់ពុទ្ធសាសនា។ ព្រះវិហារពុទ្ធសាសនា (ឬវត្ត) គឺជា មជ្ឈមណ្ឌលនៃជីវិតសហគមន៍នៅប្រទេសកម្ពុជា។ ទោះយ៉ាងណាក្ដី សព្វថ្ងៃនេះសាសនាមិនដើរតួនាទីសំខាន់ក្នុងជីវភាពប្រចាំថ្ងៃ ដូចកាលពីមុនទេ។ ទាំងនៅតំបន់ជនបទ និងទីក្រុង មានប្រជាជនតិចនាក់ណាស់ដែលចាត់ទុកវត្ត ជាកន្លែងដែលពួកគាត់អាចពឹងអាស្រ័យ និងទទួលបានការទ្រទ្រង់ នៅពេលគាត់ជួបនឹងការលំបាក។ រឿងនេះអាចជាប់ទាក់ទងនឹងការចោទប្រកាន់នាពេលថ្មីៗដែលថា វត្តមិនមែនជាកន្លែងអព្យាក្រិតទេ ហើយអ្នកដឹកនាំសាសនាមានជាប់ខ្សែរយៈជាមួយ គណបក្សនយោបាយ (Heng 2008; Thon *et al.* 2009)។ សម្រាប់ប្រជាជនជាច្រើន បញ្ហានេះ បានបំផ្លាញតួនាទីមូលដ្ឋានរបស់សាសនានៅក្នុងជីវិតរស់នៅរបស់ពួកគាត់ ហើយពុទ្ធសាសនាលែងមានន័យអ្វីច្រើនសម្រាប់ពួកគាត់ទៀតហើយ។

## សន្និដ្ឋាន

លទ្ធផលអង្កេតបានផ្ដល់ការយល់ដឹងយ៉ាងល្អ អំពីលក្ខណៈនៃមូលធនសង្គម ជាភាពផ្សារភ្ជាប់ ស្ពានចម្លង និងភាពតភ្ជាប់ចុះឡើង នៅតាមតំបន់ជនបទ និងទីក្រុង នៅក្នុងប្រទេសកម្ពុជា។ មូលធនសង្គមជាភាពផ្សារភ្ជាប់នៅរឹងមាំនៅឡើយ ទោះបីជានៅតាមតំបន់ទីក្រុង វាហាក់ដូចជាបានរួមចុះបន្តិចក្ដី។ បែបបទក្រឹត្យក្រមជាប្រពៃណីដែលលើកស្ទួយដល់គ្រួសារជា ស្ថាប័នសង្គមដ៏ចម្បង សម្រាប់ដោះស្រាយតម្រូវការគ្រប់ប្រភេទរបស់សមាជិក វានៅគង់វង្សល្អ និងមានអនុវត្តយ៉ាងទូលំទូលាយទាំងនៅតំបន់ជនបទ និងនៅទីក្រុង។ សាច់ញាតិជិតៗ (ហើយនៅតាមតំបន់ជនបទ មានមិត្តភក្ដិ និងអ្នកជិតខាង ផងដែរ) បង្កើតបានជាប្រព័ន្ធទ្រទ្រង់សង្គមក្រៅផ្លូវការយ៉ាងសំខាន់ ហើយពួកគាត់គឺជាអ្នកដែលអាចគេធ្វើសេចក្ដីទុកចិត្តបាន។

មូលធនសង្គមជាស្ពានចម្លង ហាក់ដូចនៅរឹងមាំនៅឡើយក្នុងសហគមន៍នៅជនបទ ដែលនៅទីនោះ ប្រជាជនក្នុងមូលដ្ឋានតែងរៀបចំ និងទៅចូលរួមក្នុងពិធីជាប្រពៃណីផ្សេងៗ។ ប៉ុន្តែមូលធនសង្គមប្រភេទនេះហាក់ដូចបានរួមចុះនៅតំបន់ទីក្រុង ដោយសារពុំមានពិធីជាប្រពៃណីសម្រាប់ទូទាំងសហគមន៍ ថ្វីបើការចូលរួមក្នុងពិធីជាប្រពៃណីដូចជា មង្គលការ ឬបុណ្យសពជាដើម នៅតែមានកម្រិតខ្ពស់ក្ដី។ ការផ្លាស់ប្ដូរអាកប្បកិរិយារបស់ប្រជាជនចំពោះវត្តអារាមដែលជាមជ្ឈមណ្ឌលនៃជីវិតក្នុងសហគមន៍ ក៏បានប៉ះពាល់ដល់ចរិត និងកម្រិតនៃមូលធនសង្គមជាស្ពានចម្លងដែរ ជាពិសេសនៅតំបន់ទីក្រុង។

"សង្គមកម្ពុជាបច្ចុប្បន្ន អាចសំគាល់បានតាមការតភ្ជាប់ទំនាក់ទំនងតាមខ្សែបញ្ឈរធូររលុង រវាងក្រុមខុសៗគ្នា និងការតភ្ជាប់ទំនាក់ទំនងយ៉ាងរឹងមាំ រវាងសមាជិកនានាក្នុងស្រទាប់សង្គមតែមួយ" (Pellini 2005: 8)។ ហើយលទ្ធផលអង្កេតបានបញ្ជាក់គាំទ្រជាខ្លាំងលើចំណុចនេះ។ ទាំងនៅតំបន់ជនបទ និងទីក្រុង ប្រជាជនបានបង្ហាញទំនុកចិត្តកម្រិតទាបចំពោះស្ថាប័នរដ្ឋ និងអ្នកកាន់កាប់អំណាចរដ្ឋ ដូចជា ក្រុមប្រឹក្សាឃុំសង្កាត់ជាដើម។ ម្យ៉ាងទៀត តាមសំដីរបស់អ្នកឆ្លើយសម្ភាសន៍ក្នុងអង្កេតជាពិសេសតំបន់ទីក្រុង គឺមានការមិនទុកចិត្តកម្រិតខ្ពស់ចំពោះគណបក្សនយោបាយ និងអ្នកនយោបាយនានា។

ជាទូទៅ មូលធនសង្គមជាភាពតភ្ជាប់ទំនាក់ទំនងចុះឡើង ទាំងនៅសហគមន៍តំបន់ជនបទនិងទីក្រុងវាមានកម្រិតទាបជាពិសេសនៅតំបន់ជនបទ ដែលតាំងពីដើមរៀងមក តែងនៅដាច់ឆ្ងាយពីអាជ្ញាធរថ្នាក់មជ្ឈឹមដែលនៅឯទីក្រុង (Pellini 2005) ហើយ "ប្រជាជននៅតំបន់ជនបទ ស្ទើរតែគ្មានការតភ្ជាប់ទំនាក់ទំនងអ្វីសោះជាមួយស្ថាប័នរដ្ឋ" (Grahn 2006: 31)។ នៅកម្ពុជា មូលធនសង្គមជាភាពតភ្ជាប់ដែលមានកម្រិតទាប ក៏អាចបណ្ដាលពីរចនាសម្ព័ន្ធមានឋានានុក្រមដែលបានចាក់ឫសយ៉ាងជ្រៅ នៅក្នុងគ្រប់ទម្រង់នៃអន្តរកម្ម និងទំនាក់ទំនង នៅក្នុងវប្បធម៌កម្ពុជា។

ហើយរបៀបរបបដឹកនាំ និងវប្បធម៌អំពើហិង្សា និងនិរទោស នៅកម្ពុជានាបច្ចុប្បន្ន បានធ្វើឲ្យប្រជាជនកាន់តែឃ្លាតឆ្ងាយពីរដ្ឋថែមទៀត ( Meas cited in Pearson 2011 )។

## ឯកសារយោង


Bouka, Y. (2008), *Is social capital the key to peacebuilding?* Paper presented at the Annual meeting of the International Studies Association's 49th Annual Convention, Bridging Multiple Divides. Hilton San Francisco, California, www.allacademic.com/meta/p252132_index.html (accessed 31 October 2008)

Coleman, J.S. (1988), "Social capital in the creation of human capital", *American Journal of Sociology,* 94, 95-120

de Hart, J. & P. Dekker (2003), "A tale of two cities: Local patterns of social capital", in M.Hooghe & D. Stolle (eds.), *Generating Social Capital: Civil Society and Institutions in Comparative Perspective* (New York: Palgrave) 153-170

Ebihara, M.M. (1968), *Svay, a Khmer Village in Cambodia*, unpublished PhD dissertation, Faculty of Philosophy, Columbia University

Fitzgerald, I., So S., Chan S., Kem S. & S. Tout (2007), *Moving Out of Poverty? Trends in Community Well-being and Household Mobility in Nine Cambodian Village,* CDRI Working Paper (Phnom Penh: CDRI)

Grahn, H. (2006), *In the search of trust: A study on the origin of social capital in Cambodia from an institutional perspective*, Department of Political Science, LUND University

Heng, S. (2008), "The Scope and Limitations of Political Participation by Buddhist Monks", in A. Kent & D. Chandler (eds.), *People of Virtue: Reconfiguring Religion, Power and Moral Order in Cambodia Today* (Copenhagen: Nordic Institute of Asian Studies) 241-256

Hooghe, M. (2003), "Voluntary associations and democratic attitudes: Value congruence as a causal mechanism", in M. Hooghe & D. Stolle (eds.), *Generating Social Capital: Civil Society and Institutions in Comparative Perspective* (New York: Palgrave) 89-112

Hughes, C. (2001), *An Investigation of Conflict Management in Cambodian Villages: A Review of the Literature with Suggestions for Future Research* (Phnom Penh: Centre for Peace and Development, CDRI)

Kim S. (2001). *Reciprocity: Informal Patterns of Social Interactions in a Cambodian Village near Angkor Park*, MA thesis, Northern Illinois University, Dekalb, Illinois

Krishnamurthy, V. (1999), *The impact of armed conflict on social capital: A study of two villages in Cambodia* (Phnom Penh: Social Services of Cambodia)

Ledgerwood, J. & J. Vijghen. (2002), "Decision Making in Rural Khmer Villages", in J. Ledgerwood (ed.), *Cambodia Emerges from the Past: Eight Essays* (Dekalb, Illinois: Northern Illinois University)

Lowndes, V. & D. Wilson (2001), "Social Capital and Local Governance: Exploring the Institutional Design Variable", *Political Studies,* 49, 629-647

Maloney, W., G. Smith & G. Stoker (2000), "Social Capital and Urban Governance: Adding a More Contextualized 'Top-down' Perspective", *Political Studies,* 48, 802-820

Newton, K. (2001), "Trust, social capital, civil society, and democracy", *International Political Science Review,* 22(2), 201-214

O'Leary, M. & N. Meas (2001), *Learning for transformation: A study of the relationship between culture, values, experience and development practice in Cambodia* (Phnom Penh: Krom Akphiwat Phum)

Ovesen, J., I. Trankell & J. Ojendal (1996), *When Every Household is an Island: Social Organization and Power Structures in Rural Cambodia* (Stockholm: Department of Anthropology, Uppsala University)

Pearson, J. (2005), *The multi-cultural iceberg: Exploring international relationships in Cambodian development organizations*, INTRAC PraxiNote 8

Pearson, J. (2011), *Creative Capacity Development: Learning to Adapt in Development Practice.* (Sterling, VA: Kumarian Press)

Pellini, A. (2005), "Traditional Forms of Social Capital in Cambodia and their Linkage with Local Development Processes" *Cambodia Development Review,* 9(3), 8-11

Pellini, A. & D. Ayres (2005), *Social capital and village governance: Experiences with village networks*, GTZ (German Technical Cooperation Agency) discussion paper, www.worldbank.org (accessed 10 November 2008)

Putnam, R. (1993), *Making Democracy Work: Civic Traditions in Modern Italy* (Princeton, NJ: Princeton University Press)

Sen, V. (2010), *Trust and Conflict Transformation: An Analysis of the Baku Bae Peace Movement in Indonesia* (Saarbrücken, Germany: LAP LAMBERT Academic Publishing)

Shopeju, J. O. & C.C. Ojukwu (2008), *Exploring social capital as capacity for peace-building in Nigeria*, paper presented at the 1st Annual Conference of the Society for Peace Studies and Practice, www.spspng.org/papers.php (31 October 2008)

Thon V., Ou S., Eng N. & Ly T. (2009), *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces,* CDRI Working Paper Series No. 42 (Phnom Penh: CDRI)

UNICEF (1996), *Towards a better future: An analysis of the situation of children and women in Cambodia* (Phnom Penh: UNICEF)

Wallis, J. (2002), "Social capital and local government capacity" *Australian Journal of Public Administration,* 61(3), 76-85

Wollebæk, D. & P. Selle (2003), "The importance of passive membership for social capital formation", in M. Hooghe & D. Stolle (eds.), *Generating Social Capital: Civil Society and Institutions in Comparative Perspective* (New York: Palgrave) 67-88

# អភិបាលកិច្ចទីប្រជុំជនក្នុងបរិបទវិមជ្ឈការនៅកម្ពុជា៖ ប្រធានបទមិនសូវមានគេស្រាវជ្រាវ?[១]

## សេចក្ដីផ្ដើម

អត្ថបទនេះព្យាយាមពន្យល់ថា អភិបាលកិច្ចទីប្រជុំជននៅក្នុងកំណែទម្រង់វិមជ្ឈការនៅកម្ពុជា គួរមានការសិក្សាស៊ីជម្រៅថែមទៀត។ មានការកែប្រែផ្នែកឥរិយាបថ និងផ្នែកស្ថាប័នជាច្រើនបានកើតឡើង បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី១ កាលពីមួយទសវត្សរ៍កន្លងទៅ។ ការសិក្សាលើឯកសារមានស្រាប់បង្ហាញថា ទោះជាកំណែទម្រង់វិមជ្ឈការបែបប្រជាធិបតេយ្យនៅកម្ពុជា ទទួលបានការយកចិត្តទុកដាក់ច្រើនក្ដី ក៏ការស្រាវជ្រាវភាគច្រើនពីប្រធានបទនេះ មិនបានគិតគូរដល់ស្ថានភាពជាក់ស្ដែងនៅតំបន់ទីប្រជុំជនទេ។ បទសម្ភាសន៍មួយចំនួនជាមួយអ្នកធ្វើគោលនយោបាយ និងសមាជិកក្រុមប្រឹក្សា ឃុំសង្កាត់ ដែលជាផ្នែកមួយនៃការស្រាវជ្រាវបឋមអំពីអភិបាលកិច្ចទីប្រជុំជន បានបង្ហាញពីសារៈសំខាន់នៃការពិនិត្យអង្កេតទៅតាមប្រភេទទីតាំងភូមិសាស្ត្រផ្សេងៗនៅកម្ពុជា ជាពិសេស តំបន់ជនបទ ធៀបនឹងទីប្រជុំជន ដើម្បីបង្កើនប្រសិទ្ធភាពគោលនយោបាយឲ្យបានជាអតិបរមា នៅតាមទីតាំងខុសៗគ្នាក្នុងដែនសមត្ថកិច្ចរបស់រដ្ឋអំណាចមូលដ្ឋាន។ អត្ថបទនេះចាប់ផ្ដើមឡើងដោយការកំណត់និយមន័យ "ទីប្រជុំជន" និង "អភិបាលកិច្ចទីប្រជុំជន" រួចធ្វើការត្រួតពិនិត្យឡើងវិញត្រួសៗពីវិមជ្ឈការនៅកម្ពុជា។ ផ្នែកទី៣ បង្ហាញពីមូលហេតុ និងសំណួរនៃការស្រាវជ្រាវ ព្រមទាំងក្របខ័ណ្ឌស្រាវជ្រាវសម្រាប់ប្រើជាផែនទីបង្ហាញផ្លូវចំពោះការស្រាវជ្រាវនេះ។ ផ្នែកបន្ទាប់មកទៀតបង្ហាញពីចំណេះដឹងទទួលបានពីការចុះសិក្សាដល់កន្លែងជាដំបូងៗ ហើយនៅចុងបញ្ចប់មានសេចក្ដីសន្និដ្ឋានអំពីតម្រូវការគោលនយោបាយដែលយកចិត្តទុកដាក់ពីបញ្ហាទីតាំង ដើម្បីដោះស្រាយបញ្ហាតែងតែជួបប្រទះនៅតំបន់ប្រជុំជន ។

## នៅក្នុងអភិបាលកិច្ចទីប្រជុំជន តើ "ទីប្រជុំជន" ជាអ្វី?

ដោយសារអត្ថបទនេះផ្ដោតលើតំបន់ទីប្រជុំជន ដូច្នេះគួរបញ្ជាក់ពីអត្ថន័យពាក្យ "ទីប្រជុំជន" នៅក្នុងបរិបទអភិបាលកិច្ចទីប្រជុំជន។ គេអាចកំណត់និយមន័យ ទីប្រជុំជន តាមរយៈលក្ខណៈវិនិច្ឆ័យផ្នែករដ្ឋបាល ដង់ស៊ីតេប្រជាជន មុខងារសេដ្ឋកិច្ច ឬហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជាដើម។ ទីប្រជុំជនជាច្រើននៅទ្វីបអាស៊ី រួមទាំងនៅកម្ពុជាផង ក៏ត្រូវបានឲ្យនិយមន័យដូច្នេះដែរ។ នៅកម្ពុជា និយមន័យមានស្រាប់មួយដែលក្រសួងផែនការបានយកមកប្រើ ក្នុងពេលធ្វើចំណាត់ថ្នាក់តំបន់ទីប្រជុំជនជាថ្មីនៅឆ្នាំ២០០៤ គឺបានកំណត់តំបន់ទីប្រជុំជន ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យបី គឺ៖ ១) មានដង់ស៊ីតេប្រជាជនលើសពី ២០០ នាក់/គម² ២) មានអត្រាបុរសធ្វើការក្នុងវិស័យកសិកម្ម តិចជាង ៥០% និង ៣) មានចំនួនប្រជាជន សរុបលើសពី ២០០០នាក់ (NIS 2004)[២]។ បញ្ហាចោទលើនិយមន័យនេះ គឺវាពុំមានការទទួលស្គាល់ ជាសកលពីគ្រប់ស្ថាប័នរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានាទេ។ ក្នុងអត្ថបទនេះ តំបន់ទីប្រជុំជនមិនមែនគ្រាន់តែសំគាល់ឡើងតាម លក្ខណៈហេដ្ឋារចនាសម្ព័ន្ធ ឬក៏ចំនួនប្រជាជននោះទេ ប៉ុន្តែថែមទាំងទៅតាមលក្ខណៈវិនិច្ឆ័យដែលមិនអាចមើលឃើញផ្សេងទៀត ពោលគឺ តាមវិធីសាស្ត្រផ្នែកនរវិទ្យាសម្រាប់បរិបទទីប្រជុំជន ដែលផ្ដោតសំខាន់ទៅលើដង់ស៊ីតេខ្ពស់នៃទំនាក់ទំនងសង្គម នៅក្នុងទីតាំងនីមួយៗ (Gutkind 1974)។ នៅក្នុងនរវិទ្យា ដង់ស៊ីតេប្រជាជនមិនមែនជាចំណុចសំខាន់ទេ ប៉ុន្តែគឺ ដង់ស៊ីតេទំនាក់ទំនងសង្គម។ ការលើកយកគំនិតយល់ដឹងពី ទំនាក់ទំនងសង្គម មកជជែកវែកញែកបែបនេះ បានផ្ដល់ពន្លឺថ្មីមួយដល់ការពិភាក្សាពីអភិបាលកិច្ច និងបំផុសសំណួរថាតើគេគួរកំណត់ឡើងវិញនូវនិយមន័យនៃពាក្យអភិបាលកិច្ចទីប្រជុំជន ឬយ៉ាងណា។

គេអាចឲ្យនិយមន័យអភិបាលកិច្ចយ៉ាងសាមញ្ញថាជា "ការប្រើប្រាស់សិទ្ធិអំណាចខាងសេដ្ឋកិច្ច នយោបាយ និង រដ្ឋបាលដើម្បីគ្រប់គ្រងកិច្ចការប្រទេសមួយនៅគ្រប់កម្រិត" (UNDP 2003:170)។ ដូច្នេះ តើអភិបាលកិច្ចទីប្រជុំជន សំដៅដល់ការគ្រប់គ្រងកិច្ចការទីប្រជុំជនមែនទេ? និយមន័យរបស់ UNESCO (ដកស្រង់ពី Kaufman *et al.* 2005: 7) បានចាត់ទុកអភិបាលកិច្ចទីប្រជុំជនជា "ដំណើរការតម្រង់ទិស និងគិតគូរពីទំនាក់ទំនងផ្សេងៗ រវាងអ្នកពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ។ វាមានបញ្ចូលនូវយុទ្ធសាស្ត្រពីក្រោមឡើងលើ និងពីលើចុះក្រោម ដើម្បីសម្រួលដល់ការចូលរួមរបស់សហគមន៍ពាក់ព័ន្ធ ទំនាក់ទំនងរវាងតួអង្គនានា ការធ្វើការសម្រេចចិត្តដោយមានតម្លាភាព និងការកែច្នៃបែបថ្មីនូវយុទ្ធសាស្ត្រគោលនយោបាយគ្រប់គ្រងទីប្រជុំជន"។ ចំណុចស្នូលនៃនិយមន័យនេះ គឺទំនាក់ទំនងរវាងតួអង្គផ្សេងៗ មានជាអាទិ៍ រដ្ឋាភិបាល ប្រជាពលរដ្ឋ អ្នកពាក់ព័ន្ធនានា ក៏ដូចជា វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល (NGOs)។ ការគិតគូរយ៉ាងទូលាយពីតួអង្គផ្សេងៗដែលជាប់ពាក់ព័ន្ធនឹងអភិបាលកិច្ច ក៏មានអ្នកស្រាវជ្រាវជាច្រើនទៀតយល់ស្របដែរ (Ojendal & Dellnas 2010)។ ដូចមានបង្ហាញខាងលើ ទំនាក់ទំនងទាំងនេះហាក់កើតមានញឹកញាប់នៅក្នុងបរិបទទីប្រជុំជន។ និយមន័យនេះជាក្របខ័ណ្ឌរួមមួយសម្រាប់ស្វែងយល់ពី អភិបាលកិច្ចទីក្រុងជាទូទៅ ប៉ុន្តែវាទូលំទូលាយបន្តិច ដោយសារមិនមានបញ្ជាក់ច្បាស់លាស់ពី កត្តាដែលជះឥទ្ធិពលទៅលើទំនាក់ទំនងប្រចាំថ្ងៃ រវាង

---

[១] អត្ថបទនេះរៀបរៀងឡើងដោយលោក ឈាត ស្រ៊ាង អាន សុវត្ថា ជាអ្នកស្រាវជ្រាវ និងលោក គឹម សេតារា ជាអ្នកស្រាវជ្រាវជាន់ខ្ពស់ នៃកម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់សាធារណៈនៃវិទ្យាស្ថាន CDRI។

[២] ឃុំ គឺជាឯកតាត្រូវយកមកគណនា ដើម្បីកំណត់ថា តើតំបន់នោះស័ក្តិសមជា "ទីប្រជុំជន" ឬ "ជនបទ"។ ធម្មតា សង្កាត់ សំដៅដល់ ឃុំរបស់ទីក្រុង ប៉ុន្តែបើប្រើប្រាស់និយមន័យឆ្នាំ២០០៤នោះ សង្កាត់នៅក្នុងក្រុងទាំង ២៦ នៅកម្ពុជាមិនសុទ្ធតែគ្រប់លក្ខណៈជាតំបន់ទីប្រជុំជនទាំងអស់ទេ។ សូមមើល http://db.ncdd.gov.kh/cdbonline/home/index.castle ( accessed 26 May 2012 )

អ្នកពាក់ព័ន្ធទាំងនោះ។ ទោះបីនគរូបនីយកម្មនៅកម្ពុជានៅមានលក្ខណៈក្មេងខ្ចី ហើយតំបន់ទីប្រជុំជននានាប្រហែលអាចនៅរក្សាបាននូវ លក្ខណៈចាំបាច់មួយចំនួនសម្រាប់ឲ្យអភិបាលកិច្ចមូលដ្ឋានអនុវត្តបានជោគជ័យក្តី ក៏អត្ថបទនេះយល់ស្រប ជាមួយការសិក្សារបស់ Ojendal and Dellnas (2010) ដែលថា ការយកគំរូអភិបាលកិច្ចមូលដ្ឋានមួយទៅ អនុវត្តនៅក្នុងបរិបទទីក្រុងទំនើបមួយ គឺជាការពិបាក។

## អធិប្បាយសង្ខេបពីបរិបទវិមជ្ឈការ

កម្ពុជាបានអនុវត្តកំណែទម្រង់វិមជ្ឈការ ដើម្បីដោះស្រាយបញ្ហាភាពពេញច្បាប់ផ្នែកនយោបាយ និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច តាមការបង្កឲ្យមានការចូលរួមពីថ្នាក់មូលដ្ឋានក្នុងការសម្រេចចិត្តផ្សេងៗ និងដាក់ឲ្យអាជ្ញាធរមូលដ្ឋានមានគណនេយ្យភាព។ ការបោះឆ្នោតឃុំសង្កាត់លើកទី១ បានធ្វើឡើងក្នុងឆ្នាំ២០០២។ សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវបានបោះឆ្នោតជ្រើសតាំងដោយផ្ទាល់ពីប្រជាជន សម្រាប់អាណត្តិប្រាំឆ្នាំ ស្របតាមប្រព័ន្ធបោះឆ្នោតសមាមាត្រផ្អែកលើបញ្ជីគណបក្ស។ គោលដៅជាក់លាក់នៃកំណែទម្រង់ រួមមាន ពង្រឹងរបបប្រជាធិបតេយ្យ កែលំអការផ្តល់សេវាដល់ប្រជាជនមូលដ្ឋាន និង លើកកម្ពស់ជីវភាពប្រជាជនមូលដ្ឋាន (RGC 2005)។ ចាប់ពីឆ្នាំ២០០៩ មក សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ជាអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត/ក្រុង។ ជាគោលការណ៍ សមាជិកក្រុមប្រឹក្សាខេត្ត/ក្រុង ត្រូវមានគណនេយ្យភាពចំពោះ ក្រុមប្រឹក្សាឃុំសង្កាត់ដែលជាអ្នកបោះឆ្នោតជ្រើសតាំងខ្លួនឡើង (ច្បាប់រៀបចំអង្គការឆ្នាំ២០០៨) ប៉ុន្តែក្នុងការពិតជាក់ស្តែង រឿងនេះនៅជាបញ្ហាចោទនៅឡើយ (Hughes & Devas 2007; Chheat *et al.* 2011)។ ក្នុងក្របខ័ណ្ឌថ្មីនេះ ក្រុមប្រឹក្សាថ្នាក់មូលដ្ឋានត្រូវពិភាក្សា និងតំណាងឲ្យគំនិតរបស់ប្រជាជនមូលដ្ឋាន ក្នុងការធ្វើផែនការក្នុងមូលដ្ឋាន ដើម្បីឲ្យស្របតាមតម្រូវការក្នុងមូលដ្ឋាន។ ច្បាប់ចែងថា ពួកគេត្រូវមានគណនេយ្យភាពចំពោះប្រជាជន ប៉ុន្តែបញ្ហាធនធានហិរញ្ញវត្ថុមិនគ្រប់គ្រាន់ បានរារាំងពួកគេមិនឲ្យមានគណនេយ្យភាពពិតៗ ចំពោះអ្នកបោះឆ្នោតឲ្យខ្លួន។ ការផ្ទេរថវិកាដែលមានតិចតួចបែបនេះ មានន័យថា វិមជ្ឈការហិរញ្ញវត្ថុមិនទាន់កើតមានជាក់ស្តែងនៅឡើយទេ (Pak 2011)។

ក្នុងពេលដែល ការអនុវត្តកំណែទម្រង់រដ្ឋបាល និងនយោបាយដ៏មោះមុតនេះ បានទទួលការកោតសរសើរយ៉ាងខ្លាំង ព្រោះអាចចូលរួមចំណែកដល់ ការអភិវឌ្ឍដែលមានមូលដ្ឋានទ្រឹស្តីជួយទ្រទ្រង់ជាក់លាក់ (Öjendal 2002, 2005) គឺនៅមានបញ្ហាប្រឈមមួយចំនួនទៀត ដូចជាក្របខ័ណ្ឌច្បាប់ ការរចនារៀបចំស្ថាប័ន និងយន្តការសម្រាប់ឲ្យរដ្ឋាភិបាលថ្នាក់ក្រោមជាតិធ្វើការសម្របសម្រួល និងជួយក្រុមប្រឹក្សាឃុំ (Rusten *et al.* 2004)។ ទោះបីជាកំណែទម្រង់នេះ ទទួលបានការសរសើរចំពោះការរួមចំណែកពង្រឹងរបបប្រជាធិបតេយ្យ និងការកាត់បន្ថយភាពក្រីក្រនៅមូលដ្ឋាន (Öjendal & Kim 2006, 2011, 2011a; Kim 2011) និងបើកឱកាសឲ្យស្ត្រីបានចូលរួមនៅក្នុងការងារអភិបាលកិច្ចមូលដ្ឋានក្តី ប៉ុន្តែនៅមានការងារជាច្រើនទៀតនៃកំណែទម្រង់នេះដែលត្រូវការ ការធ្វើឲ្យប្រសើរឡើងថែមទៀត (Kim 2011; Manor 2008)។ ទោះបីជាក្នុងក្របខ័ណ្ឌច្បាប់មានចែងច្បាស់ពីអាណត្តិ និងមុខងារក្តី ក៏ឃុំសង្កាត់បាននិងកំពុងអនុវត្តត្រឹមតែមុខងារតូចតាច ដូចជាការធ្វើបញ្ជីអត្រានុកូលដ្ឋាន ការដោះស្រាយទំនាស់សាមញ្ញៗ និងការប្រមូលទិន្នន័យ សេដ្ឋកិច្ច-សង្គមកិច្ចសម្រាប់ស្ថាប័នរដ្ឋផ្សេងៗប៉ុណ្ណោះ (Kim & Henke 2005)។ បញ្ហាដែលមានលក្ខណៈ រសើបខាងនយោបាយ ដូចជាការគ្រប់គ្រងដីធ្លី ព្រៃឈើ និងធនធានធម្មជាតិជាដើម បច្ចុប្បន្នខាងឃុំសង្កាត់ មិនទាន់អាចឈោងដល់នៅឡើយទេ បើទោះជាបទបញ្ញត្តិច្បាប់បានកំណត់ឲ្យធ្វើប្រតិភូកម្មទំនួលខុសត្រូវ និងសិទ្ធិអំណាចប្រភេទនេះទៅឲ្យពួកគេ ក្តី (Kim & Öjendal 2011)។

ការអនុវត្តកំណែទម្រង់វិមជ្ឈការនេះ កំពុងតែកើតឡើងនៅក្នុងពេលដែលប្រទេសកម្ពុជា កំពុងមានការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចយ៉ាងខ្លាំង ទាំងវិជ្ជមាន និងអវិជ្ជមាន។ តាមការព្យាករណ៍ ចំនួនប្រជាជនកម្ពុជានៅទីប្រជុំជន នឹងកើនឡើងខ្ពស់ដល់ ៣,៥% ក្នុងមួយឆ្នាំ ឬកើន ៣៥% ដល់ប្រាំបីលាននាក់នៅត្រឹមឆ្នាំ២០៣០។ នគរូបនីយកម្មឆាប់រហ័ស នាំឲ្យចំណុចខ្វះខាតកើនឡើងនៅតំបន់ទីប្រជុំជន ដូចជាបញ្ហា ការផ្តល់សេវាសាធារណៈមិនបានគ្រប់គ្រាន់ ការតាំងទីលំនៅខុសច្បាប់ និងការបំពុលបរិស្ថានជាដើម (Benghong 2006; OCM, undated)។ គេជឿថា វិមជ្ឈការនឹងជួយដោះស្រាយបញ្ហាទាំងនេះ (Benghong 2006; Devas 2004) ប៉ុន្តែនៅថ្នាល់កន្លែងគេអាចអនុវត្តបានពិតជាក់ស្តែងប៉ុណ្ណា ពេលនេះមិនទាន់អាចវាយតម្លៃបាននៅឡើយទេ។

## ហេតុអ្វីត្រូវមានអភិបាលកិច្ចទីប្រជុំជន?

ទោះបីជា នៅកម្ពុជាពេលថ្មីៗនេះមានកំណើនសេដ្ឋកិច្ចដ៏លឿនក៏ពិតមែន ប៉ុន្តែកម្ពុជានៅតែជាប្រទេសកំពុងអភិវឌ្ឍន៍មួយ ដែលត្រូវការជំនួយអភិវឌ្ឍន៍ជាច្រើននៅឡើយ។ ចំណុចគួរបារម្ភមួយទៀតដែលត្រូវកត់សម្គាល់ គឺជំនួយអភិវឌ្ឍន៍ភាគច្រើនតម្រង់ទិសទៅរកតែតំបន់ជនបទដែលគេឃើញថាមានភាពក្រីក្រច្រើនជាងគេ ហើយមើលរំលងភាពក្រីក្រនៅតំបន់ទីប្រជុំជន។ បើសិនចង់ដោះស្រាយ បញ្ហាផ្សេងៗនៅតំបន់ទីប្រជុំជន ឲ្យបានត្រឹមត្រូវ ស្ថាប័នអភិបាលកិច្ចមូលដ្ឋាននៅតំបន់ទីប្រជុំជនត្រូវតែមានសមត្ថភាពច្រើនជាងនេះ ហើយគេត្រូវមានគោលនយោបាយវិមជ្ឈការដែលយកចិត្តទុកដាក់ពី លក្ខណៈទីតាំងភូមិសាស្ត្រខុសគ្នា។ ក្នុងផ្នែកនេះ យើងនឹងពិភាក្សាពីហេតុផលមួយចំនួនដែលគេគួរបង្កើនការយកចិត្តទុកដាក់ ទៅលើអភិបាលកិច្ចតំបន់ទីប្រជុំជន។

ទី១ ការសិក្សាសំខាន់ៗជាច្រើន បានបង្ហាញពីកង្វះចំណាប់អារម្មណ៍លើអភិបាលកិច្ចទីប្រជុំជន នៅក្នុងការស្រាវជ្រាវស្តីពីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការនៅកម្ពុជា។ អត្ថបទរបស់ Blunt and Turner (2005) ដែលរៃកញ្ញែកថា បរិបទស្ថាប័ន និងសង្គមវប្បធម៌នៅកម្ពុជា មិនសូវសមស្របនឹងកំណែទម្រង់វិមជ្ឈការនោះ ហាក់មិនបានយកចិត្តទុកដាក់សោះពីភាពខុសប្លែកគ្នារវាងតំបន់ទីប្រជុំជន និងជនបទ។ ស្រដៀង

គ្នានេះដែរ ការសិក្សាវាយតម្លៃរបស់ Smoke and Morrison (2008) ពីដំណើរការវិមជ្ឈការនៅកម្ពុជា បានមើលរំលងទិដ្ឋភាពជាក់ស្តែងនៅតំបន់ទីប្រជុំជន។ របាយការណ៍នោះពិភាក្សាថា តើកំណែទម្រង់វិមជ្ឈការនៅកម្ពុជា ជាមធ្យោបាយមួយសម្រាប់ពង្រឹងអំណាចរបស់រដ្ឋាភិបាលមជ្ឈឹម ឬក៏ បង្កើតនូវវេទិកាមួយ ដើម្បីឲ្យមានគណនេយ្យភាពពីលើចុះក្រោមពោលគឺ ចំពោះដល់ប្រជាពលរដ្ឋឬយ៉ាងណា ប៉ុន្តែរបាយការណ៍នេះ ហាក់ដូចបានច្របាច់បូកបញ្ចូលរួមគ្នានូវស្ថានភាពខុសគ្នារវាងតំបន់ ទីប្រជុំជន និងជនបទ ហើយមិនបានពិនិត្យពីតថភាពជារួមនៅទីប្រជុំជនដែលអាចជំរុញ ឬរារាំងដល់ការអនុវត្តអភិបាលកិច្ចតំបន់ទីប្រជុំជនក្នុងបរិបទវិមជ្ឈការនោះទេ។ គេក៏សង្កេតឃើញមានអារម្មណ៍សុទិដ្ឋិនិយមខ្លាំងមួយ នៅក្នុងរបាយការណ៍របស់ Ojendal and Kim (2011) ស្តីពីដំណើរជឿនលឿនទៅកាន់ វិមជ្ឈការតាមបែបប្រជាធិបតេយ្យពិតៗនៅកម្ពុជា ប៉ុន្តែស្ថានភាពជាក់ស្តែងនៅតំបន់ទីប្រជុំជន មិនត្រូវបានគេបង្ហាញនៅក្នុង រូបភាពនៃសុទិដ្ឋិនិយមនោះទេ។ ពួកគេវែកញែកថា ទិដ្ឋភាពសុទិដ្ឋិនិយមនេះ អាចផុសចេញពីធាតុពិតដែលកំណែទម្រង់ បានកើតចេញពីបទពិសោធន៍នៅកម្ពុជាផ្ទាល់ (Ojendal & Kim 2011) និងមិនមែននាំចូលទាំងស្រុងពីបរទេសនោះទេ។ ការសិក្សាទាំងនេះមានចំណុចខ្សោយរួមមួយគឺកង្វះ ឬការបំភ្លេចចោលនូវទិដ្ឋភាពនៃកន្លែងនៅតំបន់ទីប្រជុំជននៅក្នុងការវិភាគអំពីបាតុភូតសង្គម នយោបាយ ឬក៏បញ្ហាផ្សេងៗខាងទ្រឹស្តីដែលពួកគេបានធ្វើការសិក្សាស្រាវជ្រាវ។ អត្ថបទនេះលើកមកពិភាក្សាតែ ឧទាហរណ៍មួយចំនួនតូចប៉ុណ្ណោះ ប៉ុន្តែការវែកញែកពីបញ្ហាខាងលើ ឃើញមាននៅក្នុងឯកសារមានស្រាប់ទាំងអស់ដែលពិនិត្យពីរឿងនេះ ហើយវាបង្ហាញថា ក្នុងផ្នែកស្រាវជ្រាវពីរដ្ឋបាលមូលដ្ឋាននៅកម្ពុជានៅមានចន្លោះប្រហោងមួយត្រូវបំពេញដែលទាក់ទងនឹងអភិបាលកិច្ចក្នុងបរិបទទីប្រជុំជន។

ទី២ គេមិនទាន់ដឹងទេថា តើគោលនយោបាយវិមជ្ឈការដែលនាំឲ្យមាន ការបង្កើតរចនាសម្ព័ន្ធរដ្ឋាភិបាលថ្នាក់ក្រោមជាតិថ្មីនោះបានយកចិត្តទុកដាក់កម្រិតណាពីភាពស្មុគស្មាញនិងតថភាពជាក់ស្តែងនៃបរិបទទីប្រជុំជននោះទេ។ ក្រុមប្រឹក្សាស្រុក/ខេត្តថ្មីព្រមទាំងតួនាទី និងមុខងាររបស់ពួកគេ ត្រូវបានកំណត់ឡើងនៅក្នុងបរិបទនៃនគរូបនីយកម្មឆាប់រហ័ស ដែលកើតមានឡើងស្របគ្នានឹងកំណើនសេដ្ឋកិច្ចយ៉ាងទៀងទាត់នៅកម្ពុជា។ ភាពក្រីក្រនៅតំបន់ទីក្រុង គឺជាបាតុភូតផ្នែករចនាសម្ព័ន្ធមួយដែលមួយផ្នែកគឺ ជំរុញឡើងដោយសារសំពាធនៃការបាត់បង់ការងារ និងមធ្យោបាយចិញ្ចឹមជីវិតបែបប្រពៃណីនៅតំបន់ជនបទ និងមួយផ្នែកទៀត គឺដោយសារវត្តមានមធ្យោបាយចិញ្ចឹមជីវិត និងឱកាសសេដ្ឋកិច្ចល្អៗនៅទីក្រុង ដែលកើតមានតាមរយៈការអនុវត្តប្រព័ន្ធសេដ្ឋកិច្ចសេរីនិយមបែបថ្មី។ ជនក្រីក្រនៅទីក្រុងភាគច្រើនរស់នៅក្នុងតំបន់ក្រតោកយ៉ាក ដែលខ្វះខាតទាំងសេវាកម្មជាមូលដ្ឋាន ដោយសារកង្វះខាតសមត្ថភាពរបស់អាជ្ញាធរនៅតំបន់ទីក្រុង។ ការចូលរួមរបស់ប្រជាជនក្នុងការធ្វើផែនការក្នុងមូលដ្ឋាន និងការសម្រេចចិត្តផ្សេងៗដែលអាចជះឥទ្ធិពលទៅលើការរស់នៅរបស់ខ្លួន កម្រទទួលបានការវាយតម្លៃខ្ពស់ពីសំណាក់អាជ្ញាធរតំបន់ទីប្រជុំជនណាស់ ហើយស្ថានភាពនេះបានធ្វើឲ្យពួកគេកាន់តែខ្សត់ខ្សោយសិទ្ធិអំណាចថែមទៀត (Devas 2004)។ បើគេធ្វើការពិនិត្យម៉ត់ចត់ទៅលើ កំណែទម្រង់របស់កម្ពុជាដែលប្រព្រឹត្តទៅនៅក្នុងតំបន់ទីប្រជុំជន គេនឹងអាចជួយបំភ្លឺពីការចូលរួមរបស់ប្រជាពលរដ្ឋ និងថាតើការចូលរួមនោះមានអត្ថន័យយ៉ាងណា។

ទី៣ ចំណុចថា តើរដ្ឋាភិបាលត្រូវធ្វើអ្វីខ្លះ ដើម្បីធានាឲ្យអនុវត្តគោលនយោបាយវិមជ្ឈការបានប្រកបដោយជោគជ័យ ជាពិសេសនៅតំបន់ទីប្រជុំជននោះ ប្រហែលកន្លងមកមិនទាន់ទទួលបានការយកចិត្តទុកដាក់គ្រប់គ្រាន់ទេ[៣]។ ការអនុវត្តកំណែទម្រង់វិមជ្ឈការប្រចាំថ្ងៃរបស់រដ្ឋាភិបាល ហាក់នៅខ្វះអនុសាសន៍ផ្នែកគោលនយោបាយដែលយកចិត្តទុកដាក់ពីទីតាំងផ្សេងៗគ្នា និងគំនិតផ្សេងៗ ក្នុងការដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងការរីកលូតលាស់យ៉ាងឆាប់រហ័សនៃទីប្រជុំជន។ ទោះបីជាគេឃើញមានជោគជ័យមួយកម្រិតក្នុងការអភិវឌ្ឍនៅតាមមូលដ្ឋាន តាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងអំឡុងមួយទសវត្សរ៍កន្លងទៅក៏ពិតមែន ប៉ុន្តែគោលនយោបាយសម្រាប់ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ដែល "មើលមិនឃើញពីស្ថានភាពខុសប្លែកគ្នាតាមកន្លែង" គឺមិនបានជួយឲ្យអន្តរាគមន៍របស់រដ្ឋាភិបាលមានប្រសិទ្ធភាពជាអតិបរមាទេ។ ដើម្បីប្តូរទិសនិន្នាការនេះ UNCDF (2010) បានបញ្ជាក់ពីតម្រូវការឲ្យមានគោលនយោបាយ សម្រាប់ដោះស្រាយបញ្ហាដ៏ជាក់លាក់នានាដែលខេត្ត ឬឃុំសង្កាត់ នៅតំបន់ជនបទ និងនៅទីក្រុងត្រូវប្រឈមមុខ។

## របកគំហើញជាបឋមពីមូលដ្ឋាន

ការសិក្សាដល់កន្លែងជាដំបូងៗនៅខេត្តកំពត និងបាត់ដំបងបានបង្កើនការយល់ដឹងរបស់យើងអំពី ស្ថានភាព ភូមិសាស្ត្រ និងសេដ្ឋកិច្ច-សង្គមកិច្ច និងស្ថានភាពបច្ចុប្បន្ននៃរដ្ឋបាលមូលដ្ឋាននៅក្នុងតំបន់ទីប្រជុំជនទាំងនោះ។[៤] ពិតមែនតែការសិក្សាបានរកឃើញនូវការរីកចម្រើនជាសក្តានុពលក្នុង សមត្ថភាពផ្តល់សេវាកម្ម និងក្នុងចំណូលហិរញ្ញវត្ថុក្តី ប៉ុន្តែនៅមានបញ្ហាប្រឈមជាច្រើនទៀតចំពោះរដ្ឋបាលមូលដ្ឋានបច្ចុប្បន្ន ក្នុងការផ្តល់ និងអនុវត្តសិទ្ធិអំណាចរបស់ខ្លួន នៅតំបន់ទីប្រជុំជន ដែលត្រូវមានការសិក្សាជាលក្ខណៈប្រព័ន្ធ ដើម្បីស្វែងយល់ពីភាពស្មុគស្មាញនៃបញ្ហាទាំងនេះ និងវិធីដោះស្រាយ។

ពិតណាស់ តាមនិយមន័យ ស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចនៅតំបន់ទីក្រុង វាខុសប្លែកពី ស្ថានភាពនៅតំបន់ជនបទ ហើយវាបង្ហាញពីទំនាក់ទំនងរវាងតំបន់ទាំងពីរ។ អ្នករស់នៅតំបន់ទីប្រជុំជនភាគច្រើន ជាអ្នកលក់ដូរតូចតាច បុគ្គលិករដ្ឋ ឬពលករស៊ីប្រាក់ខែ ហើយមានច្រើននាក់ជាជនចំណាកស្រុកពីតំបន់ជនបទ។ សមាសភាពនេះចោទបញ្ហាមួយធំចំពោះរដ្ឋាភិបាលក្នុងការប្រមែប្រមូលប្រជាជនឲ្យរួមចំណែកក្នុង ការសម្រេច

---

[៣] សម្ភាសន៍ជាមួយ ឯកឧត្តម ឡេង វី ប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ ថ្ងៃទី៤ ឧសភា ២០១២។

[៤] ការសិក្សាដល់កន្លែង បានធ្វើក្នុងខេត្តកំពត នៅថ្ងៃទី ១៩-២០ មករា ២០១២ និងក្នុងខេត្តបាត់ដំបង នៅថ្ងៃទី ៨-១០ កុម្ភៈ ២០១២។

ចិត្ត និងការពិភាក្សានៅមូលដ្ឋាន។ វាក៏បង្កើតបរិយាកាសមួយដែលក្នុងនេះ អ្នកធូរធារ និងអ្នកមានទំនាក់ទំនងល្អជាមួយថ្នាក់លើ តែងរំពឹងថា ក្រុមប្រឹក្សាមូលដ្ឋានត្រូវអនុវត្តមុខងារតាមបែបណាមួយដែលខ្លួនអាចទទួលយកបាន និងមានផលប្រយោជន៍ចំពោះខ្លួន។ ប៉ុន្តែក្រុមនេះតែងដើរវិលងអាជ្ញាធរមូលដ្ឋាន នៅពេលដែលពួកគេត្រូវការសេវាកម្មផ្សេងៗ ដោយសារតែពួកគេមានទំនាក់ទំនងជិតស្និទ្ធជាមួយ ថ្នាក់លើដែលនៅតែក្ដោបក្ដាប់ការងារផ្ដល់សេវាកម្ម។ ទំនាក់ទំនងជិតស្និទ្ធនោះ អាចជំរុញឲ្យមាន កិច្ចសហប្រតិបត្តិការល្អរវាងថ្នាក់ផ្សេងៗនៃរដ្ឋាភិបាលថ្នាក់ក្រោមជាតិ ប៉ុន្តែ វាក៏បង្កើតភាពច្របូកច្របល់ដែរ ដោយសារកង្វះការបញ្ជាក់ឲ្យច្បាស់ពីតួនាទី និងមុខងារនៅតាមថ្នាក់នីមួយៗ។

ដោយសារមានភាពនៅកៀកគ្នា និងទំហំកន្លែង គេត្រូវមានជាចាំបាច់នូវអន្តរកម្ម និងកិច្ចសហប្រតិបត្តិការរវាងសង្កាត់នានាក្នុងការផ្ដល់សេវា និងដោះស្រាយបញ្ហាសង្គម។ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជា បំពង់ផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធលូ ផ្លូវថ្នល់ និងបណ្ដាញអគ្គិសនី ដែលជាសេវាសំខាន់បំផុតសម្រាប់ជីវភាពនៅទីប្រជុំជន តម្រូវឲ្យមានកិច្ចសហប្រតិបត្តិការរឹងមាំ និងការយោគយល់គ្នារវាងសង្កាត់នានា។ វិធីសាស្ត្រនេះក៏ចាំបាច់ដែរសម្រាប់ដោះស្រាយបញ្ហា ដូចជា ក្រុមជនពាល បទឧក្រិដ្ឋ ចំណាកស្រុក និង ការបំពុលបរិស្ថានជាដើម។

ក្នុងយុទ្ធនាការជំរុញឲ្យមាន ការផ្ដល់សេវាបានកាន់តែមានប្រសិទ្ធភាព នៅក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការនោះ ការិយាល័យសេវាច្រកចេញចូលតែមួយ (OWSO) ត្រូវបានបង្កើតឡើងឲ្យដំណើរការជា យន្តការមួយទៀតសម្រាប់ការផ្ដល់សេវាកម្មនៅកម្រិតក្រុង/សង្កាត់ (Thon *et al.* 2010)។ OWSO មានគំនិតក្នុងការលើកកម្ពស់ ការផ្ដល់សេវាកម្មប្រកបដោយតម្លាភាពនៅក្នុងប្រព័ន្ធរដ្ឋ។ គំរូនេះ អាចចាត់ទុកជា យន្តការមួយដ៏មានប្រសិទ្ធភាព សម្រាប់ការធ្វើប្រតិភូកម្មមុខងារមួយចំនួនទៅឲ្យក្រុមប្រឹក្សាតាមសង្កាត់ ដើម្បីឲ្យពួកគេអាចឆ្លើយតបបានកាន់តែប្រសើរចំពោះតម្រូវការក្នុងមូលដ្ឋាន។ ក្រុមប្រឹក្សាសង្កាត់នៅតំបន់ទីប្រជុំជន ដើរតួនាទីសំខាន់ណាស់ក្នុងការចុះបញ្ជីទ្រព្យសម្បត្តិ និងការប្រមូលពន្ធលើទ្រព្យសម្បត្តិ ដែលទើបនឹងណែនាំថ្មីៗនៅតំបន់ទីប្រជុំជន។ សក្ដានុពលក្នុងការរកចំណូល និងផ្ដល់សេវាកម្មនេះ អាចជួយឲ្យមានការយល់ដឹងកាន់តែប្រសើរអំពីបរិយាកាសសេដ្ឋកិច្ច-សង្គមកិច្ច នៅតំបន់ទីប្រជុំជន ដែលអាជ្ញាធរមូលដ្ឋានត្រូវមានការជាប់ពាក់ព័ន្ធច្រើនណាស់។

ប្រព័ន្ធពហុបក្សនៅកម្ពុជា កន្លងមកបានទទួលរងការរិះគន់ថាជារបបនយោបាយបែបប្រជាធិបតេយ្យ "តែសំបកក្រៅ" នៅកម្ពុជា។ នៅក្នុងរដ្ឋអំណាចថ្នាក់មូលដ្ឋាននៅតំបន់ទីប្រជុំជន ការសម្រេចចិត្តផ្សេងៗក្នុងក្រុមប្រឹក្សា គឺខ្វះខាតនូវការសន្ទនា ឬ ការពិភាក្សាឆ្លងកាត់ក្រុមបក្សនយោបាយផ្សេងៗគ្នា។ សមាជិកក្រុមប្រឹក្សាមកពីគណបក្សប្រឆាំង ជារឿយៗត្រូវគេបំភ្លេចចោលនៅក្នុងការសម្រេចចិត្ត ឬការចូលរួមជាមួយដៃគូអភិវឌ្ឍន៍នានា ដូចជា វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល ឬក៏ក្នុងការចូលរួមក្នុងពិធីជាផ្លូវការផ្សេងៗ។ មួយវិញទៀត គោលគំនិតនៃ "សង្គមស៊ីវិល" នៅមិនទាន់មានការយល់ដឹងជាទូទៅ ឬយល់ដឹងបានស្មើៗគ្នានៅតាមតំបន់ទីប្រជុំជនទេ ហើយជាក់ស្ដែងតួនាទី "សង្គមស៊ីវិល" នេះកម្រមានឮសូរគេលើកឡើងណាស់ នៅតាមសង្កាត់ទីក្រុងក្នុងខេត្តកំពត ប៉ុន្តែមានគេលើកឡើងជារឿយៗនៅតំបន់ទីក្រុងក្នុងខេត្តបាត់ដំបង។

## ការស្រាវជ្រាវស្នើឡើងដោយ CDRI

ដោយពិនិត្យឃើញចន្លោះខ្វះខាតផ្នែកចំណេះដឹងនេះ CDRI បានរចនារៀបចំការសិក្សាមួយ ដើម្បីពិនិត្យពីអភិបាលកិច្ចតំបន់ទីប្រជុំជននៅកម្ពុជា ក្រោយធ្វើវិមជ្ឈការ។ ការស្រាវជ្រាវនេះព្យាយាមឆ្លើយតបនឹងសំណួរៈ តើគោលនយោបាយវិមជ្ឈការជះឥទ្ធិពលយ៉ាងដូចម្ដេចទៅលើ អភិបាលកិច្ចតំបន់ទីប្រជុំជននៅកម្ពុជា? ការស្រាវជ្រាវនេះនឹងពិនិត្យថា តើកំណែទម្រង់នេះជះឥទ្ធិពលយ៉ាងណាលើគណនេយ្យភាព និងការឆ្លើយតបរបស់អាជ្ញាធរមូលដ្ឋាន ចំពោះប្រជាជន និងតើប្រជាជនមូលដ្ឋាន បានឆ្លើយតប និងចូលរួមដូចម្ដេចក្នុងដំណើរការធ្វើការសម្រេចចិត្តក្នុងបរិបទវិមជ្ឈការ។

ក្របខ័ណ្ឌស្រាវជ្រាវជាគោលគំនិតនេះបានយកចិត្តទុកដាក់ជាពិសេសលើទំនាក់ទំនងសង្គមដែលប្រែប្រួល ទៅតាមទីតាំង ថាតើទំនាក់ទំនងទាំងនោះ ជះឥទ្ធិពលយ៉ាងណាទៅលើតួអង្គនានា។ គេអាចស្វែងយល់ពី ដំណើរការដ៏ស្មុគស្មាញ និងសំខាន់ ក្នុងការតភ្ជាប់រវាងអាជ្ញាធរ និងប្រជាពលរដ្ឋបាន តាមរយៈគោលគំនិតបីសំខាន់ៗគឺ គណនេយ្យភាព ការឆ្លើយតប និង ការចូលរួម ដែលមានលើកឡើងជារឿយៗ នៅក្នុងការសិក្សាមានស្រាប់នានាស្ដីពីអភិបាលកិច្ច និងវិមជ្ឈការ។ ការសិក្សានេះបានវិភាគលើគោលគំនិតទាំងបីខាងលើ ព្រមទាំងបូកបញ្ចូលនូវការយកចិត្តទុកដាក់ពីទីតាំង ពោលគឺដោយមានការយល់ដឹងថា គំនិតចម្បងទាំងបីនេះ កំពុងកើតឡើងនៅក្នុងលំហកន្លែងតូចចង្អៀត ដែលជាលក្ខណៈធម្មតានៃតំបន់ទីប្រជុំជន ដែលខុសពីតំបន់ជនបទមានកន្លែងលំហធំទូលាយ។ ជាការសំខាន់ណាស់ដែលត្រូវមើលឃើញថា លំហគឺជាចំនុចផ្ដោតនៃគោលគំនិតទាំងនេះ គឺមិនមែនដូចក្នុងការយល់ឃើញជាទូទៅដែលថា លំហគឺជាកន្លែងដែលគោលគំនិតទាំងនេះស្ដែងឡើងនោះទេ។ ការចូលរួមក្នុងការអភិវឌ្ឍ និងកិច្ចការនយោបាយនៅមូលដ្ឋាន ជាទិដ្ឋភាពដ៏សំខាន់បំផុតមួយនៃវិមជ្ឈការបែបប្រជាធិបតេយ្យ ព្រោះបានអនុញ្ញាតឲ្យប្រជាពលរដ្ឋចូលរួម និងបញ្ចេញសំឡេង/ចំណង់ចំណូលចិត្តរបស់ខ្លួនស្ដីពីតម្រូវការនិងការអភិវឌ្ឍក្នុងសហគមន៍។ នៅពេលប្រជាជនមូលដ្ឋាន មានឱកាសចូលរួមក្នុងការកំណត់គម្រោង និងធ្វើផែនការថវិកានោះ ពួកគេទទួល បានព័ត៌មានច្រើនជាងមុនអំពីសកម្មភាពរបស់ថ្នាក់ដឹកនាំ/ក្រុមប្រឹក្សា និងមានអារម្មណ៍ជាម្ចាស់កាន់តែខ្ពស់ (Heng *et al.* 2011)។

គណនេយ្យភាព សំដៅដល់ ការទទួលខុសត្រូវលើសកម្មភាពនានា (Grindle 2011; Kim 2012)។ គេអាចកំណត់និយមន័យវាថាជា កាតព្វកិច្ចត្រូវឆ្លើយបំភ្លឺនិងទទួលខុសត្រូវលើសកម្មភាពនានា ដោយផ្អែកលើក្របខ័ណ្ឌជាក់លាក់មួយ (Kim & Ojendal

*(តទៅទំព័រ ២១)*

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស[១]

ផ្នែកនេះ បង្ហាញពីសូចនាករសេដ្ឋកិច្ចនៃប្រទេសអភិវឌ្ឍន៍ធំៗលើពិភពលោក និងបណ្ដាប្រទេសនៅអាស៊ីបូព៌ា។

ភាពមិនប្រាកដប្រជា នៃបរិយាកាសសេដ្ឋកិច្ចពិភពលោក បានបន្តរារាំងដល់កិច្ចប្រឹងប្រែងជំរុញសេដ្ឋកិច្ច ឲ្យរើបឡើងវិញ នៅបណ្ដាប្រទេសនៅតំបន់អាស៊ីបូព៌ា និងប្រទេសឧស្សាហកម្មធំៗ ដោយការប្រមើលពីកំណើននៅត្រីមាសទី១ ឆ្នាំ២០១២ នេះ វាប្រែប្រួលឡើងចុះខ្លាំងជាងនៅត្រីមាសមុន និងត្រីមាសដូចគ្នាឆ្នាំមុន។

កំណើន ផសស ពិតនៅឥណ្ឌូនេស៊ី ធ្លាក់ចុះបន្តិច មកត្រឹម ៦,៣% ធៀបនឹង ៦,៥% កាលពីឆ្នាំមុន។ កំណើន ផសស នៅម៉ាឡេស៊ី ធ្លាក់ចុះនៅត្រីមាសទី១ មកត្រឹម ៤,៧% ធៀបនឹង ៥,២% កាលពីត្រីមាសមុន។ សេដ្ឋកិច្ចនៅប្រទេសខ្លះអាស៊ីមួយចំនួន បន្តធ្លាក់ចុះទៀត។ កំណើន ផសស ពិត នៅសិង្ហបុរី ធ្លាក់ចុះមកត្រឹម ១,៦% ធៀបនឹង ៦,៨% កាលពីឆ្នាំមុន។ កំណើន ផសស នៅ ហុងកុង និង តៃវ៉ាន់ រួមចុះមកត្រឹម ០,៤% ដែលជាអត្រាទាបបំផុត គិតចាប់ពីឆ្នាំ២០១០ មក។ សេដ្ឋកិច្ចប្រទេសថៃ រើបឡើងវិញមកត្រឹមកម្រិតកាលពីមួយឆ្នាំមុន បន្ទាប់ពីបានធ្លាក់ចុះយ៉ាងគំហុកនៅត្រីមាសទី៤ ឆ្នាំ២០១១។ មូលនិធិរូបិយវត្ថុអន្តរជាតិមានសុទិដ្ឋិនិយមថា សេដ្ឋកិច្ចថៃ នឹងស្ទុះឡើងវិញដល់ ៥,០% នៅឆ្នាំនេះ និង ៥,៥% នៅឆ្នាំ២០១៣។ នៅត្រីមាសទី១ សេដ្ឋកិច្ចប្រទេសចិន កើនឡើងយឺតជាងមុន ប៉ុន្តែនៅមានកម្រិតខ្ពស់ដដែល គឺ ៨,១% ធៀបនឹង ៩,៧% កាលពីឆ្នាំមុន។ កូរ៉េខាងត្បូង មានកំណើន ផសស ៣,០% ធៀបនឹង ៤,២% កាលពីឆ្នាំមុន។

នៅត្រីមាសទី១ ឆ្នាំ២០១២ កំណើនសេដ្ឋកិច្ចនៅតំបន់អឺរ៉ូ រួមចុះដល់សូន្យ ដែលជាកម្រិតទាបបំផុត គិតចាប់ពីឆ្នាំ២០១០ មក។ ថ្នាក់ដឹកនាំនៅបណ្ដាប្រទេសអឺរ៉ុប កំពុងប្រឹងដោះស្រាយវិបត្តិបំណុលនៅប្រទេសក្រិច និងបញ្ហានៅប្រទេសជាសមាជិកសហភាពអឺរ៉ុបដទៃទៀត។ បន្ទាប់ពីទទួលបានកញ្ចប់ប្រាក់ជានាចំនួនបី និងអនុវត្តវិធានការត្បិតត្បៀតចំណាយ ប្រទេសក្រិចត្រូវប្រឹងថែមទៀតដើម្បីស្តារទំនុកចិត្តអាជីវកម្ម និងវិនិយោគិនឡើងវិញ។ ការបោះឆ្នោតនៅខែមិថុនា អាចប៉ះពាល់ដល់ការសម្រេចចិត្តរបស់ប្រទេសក្រិច ក្នុងការអនុវត្តវិធានការរឹតត្បិតចំណាយបន្ថែម ដើម្បីអាចទទួលបានកញ្ចប់ប្រាក់ជានាមួយទៀត ហើយបញ្ហានេះ អាចធ្វើឲ្យក្រិចត្រូវចាកចេញពីតំបន់អឺរ៉ូ។ គេក៏កំពុងផ្ដោតការយកចិត្តទុកដាក់ លើស្ថានភាពមិនល្អនៃលទ្ធភាពសងបំណុលរបស់ធនាគារនៅប្រទេសអេស្ប៉ាញដែរ។

សេដ្ឋកិច្ចសហរដ្ឋអាមេរិក មានដំណើរការល្អដោយមានកំណើន ២,១% នៅត្រីមាសទី១ ឆ្នាំ២០១២។ សេដ្ឋកិច្ចជប៉ុនមានកំណើនវិជ្ជមានវិញ ដល់ ២,៧% បន្ទាប់ពីមានកំណើនអវិជ្ជមាន ឬមានកំណើនសូន្យតាំងពីឆ្នាំ២០១១ មក។ ទោះជាយ៉ាងនេះក្ដី ប្រទេសជប៉ុននៅតែត្រូវបន្តដោះស្រាយបញ្ហាភាពទន់ខ្សោយនៃតម្រូវការពិភពលោក នូវទំនិញប្រើប្រាស់របស់ជប៉ុន ការឡើងថ្លៃប្រាក់យេន ការកសាងសេដ្ឋកិច្ចឡើងវិញ ក្រោយស៊ូណាមិ និងការបង្កើតគោលនយោបាយថាមពល បើសិនជប៉ុនសម្រេចចិត្តមិនប្រើថាមពលនុយក្លេអ៊ែរ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្ដូរប្រាក់

នៅត្រីមាសទី១ ឆ្នាំ២០១១ អតិផរណានៅកម្ពុជាកើនដល់ ៥,៥% ធៀបនឹង ៣,៦% កាលពីឆ្នាំមុន។ ថ្លៃប្រេងក្នុងស្រុក និងអតិផរណាខ្ពស់នៅប្រទេសជិតខាង ដូចជាវៀតណាម ជាដើម បានជះឥទ្ធិពលបន្ថែមទៀត លើថ្លៃប្រេងលក់រាយនៅកម្ពុជា ដោយសារការធ្វើសមាហរណកម្មទីផ្សារផលិតផល។ នៅត្រីមាសទី១ វៀតណាមបន្តមានអតិផរណាខ្ពស់ដដែល ដល់ ១៦,០% បើធៀបនឹង ១២,៨% នៅត្រីមាសដូចគ្នាឆ្នាំមុន។ អត្រាអតិផរណានៅអាស៊ីបូព៌ា និងបណ្ដាប្រទេសឧស្សាហកម្ម មានកម្រិតសមរម្យ។ នៅត្រីមាសទី១ ឆ្នាំ២០១២ អតិផរណាប្រចាំឆ្នាំនៅចិន រួមចុះមកត្រឹម ៣,៨% ធៀបនឹង ៥,១% កាលពីឆ្នាំមុន ប៉ុន្តែអតិផរណានៅតំបន់អឺរ៉ូ កើនដល់ ២,៧% ធៀបនឹង ២,៥% កាលពីឆ្នាំមុន។ ក្នុងអំឡុងពេលនេះដែរ ប្រាក់រៀល ធ្លាក់ថ្លៃ ០,១% ទល់នឹងប្រាក់ដុល្លារ និង ៤,១% ទល់នឹងប្រាក់អឺរ៉ូ ប៉ុន្តែប្រាក់យេនឡើងថ្លៃ ៣,៨% ទល់នឹងប្រាក់ដុល្លារ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី១ ឆ្នាំ២០១២ ពោត (US No. 2) ធ្លាក់ថ្លៃ ១,០% បើធៀបនឹងមួយឆ្នាំមុន មកត្រឹម ២៧៧,៥ដុល្លារ/តោន ប្រេងឆា (អឺរ៉ុបភាគពាយព្យ) ធ្លាក់ថ្លៃ ១១,៥% មកត្រឹម ១១០៦,៧ដុល្លារ/តោន ហើយ កៅស៊ូ (SMR 5) ធ្លាក់ថ្លៃ ២៩,៨% មកត្រឹម ៣៧០១,២ដុល្លារ/តោន។ អង្ករ (Thai 100 percent B) ឡើងថ្លៃ ៣,៩% ដល់ ៥៤៩ដុល្លារ/តោន រីឯសណ្ដែកសៀង (US No. 1) ធ្លាក់ថ្លៃ ៨,៦% មកត្រឹម ៤៩០,៨ដុល្លារ/តោន។ សាំង (US Gulf Coast) ឡើងថ្លៃ ១៦,៣% ដល់ ០,៧៨ដុល្លារ/លីត្រ ហើយម៉ាស៊ូត (US Gulf Coast) ឡើងថ្លៃ ១៥,៥% ដល់ ០,៨៤ដុល្លារ/លីត្រ។

[១] អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

### តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១២ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2006 | 2007 | 2008 | 2009 | 2010 | | | 2011 | | | | 2012 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.6 | 10.2 | 6.8 | 0.1 | - | - | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.4 | 6.3 | 6.1 | 4.2 | 6.2 | 5.8 | 6.9 | 6.5 | 6.5 | 6.5 | 6.5 | 6.3 |
| ម៉ាឡេស៊ី | 5.9 | 6.3 | 4.6 | -2.4 | 8.9 | 5.3 | 4.8 | 4.6 | 4.0 | 5.8 | 5.2 | 4.7 |
| សិង្ហបុរី | 7.7 | 7.7 | 1.1 | -4.5 | 18.7 | 10.5 | 12.0 | 8.3 | 0.9 | 5.9 | 3.6 | 1.6 |
| ថៃ | 4.8 | 4.9 | 2.6 | 3.3 | 9.2 | 6.7 | 3.8 | 3.0 | 2.6 | 3.5 | -9.0 | 0.0 |
| វៀតណាម | 8.1 | 8.5 | 6.2 | 4.7 | 6.4 | 7.2 | 7.3 | 5.4 | 5.7 | 7.2 | 6.1 | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 10.5 | 11.9 | 9.0 | 8.2 | 10.3 | 9.7 | 9.8 | 9.7 | 9.5 | 9.1 | 8.9 | 8.1 |
| ហុងកុង | 6.6 | 6.4 | 2.4 | -3.2 | 6.5 | 6.8 | 6.2 | 7.2 | 5.1 | 4.3 | 3.0 | 0.4 |
| កូរ៉េខាងត្បូង | 5.0 | 4.9 | 2.2 | -1.0 | 7.1 | 4.5 | 4.8 | 4.2 | 3.4 | 3.4 | 3.4 | 3.0 |
| តៃវ៉ាន់ | 4.6 | 5.2 | 0.1 | -3.6 | 12.9 | 9.8 | 6.9 | 6.5 | 4.9 | 3.4 | 1.9 | 0.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.7 | 2.9 | 0.9 | -3.8 | 1.7 | 1.9 | 2.0 | 2.5 | 1.6 | 1.4 | 0.7 | 0.0 |
| ជប៉ុន | 2.1 | 2.0 | -0.7 | -5.4 | 3.5 | 5.0 | 2.2 | -1.0 | -1.0 | 0.0 | -1.0 | 2.7 |
| សហរដ្ឋអាមេរិក | 3.3 | 2.2 | 1.1 | -2.5 | 2.9 | 2.3 | 2.8 | 2.3 | 1.5 | 1.6 | 1.6 | 2.1 |

*Sources: International Monetary Fund, Economist and countries' statistic offices.*

### តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១២ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | 2010 | | | 2011 | | | | 2012 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 4.7 | 10.5 | 19.7 | | 4.1 | 1.8 | 3.3 | 3.6 | 6.2 | 6.7 | 4.9 | 5.5 |
| ឥណ្ឌូនេស៊ី | 13.4 | 6.4 | 10.1 | 4.7 | 4.4 | 6.2 | 6.3 | 6.8 | 5.9 | 4.7 | 4.1 | 3.8 |
| ម៉ាឡេស៊ី | 3.7 | 2.0 | 5.3 | 0.4 | 1.6 | 1.9 | 2.1 | 2.8 | 3.3 | 3.4 | 3.2 | 2.3 |
| សិង្ហបុរី | 1.0 | 2.1 | 6.5 | 0.5 | 3.1 | 3.4 | 4.0 | 5.2 | 4.7 | 5.5 | 5.5 | 4.9 |
| ថៃ | 4.7 | 2.2 | 5.5 | -0.9 | 3.3 | 3.3 | 2.0 | 3.0 | 4.1 | 4.1 | 4.0 | 3.4 |
| វៀតណាម | 7.7 | 8.3 | 23.3 | 7.3 | 9.0 | 8.4 | 10.9 | 12.8 | 19.4 | 22.5 | 19.8 | 16.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 1.5 | 4.8 | 5.9 | -0.8 | 2.7 | 3.3 | 4.7 | 5.1 | 5.7 | 6.3 | 4.6 | 3.8 |
| ហុងកុង | 2.2 | 2.0 | 4.3 | -0.3 | 2.6 | 2.3 | 2.9 | 4.0 | 5.1 | 6.5 | 5.7 | 5.2 |
| កូរ៉េខាងត្បូង | 2.4 | 2.5 | 4.6 | 2.8 | 2.6 | 2.9 | 3.6 | 4.4 | 4.2 | 4.8 | 4.1 | 2.9 |
| តៃវ៉ាន់ | 0.6 | 1.8 | 3.2 | -1.1 | 1.1 | 0.4 | 1.1 | 1.3 | 1.6 | 1.3 | 1.4 | 1.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 2.1 | 3.3 | 0.4 | 1.5 | 1.7 | 2.0 | 2.5 | 2.7 | 2.7 | 2.9 | 2.7 |
| ជប៉ុន | 0.5 | 0.1 | 1.4 | -1.3 | -0.9 | -0.9 | 0.1 | 0.0 | 0.3 | 0.2 | -0.3 | 0.3 |
| សហរដ្ឋអាមេរិក | 3.2 | 2.9 | 3.8 | -0.4 | 1.8 | 1.2 | 1.3 | 2.1 | 3.5 | 3.8 | 3.3 | 2.8 |

*Sources: International Monetary Fund, Economist and National Institute of Statistics.*

### តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១២ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | 2010 | | 2011 | | | | 2012 |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា (រៀល) | 4103.20 | 4062.70 | 4054.20 | 4140.48 | 4236.69 | 4122.58 | 4041.90 | 4044.89 | 4095.66 | 4071.89 | 4045.98 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 9134.00 | 9419.00 | 9699.00 | 10413.83 | 8995.11 | 8965.70 | 8902.02 | 8593.94 | 8625.83 | 8985.65 | 9078.63 |
| ម៉ាឡេស៊ី (រីងហ្គិត) | 3.70 | 3.30 | 3.30 | 3.52 | 3.15 | 3.11 | 3.05 | 3.02 | 3.02 | 3.15 | 3.06 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.59 | 1.51 | 1.42 | 1.45 | 1.36 | 1.30 | 1.28 | 1.24 | 1.23 | 1.29 | 1.26 |
| ថៃ (បាត) | 37.90 | 32.22 | 33.36 | 34.34 | 31.63 | 29.99 | 30.56 | 30.28 | 30.15 | 30.98 | 31.00 |
| វៀតណាម (ដុង) | 15994.00 | 16030.00 | 16382.00 | 17725.24 | 19485.00 | 19499.48 | 20273.83 | 20693.58 | 20699.60 | 20997.70 | 20971.18 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន (យ៉ន់) | 7.97 | 8.03 | 6.94 | 6.83 | 6.77 | 6.66 | 6.58 | 6.50 | 6.42 | 6.36 | 6.31 |
| ហុងកុង (ដុល្លារហុងកុង) | 7.77 | 7.80 | 7.78 | 7.75 | 7.77 | 7.76 | 7.79 | 7.78 | 7.79 | 7.78 | 7.76 |
| កូរ៉េខាងត្បូង (វ៉ុន) | 955.00 | 929.04 | 1137.23 | 1277.76 | 1182.41 | 1132.85 | 1120.19 | 1084.27 | 1084.90 | 1144.87 | 1131.17 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.50 | 32.85 | 31.54 | 33.04 | 31.90 | 30.36 | 29.30 | 28.86 | 29.19 | 30.26 | 29.68 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.80 | 0.70 | 0.84 | 0.72 | 0.77 | 0.74 | 0.73 | 0.70 | 0.71 | 0.74 | 0.76 |
| ជប៉ុន (យ៉េន) | 116.40 | 117.80 | 102.46 | 93.60 | 85.74 | 82.53 | 82.33 | 81.66 | 77.86 | 77.78 | 79.30 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

### តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៦-២០១២ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | 2010 | | 2011 | | | | 2012 |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ពោត (US No. 2) - USA (USD/តោន) | 111.04 | 149.08 | 218.15 | 167.31 | 176.13 | 238.81 | 280.32 | 311.63 | 302.79 | 270.77 | 277.50 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 433.85 | 707.68 | 912.23 | 686.84 | 874.67 | 1108.00 | 1251.00 | 1147.00 | 1079.00 | 1024.67 | 1106.67 |
| កៅស៊ូ SMR 5 (USD/តោន) | 1996.30 | 2202.30 | 2586.30 | 1884.84 | 3175.97 | 4257.27 | 5278.03 | 4968.77 | 4617.57 | 3658.00 | 3701.17 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 282.00 | 305.36 | 615.32 | 524.47 | 468.33 | 531.00 | 528.25 | 514.33 | 581.3 | 610.33 | 549.00 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 213.88 | 294.59 | 460.41 | 414.03 | 406.88 | 480.24 | 537.24 | 525.66 | 513.98 | 454.83 | 490.79 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 61.58 | 69.25 | 95.44 | 60.50 | 74.91 | 84.17 | 100.70 | 113.31 | 108.91 | - | - |
| សាំង - US Gulf Coast (សេន/លីត្រ) | 47.70 | 53.58 | 62.22 | 42.91 | 51.54 | 57.23 | 67.92 | 78.73 | 74.63 | 68.50 | 78.97 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 51.35 | 55.51 | 76.20 | 43.05 | 53.64 | 61.68 | 72.47 | 75.72 | 77.27 | 77.31 | 83.75 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច-ស្ថានភាពក្នុងប្រទេស[១]

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

បរិយាកាសសេដ្ឋកិច្ចសកលនៅអន់ខ្សោយ ដោយសារជាសំខាន់ វិបត្តិហិរញ្ញវត្ថុ និងវិបត្តិបំណុលនៅប្រទេសក្រិច និងនៅប្រទេសអឺរ៉ុបខ្លះទៀតក៏ពិតមែន ប៉ុន្តែសេដ្ឋកិច្ចកម្ពុជានៅខ្លាំងក្លាគួរសម ដោយមានកំណើន ផសស ៧,០% នៅឆ្នាំ២០១១។ ដំណើរការសេដ្ឋកិច្ចនៅត្រីមាសទី៤ ឆ្នាំ២០១១ ហាក់បានល្អប្រសើរជាងកាលពីត្រីមាសទី៤ ឆ្នាំ២០១០។ អនុមតិវិនិយោគសរុប គិតជាទ្រព្យសកម្មជាប់លាប់កើន ៩,៦% ធៀបនឹងមួយឆ្នាំមុន ក្នុងនោះ អនុមតិវិនិយោគខាងកសិកម្ម មាន ៣២,៩% ខាងឧស្សាហកម្ម មាន ១៣,១% និងខាងសេវាកម្ម មាន ៥៤,០%។ វិស័យកសិកម្មបានស្ទុះឡើងវិញ ដោយមានកំណើនអនុមតិវិនិយោគ១១00%ធៀបនឹងមួយឆ្នាំមុនដល់៤៤០,៦លានដុល្លារ។ វិនិយោគខាងឧស្សាហកម្ម កើន ៩៩,៤% ក្នុងនេះផ្នែកសម្លៀកបំពាក់មានចំណែក៦៧,៨%ក្នុងវិនិយោគសរុបដោយមានកំណើន ១៣៧,៤%។ វិនិយោគខាងសេវាកម្ម ធ្លាក់ចុះ ៣៤,១% ធៀបនឹងឆ្នាំមុន មកត្រឹម ៧២២,៦លានដុល្លារ ក្នុងនេះវិនិយោគផ្នែកសណ្ឋាគារ និងទេសចរណ៍ (ស្មើនឹង ៣៥,៦% នៃវិនិយោគសរុប) ធ្លាក់ចុះ ៧៦,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ប៉ុន្តែចំនួនភ្ញៀវទេសចរមកទស្សនាកម្ពុជា កើន ១៣,៩%។ នៅត្រីមាសទី១ ឆ្នាំ២០១១ វិស័យសំណង់បន្តរើបឡើងវិញ ដោយមានតម្លៃអនុមតិវិនិយោគសរុបកើន ៦៣៦,៩% ធៀបនឹងឆ្នាំមុន។

នៅត្រីមាសទី១ នេះដែរ ការនាំចេញបន្តមានដំណើរការរស់រវើក ដោយមានកំណើន ២៥,៨%។ ការនាំចេញសម្លៀកបំពាក់ រួមចំណែក ៨៣,៦% នៃតម្លៃនាំចេញសរុប ឬ កើន ២១,៦%។ សហរដ្ឋអាមេរិក នៅតែជាគោលដៅនាំចេញចម្បងរបស់កម្ពុជា ដោយមានចំណែក ៤៦,១% នៃការនាំចេញសម្លៀកបំពាក់សរុប ហើយបន្ទាប់មក គឺ សហភាពអឺរ៉ុប (៣០,៦%) ដៃគូពាណិជ្ជកម្មដទៃទៀត (១៧,៩%) ជប៉ុន (៤,៦%) និង អាស៊ាន (០,៦%)។ ទោះយ៉ាងនេះក្តី កំណើនពីមួយឆ្នាំទៅមួយឆ្នាំ នៃការនាំចេញសម្លៀកបំពាក់ទៅសហរដ្ឋអាមេរិក (៦,២%) មានទំហំតូចជាងកំណើនការនាំចេញទៅសហភាពអឺរ៉ុប (៥១,៥%) អាស៊ាន (៦៨,៤%) និង ជប៉ុន (៤៦,១%)។ នៅត្រីមាសនេះដែរ ការនាំចេញផលិតផលកសិកម្ម កើន ៨,៨% ក្នុងនេះ ការនាំចេញឈើ កើន ៤៣,៥% ហើយការនាំចេញផលិតផល "ផ្សេងៗ" កើន ៧៨,៦%។ ការនាំចេញកៅស៊ូធ្លាក់ចុះ ១៩,២% ហើយការនាំចេញត្រី ធ្លាក់ចុះ ១៦,៦%។ ការនាំចូលសរុប កើន ១១,១% ដល់ ៨០៩,៩លានដុល្លារ ក្នុងនេះ ការនាំចូលសាំង កើន ៨,៧% ម៉ាស៊ូត កើន ១៧,២% និង សម្ភារៈសំណង់ កើន ១,៦%។ អតិរេកពាណិជ្ជកម្ម កើន ៦២,៩% ធៀបនឹងមួយឆ្នាំមុន ដល់ ៤៧០,២លានដុល្លារ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៤ ឆ្នាំ២០១១ ចំណូលសរុបរបស់រដ្ឋាភិបាល កើន ១៧,៦% ធៀបនឹងត្រីមាសមុន ឬ ៦,១% ធៀបនឹងមួយឆ្នាំមុន ដល់ ១៧៧៦,៦ពាន់លានរៀល ក្នុងនោះ ចំណូលចរន្តរួមចំណែក ៩៧,៩%។ ចំណូលចរន្តសរុប កើន ១៦,២% ធៀបនឹងត្រីមាសមុន ឬ ១០,៨% ធៀបនឹងមួយឆ្នាំមុន ដល់ ១៧៤០,១ពាន់លានរៀល។ ចំណូលពន្ធសរុប (ស្មើនឹង ៨៣,៦% នៃចំណូលចរន្ត) កើន ១៨,៣% ធៀបនឹងមួយឆ្នាំមុន ដល់ ១៤៥៤,៣ពាន់លានរៀល។ ចំណូលមិនមែនពន្ធ (ស្មើនឹង ១៦,៤% នៃចំណូលចរន្ត) ធ្លាក់ចុះ ១៦,២% មកត្រឹម ២៨៥,៨ពាន់លានរៀល។ នៅត្រីមាសនេះដែរ ចំណាយសរុប កើន ៦០,១% ធៀបនឹងមួយឆ្នាំមុន ដល់ ៣១១៥ពាន់លានរៀល។ ចំណាយមូលធន (៤៦,៤% នៃចំណាយសរុប) កើន ១១៣,៨% ធៀបនឹងមួយឆ្នាំមុន ដល់ ១៤៤៤,៩ពាន់លានរៀល ហើយចំណាយចរន្ត (៥៣,៦% នៃចំណាយសរុប) កើន ៣១,៥% ដល់ ១៦៧០,២ពាន់លានរៀល។ ចំណាយលើបៀវត្សរ៍ (៣៦,៤% នៃចំណាយចរន្តសរុប) កើន ៧,២% ធៀបនឹងមួយឆ្នាំមុន។ ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច កើន ១១០,៦% ដល់ ៤៨៧,៣ពាន់លានរៀល។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី១ ឆ្នាំ២០១២ អតិផរណាថ្លៃទំនិញគ្រប់មុខនៅទីក្រុងភ្នំពេញ កើនដល់ ៥,៥% ធៀបនឹង ៣,៦% នៅត្រីមាសទី១ ឆ្នាំមុន។ ថ្លៃស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើន ៦,៩% ធៀបនឹង ៣,៩% កាលពីមួយឆ្នាំមុន ហើយថ្លៃដឹកជញ្ជូន កើន ៧,៨% ធៀបនឹង ៥,០% កាលពីឆ្នាំមុន។ នៅត្រីមាសទី១ នេះដែរ ប្រាក់រៀល ធ្លាក់ថ្លៃ ០,១% ទល់នឹងប្រាក់ដុល្លារ ប៉ុន្តែឡើងថ្លៃ ១,៨% ទល់នឹងប្រាក់បាតថៃ និង ៣% ទល់នឹងប្រាក់ដុងវៀតណាម។ ប្រេងម៉ាស៊ូត ឡើងថ្លៃ ១៥,៦% ធៀបនឹងមួយឆ្នាំមុន ដល់ ៥១២០,២រៀល/លីត្រ ហើយសាំង ឡើងថ្លៃ ១៣,៦% ដល់ ៥៣៩៥,៨រៀល/លីត្រ។

## ការវិវត្តរូបិយវត្ថុ

នៅត្រីមាសទី៤ ឆ្នាំ២០១១ ទ្រព្យសកម្មបរទេសសុទ្ធ កើន ១,១% ធៀបនឹងត្រីមាសមុន (៧,២% ធៀបនឹងមួយឆ្នាំមុន) ដល់ ១៧.៨៩៣,៩ពាន់លានរៀល ហើយទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើន ១៦,១% (១០៧,៣% ធៀបនឹងមួយឆ្នាំមុន)។ ឥណទានដល់វិស័យឯកជន កើន ៧,១% (៣១,៦% ធៀបនឹងមួយឆ្នាំមុន) ដល់ ១៧.៥៥២,៨ពាន់លានរៀល ដែលជាសញ្ញារើបឡើងវិញនៃការផ្តល់កម្ចីឲ្យវិស័យឯកជន និងឱកាសអាជីវកម្មថ្មីៗ។

---

១ អត្ថបទនេះ រៀបរៀងដោយលោករ័ត្ន វឌ្ឍនា អ្នកស្រាវជ្រាវកញ្ញា អ៊ួនរិមល និង លោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

## ស្ថានភាពក្រីក្រ

អង្កេតប្រចាំត្រីមាសជាទៀងទាត់របស់វិទ្យាស្ថាន CDRI កាលពីខែឧសភា ២០១២ បានរកឃើញថា ប្រាក់ចំណូលប្រចាំថ្ងៃរបស់ពលករងាយរងគ្រោះស្ទើរតែគ្រប់ក្រុម បានកើនឡើង បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ក្រុមទាំងនោះមានជាអាទិ៍ អ្នកធាក់ស៊ីក្លូ អ្នកលីសែង អ្នកស៊ីឈ្នួលធ្វើស្រែ កម្មកររោងចក្រកាត់ដេរ អ្នករត់ម៉ូតូឌុប កម្មករសំណង់មានជំនាញ និងកម្មករសំណង់គ្មានជំនាញ ហើយក្នុងនោះ ក្រុមអ្នកធាក់ស៊ីក្លូ អ្នកលីសែង និងអ្នករត់ម៉ូតូឌុប មានប្រាក់ចំណូលកើនខ្លាំងជាងគេ។

ចំណូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ ស្ទុះឡើង ២៩% ដល់ ១០.៦៨៦រៀល នៅខែឧសភា។ ចំណាយប្រើប្រាស់ប្រចាំថ្ងៃរបស់ពួកគេ កើន ១៥% លើសពី កម្រិត ៤៥៤៣រៀល កាលពីខែឧសភា ២០១១។ ក្នុងចំណោមអ្នកធាក់ស៊ីក្លូឆ្លើយសម្ភាសន៍ មានតែ ១២% ប៉ុណ្ណោះ ដែលមានស៊ីក្លូផ្ទាល់ខ្លួន ចំណែកឯអ្នកផ្សេងទៀតត្រូវជួលពីគេ។ ចំនួនអ្នកធាក់ស៊ីក្លូគេងតាមចិញ្ចើមថ្នល់ ឬនៅក្នុងវត្ត ធ្លាក់ចុះមកត្រឹម ៦៥% ធៀបនឹង ៦៨% កាលពីខែឧសភា ឆ្នាំ២០១១។ ជាមធ្យមពួកគេប្រកបរបរជាអ្នកធាក់ស៊ីក្លូ បាន ៩ឆ្នាំហើយ។

ចំណូលប្រចាំថ្ងៃរបស់អ្នកលីសែង កើន ២៩% ធៀបនឹងមួយឆ្នាំមុន ដល់ ១២.៧១៣រៀល ហើយចំណាយរបស់ពួកគេកើន ១៥% ពី ៥៤៥៥រៀល ដល់ ៦២៥៥រៀល/ថ្ងៃ។ អ្នកលីសែងផ្ដល់សម្ភាសន៍ ៩២% ប្រាប់ថា ពួកគេជួលផ្ទះមួយនៅរួមគ្នា ១០នាក់ជាមធ្យម ហើយ ៥% ប្រាប់ថា ស្នាក់នៅតាមចិញ្ចើមថ្នល់ ឬនៅវត្ត និង ៣% ទៀត ប្រាប់ថា នៅតាមផ្ទះសាច់ញាតិ។ ម៉្យាងទៀតមាន ៧២% ប្រាប់ថា ស្ថានភាពគ្រួសាររបស់ពួកគេបានប្រសើរជាងមុន ចាប់តាំងពីពេលប្រកបរបរនេះ ហើយ ២០% ទៀត ប្រាប់ថា ស្ថានភាពគ្រួសារនៅដដែល រីឯ ៨% ទៀតប្រាប់ថា កាន់តែយ៉ាប់ជាងមុន។

ចំណូលប្រចាំថ្ងៃរបស់អ្នករត់ម៉ូតូឌុប កើន ២៨% ធៀបនឹងមួយឆ្នាំមុន ដល់ ១៣.៦១៦រៀល។ ក្នុងចំណោមអ្នករត់ ម៉ូតូឌុបផ្ដល់សម្ភាសន៍ មាន ៩២% ជាអ្នករកចំណូលចម្បងក្នុងគ្រួសារដែលមានសមាជិកជាមធ្យម ៥នាក់។ ពួកគេ ៤៨% បានចូលរៀនថ្នាក់ បឋមសិក្សា ៤២% បានចូលរៀនអនុវិទ្យាល័យ ៨% បានចូលរៀនវិទ្យាល័យ និង ២% មិនបានចូលរៀនទេ។

ចំពោះកម្មករសំណង់គ្មានជំនាញវិញ ប្រាក់ចំណូលពិតប្រចាំថ្ងៃ កើន ២៣% ពីកម្រិត ៩៤១៥រៀល កាលពីមួយឆ្នាំមុន។ ចំណូលរបស់កម្មករសំណង់មានជំនាញ កើនតែ ៣,៩% ប៉ុណ្ណោះ ពីកម្រិត ១២.៣៦៨រៀល កាលពីមួយឆ្នាំមុន។ កម្មករសំណង់គ្មានជំនាញ ៨៥% ជួលផ្ទះគេនៅ ក្នុងពេលធ្វើការនៅទីក្រុងភ្នំពេញ រីឯ ៨៨% នៃកម្មករសំណង់មានជំនាញ បានស្នាក់នៅក្នុងការដ្ឋានសំណង់។ មានតែ ១០% នៃកម្មករសំណង់មាន ជំនាញប៉ុណ្ណោះ ដែលបានដឹងពីវត្តមានសមាគមកម្មករសំណង់ ប៉ុន្តែគ្មានពួកគាត់ណាម្នាក់បានចូលជាសមាជិកទេ។

អ្នកលក់បន្លែតូចតាចមានចំណូលប្រចាំថ្ងៃកើនឡើង១៥%។ ពួកគាត់ភាគច្រើន ចំណាយពេលច្រើននៅក្នុងផ្សារ គឺជាមធ្យមប្រហែល ៧ម៉ោង/ថ្ងៃ ព្រមទាំងត្រូវក្រោកពីម៉ោង ៣ ទៀបភ្លឺ ដើម្បីទិញបន្លែទុកលក់។ ពួកគាត់ត្រូវការមូលធនប្រហែល ៧០.០០០រៀល/ថ្ងៃ ដើម្បីដំណើរការអាជីវកម្ម ប៉ុន្តែមានអ្នកឆ្លើយសម្ភាសន៍ ៥៨% ប្រាប់ថា ចំនួននេះមិនគ្រប់គ្រាន់ទេ។ មានអ្នកលក់បន្លែតូចតាចតែ ២,៥% ប៉ុណ្ណោះ ដែលជាបុរស។

ចំណូលប្រចាំថ្ងៃរបស់អ្នកស៊ីឈ្នួលធ្វើស្រែ កើន ៧,៥% ដល់ ៦៤៣១រៀល ប៉ុន្តែចំណាយប្រចាំថ្ងៃថយចុះ ០,២% មកត្រឹម ២០៨៣រៀល។ ពួកគេ ៥០% ពុំមានដីធ្លីទេ ៤៥% មានដីតិចជាងមួយហិកតា ហើយ ៥% មានដីមួយហិកតា។ ៥៥% នៃអ្នកស៊ីឈ្នួលធ្វើស្រែដែលបានឆ្លើយសម្ភាសន៍ គិតថា ចំណូលរបស់ខ្លួន បានត្រឹមតែសម្រាប់ចិញ្ចឹមគ្រួសារប៉ុណ្ណោះ រីឯ ៤៥% ទៀត គិតថា វាមិនគ្រប់គ្រាន់ទេ ទោះបីគាត់ខំធ្វើការដល់ទៅ ៨ម៉ោង/ថ្ងៃ ជាមធ្យមក្ដី។

ចំណូលប្រចាំថ្ងៃរបស់កម្មកររោងចក្រកាត់ដេរ កើន ៥,៦% ធៀបនឹងឆ្នាំមុន ដល់ ៨៣៩១រៀល ហើយក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ មាន ៩៨% ជានារី។ ស្របតាមកំណើនសកម្មភាពក្នុងឧស្សាហកម្មកាត់ដេរ មានអ្នកផ្ដល់សម្ភាសន៍ ៧២% ប្រាប់ថា ខ្លួនបានធ្វើការថែមម៉ោងជារឿយៗ ១៦% បានធ្វើការថែមម៉ោងម្ដងម្កាល និង ១២% មិនដែលបានធ្វើការថែមម៉ោងទេ។ ម៉្យាងទៀតមានអ្នកផ្ដល់សម្ភាសន៍ ៥៥% ប្រាប់ថា ចង់ប្ដូរការងារ ព្រោះនៅរោងចក្រមិនអាចរកប្រាក់សន្សំសម្រាប់ពេលអនាគតទេ។

ចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់ អ្នករើសអេតចាយ រួមចុះ ៤,៦% ពី ៨៦៦១រៀល ក្នុងខែឧសភា ឆ្នាំ២០១១ ដោយសារថ្លៃ និងប្រភពរបស់អេតចាយ ថយចុះ។ ក្នុងចំណោមអ្នករើសអេតចាយឆ្លើយសម្ភាសន៍ មាន ៧៣% មកពីខេត្តព្រៃវែង ១២% មកពី ស្វាយរៀង ១០% មកពី តាកែវ ២,៥% មកពីពោធិ៍សាត់ និង ២,៥% មកពី កណ្ដាល។ ពួកគេ ៨០% មកភ្នំពេញជាមួយនឹងគ្រួសារ រីឯ ២០% មកម្នាក់ឯង។


**Cambodia Development Review—2012 Subscription Rates**

**Domestic Subscription (Individual)**

❐ English edition ($14) ❐ Khmer edition (5,000 riels) Payment by ❐ cash or ❐ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❐ English edition ($60 for five copies) ❐ Khmer edition (20,000 riels for five copies) Payment by ❐ cash or ❐ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International Subscription (Individual)**

❐ Thailand, Laos, Vietnam ❐ English edition ($25)* ❐ Khmer edition ($15)*
❐ Asia and Europe ❐ English edition ($30)* ❐ Khmer edition ($20)*
❐ Americas and Africa ❐ English edition ($35)* ❐ Khmer edition ($25)*

**Details for payment by telegraphic transfer**

Account Name: CDRI
Account Number: 133451
Bank Name: ANZ Royal Bank (Cambodia) Ltd
Bank Address: Phnom Penh, Cambodia Head Office
Swift Code: ANZBKHPP
Receiver Correspondent Bank: JP Morgan Chase Manhattan Bank, N.A., New York, USA
Swift Code: CHASUS33

Title: ❐Mr ❐Ms ❐Dr ❐Other ..........
First name: .......... Last name: .......... Position: ..........
Organisation / Company: ..........
Address (CCC Box if applicable): ..........
City / Province: .......... Country: ..........
Telephone: .......... Fax: ..........
e-mail: .......... ❐ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Department at CDRI if your contact details change.

## តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៥-១១*

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 Q2 | Q3 | Q4 | 2011 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | |
| កសិកម្ម | 26.8 | 498.0 | 135.6 | 92.0 | 615.0 | 41.4 | 278.0 | 36.7 | 4.1 | 156.4 | 123.9 | 440.6 |
| ឧស្សាហកម្ម | 914.6 | 365.3 | 709.1 | 724.9 | 818.5 | 54.5 | 44.3 | 87.7 | 67.1 | 257.1 | 2361.0 | 174.9 |
| *កាត់ដេរ* | *174.4* | *89.4* | *170.7* | *142.8* | *90.1* | *21.3* | *29.3* | *50.0* | *57.1* | *108.4* | *109.7* | *118.7* |
| សេវាកម្ម | 155.5 | 2939.1 | 1742.5 | 10,003.2 | 4432.0 | 121.6 | 0 | 1096.2 | 209.5 | 2229.2 | 264.1 | 722.6 |
| *សណ្ឋាគារ និងទេសចរណ៍* | *102.6* | *345.0* | *1048.3* | *8758.1* | *3980.1* | *14.0* | *0* | *1087.4* | *107.9* | *2221.9* | *264.1* | *257.0* |
| សរុប | 1096.9 | 3802.4 | 2587.2 | 10,570.9 | 5865.5 | 217.5 | 322.3 | 1220.6 | 280.72 | 2642.7 | 2748.9 | 1338.1 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | - | -56.8 | 48.2 | 278.8 | -77.0 | 841.4 | 4.0 | -51.3 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | 275.6 | 246.6 | -32.0 | 308.6 | -44.5 | 452.0 | -16.6 | -71.3 | -44.2 | 1115.0 | 752.9 | 9.6 |

*Including expansion project approvals. Source: Cambodian Investment Board*

## តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៥-១២

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 Q3 | Q4 | 2011 Q1 | Q2 | Q3 | Q4 | 2012 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | លានដុល្លារ | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 45.5 | 33.1 | 79.1 | 154.7 | 87.1 | 14.1 | 9.5 | 4.1 | 5.9 | 106.3 | 60.9 | 64.8 |
| ផ្ទះល្វែង | 204.2 | 213.3 | 297.2 | 221.6 | 73.3 | 25.3 | 20.3 | 16.1 | 22.8 | 90.0 | 58.5 | 60.8 |
| ផ្សេងៗ | 109.1 | 76.8 | 259.6 | 740.9 | 268.8 | 38.9 | 76.2 | 23.6 | 48.7 | 51.1 | 29.3 | 197.2 |
| សរុប | 358.8 | 323.3 | 635.8 | 1117.0 | 196.8 | 78.4 | 106.0 | 43.8 | 77.4 | 247.4 | 148.7 | 322.8 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | - | -61.2 | 35.3 | -58.7 | 76.7 | 219.7 | -39.9 | 117.1 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | 36.2 | -9.9 | 96.7 | 75.7 | -82.4 | -14.2 | 58.7 | -14.8 | -61.7 | 215.6 | 40.29 | 637.1 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ចំនួនអ្នកដំណើរមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៥-១១

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 Q2 | Q3 | Q4 | 2011 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | |
| តាមផ្លូវអាកាស | 856.5 | 1029.0 | 1296.5 | 1239.4 | 1111.7 | 260.9 | 288.3 | 383.7 | 427.4 | 286.9 | 335.3 | 430.7 |
| តាមផ្លូវគោក និងទឹក | 565.1 | 672.9 | 718.6 | 881.9 | 999.7 | 276.6 | 293.8 | 321.4 | 351.0 | 319.6 | 364.5 | 366.3 |
| សរុប | 1421.6 | 1701.9 | 2015.1 | 2121.3 | 2111.5 | 537.5 | 582.0 | 705.1 | 778.4 | 606.5 | 699.8 | 797.1 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | - | -21.4 | 8.3 | 21.2 | 10.4 | -22.1 | 15.4 | 13.9 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | 34.7 | 19.7 | 28.4 | 5.3 | 0.5 | 15.8 | 19.4 | 20.0 | 13.9 | 12.8 | 20.2 | 13.0 |

*Source: Ministry of Tourism*

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៥-១២

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 Q3 | Q4 | 2011 Q1 | Q2 | Q3 | Q4 | 2012 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | លានដុល្លារ | | | | | | |
| ការនាំចេញសរុប | 2452.4 | 2922.8 | 3161.6 | 3209.5 | 2901.6 | 1045.4 | 1070.9 | 1017.6 | 1132.1 | 1455.6 | 1324.2 | 1280.1 |
| ក្នុងនេះ៖ សម្លៀកបំពាក់ | 2352.8 | 2810.8 | 3050.2 | 3097.8 | 2565.3 | 938.3 | 942.7 | 880.5 | 964.2 | 1285.7 | 1129.2 | 1070.8 |
| *- សហរដ្ឋអាមេរិក* | 1555.6 | 1851.7 | 1959.9 | 1913.0 | 1512.6 | 531.9 | 524.8 | 464.5 | 466.7 | 619.4 | 504.7 | 493.3 |
| *- សហភាពអឺរ៉ុប* | 506.9 | 603.0 | 660.9 | 693.4 | 644.7 | 239.4 | 248.0 | 232.0 | 301.4 | 397.5 | 391.3 | 328.4 |
| *- អាស៊ាន* | 70.7 | 80.4 | 90.3 | 99.6 | 6.9 | 2.9 | 3.0 | 3.8 | 4.2 | 4.7 | 5.0 | 6.4 |
| *- ជប៉ុន* | 25.0 | 40.6 | 30.1 | 26.5 | 44.6 | 25.5 | 26.3 | 34.3 | 28.0 | 43.4 | 41.2 | 50.1 |
| *- ប្រទេសផ្សេងៗ* | 194.6 | 235.1 | 309.0 | 365.3 | 356.5 | 138.6 | 140.7 | 145.9 | 163.9 | 220.7 | 187.0 | 192.5 |
| កសិកម្ម | 61.3 | 59.7 | 55.6 | 44.6 | 73.1 | 44.9 | 72.3 | 74.0 | 167.9 | 98.9 | 92.0 | 80.5 |
| *- កៅស៊ូ* | 36.7 | 41.5 | 41.0 | 35.8 | 51.6 | 25.4 | 38.1 | 49.9 | 48.6 | 56.1 | 43.1 | 40.3 |
| *- ឈើ* | 10.3 | 8.6 | 8.7 | 3.4 | 3.5 | 8.8 | 18.7 | 6.2 | 16.8 | 16.1 | 9.7 | 8.9 |
| *- ត្រី* | 10.1 | 5.9 | 3.2 | 2.3 | 4.0 | 0.5 | 0.8 | 0.6 | 0.4 | 1.4 | 0.7 | 0.5 |
| *- ផ្សេងៗ* | 4.2 | 3.7 | 2.7 | 3.1 | 14.0 | 10.2 | 14.7 | 17.3 | 31.3 | 25.3 | 38.6 | 30.9 |
| ផ្សេងៗ | 38.3 | 52.3 | 55.8 | 67.1 | 263.2 | 62.2 | 55.9 | 63.2 | 70.8 | 71.0 | 102.9 | 128.8 |
| ការនាំចូលសរុប | 2513.0 | 512.2 | 554.8 | 1010.9 | 2239.0 | 731.3 | 677.1 | 728.7 | 918.8 | 763.1 | 877.5 | 809.9 |
| ក្នុងនេះ៖ សាំង | 40.2 | 38.8 | 58.7 | 70.1 | 91.2 | 27.6 | 30.5 | 62.0 | 76.7 | 73.8 | 81.8 | 70.7 |
| ម៉ាស៊ូត | 93.1 | 113.0 | 122.8 | 113.5 | 180.8 | 48.0 | 50.5 | 92.5 | 129.8 | 118.9 | 105.5 | 139.4 |
| សម្ភារៈសំណង់ | 134.7 | 56.5 | 69.0 | 77.8 | 49.7 | 16.7 | 13.8 | 11.8 | 12.7 | 11.6 | 12.0 | 13.5 |
| ផ្សេងៗ | 2245.0 | 303.9 | 304.3 | 749.5 | 1917.3 | 638.9 | 582.3 | 562.4 | 699.6 | 558.8 | 678.2 | 586.3 |
| ជញ្ជីងពាណិជ្ជកម្ម | -60.6 | 2410.6 | 2606.8 | 2198.6 | 662.6 | 314.1 | 393.8 | 289.0 | 213.3 | 692.5 | 446.7 | 470.2 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | 30.9 | 0.5 | -6.6 | 9.5 | 33.3 | -12.2 | -5.2 |
| ការនាំចេញសរុប | - | - | - | - | - | 27.3 | 2.4 | -5.0 | 11.3 | 28.6 | -9.0 | -3.3 |
| ការនាំចូលសរុប | - | - | - | - | - | 29.8 | -7.4 | 7.6 | 26.1 | -16.9 | 15.0 | -7.7 |
| | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 16.1 | 19.5 | 8.5 | 1.6 | -17.2 | 75.2 | 62.7 | 40.8 | 34.5 | 37.0 | 19.8 | 21.6 |
| ការនាំចេញសរុប | 16.3 | 19.2 | 8.2 | 1.5 | -9.6 | 68.5 | 63.5 | 46.7 | 37.9 | 39.2 | 23.7 | 25.8 |
| ការនាំចូលសរុប | 189.6 | -79.6 | 8.3 | 82.2 | 121.5 | 51.0 | 27.1 | 44.1 | 63.1 | 4.4 | 29.6 | 11.1 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF (web site)*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៥-១១ (ពាន់លានរៀល)

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 Q2 | Q3 | Q4 | 2011 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 2625.0 | 3259.2 | 1146.1 | 5290.0 | 4885.2 | 1341.1 | 1436.0 | 1675.0 | 1400.5 | 1564.3 | 1510.1 | 1776.6 |
| ចំណូលចរន្ត | 2474.0 | 2881.8 | 1141.6 | 5210.7 | 4855.9 | 1330.9 | 1431.2 | 1570.5 | 1378.6 | 1563.0 | 1497.6 | 1740.1 |
| ចំណូលពន្ធ | 1911.0 | 2270.9 | 965.2 | 4409.9 | 4268.0 | 1143.8 | 1225.5 | 1229.6 | 1142.3 | 1367.5 | 1313.4 | 1454.3 |
| ពន្ធក្នុងស្រុក | - | - | 661.8 | 3248.4 | 3088.6 | 890.9 | 916.9 | 905.5 | 875.6 | 1095.3 | 996.6 | 1104.1 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | 303.5 | 1161.5 | 1064.7 | 253.0 | 308.6 | 324.1 | 266.7 | 272.3 | 316.7 | 350.2 |
| ចំណូលមិនមែនពន្ធ | 563.0 | 610.9 | 176.4 | 800.8 | 702.1 | 187.1 | 205.7 | 340.9 | 236.3 | 195.5 | 184.2 | 285.8 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | 13.6 | 78.0 | 64.6 | 20.2 | 19.5 | 14.5 | 10.6 | 18.6 | 15.2 | 19.4 |
| លក់ទំនិញ និងសេវា | - | - | 124.3 | 424.7 | 408.0 | 102.9 | 127.0 | 121.7 | 130.0 | 138.9 | 144.2 | 175.6 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | 38.5 | 298.2 | 228.2 | 61.0 | 59.2 | 204.8 | 95.7 | 37.9 | 24.9 | 90.8 |
| ចំណូលជាមូលធន | 152.0 | 377.4 | 4.5 | 79.3 | 29.3 | 10.2 | 4.8 | 104.5 | 21.9 | 1.3 | 12.5 | 36.5 |
| ចំណាយសរុប | 3295.0 | 4174.7 | 1689.7 | 6297.8 | 7383.5 | 2154.8 | 2390.3 | 1945.4 | 1437.3 | 2025.2 | 2310.6 | 3115.0 |
| ចំណាយជាមូលធន | 1328.0 | 1638.1 | 807.4 | 2574.4 | 2694.9 | 913.0 | 887.0 | 675.6 | 579.8 | 721.0 | 801.2 | 1444.9 |
| ចំណាយចរន្ត | 1967.0 | 2536.8 | 882.3 | 3809.0 | 4440.0 | 1168.1 | 1503.3 | 1269.8 | 857.5 | 1304.1 | 1509.4 | 1670.2 |
| បៀវត្សរ៍ | 711.0 | 822.0 | 362.6 | 1397.0 | 2012.0 | 545.6 | 562.4 | 567.4 | 401.0 | 531.6 | 629.7 | 608.3 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | - | - | 194.2 | 927.1 | 871.4 | 253.2 | 401.5 | 231.4 | 257.4 | 450.9 | 323.3 | 487.3 |
| ចំណាយចរន្តផ្សេងទៀត | - | - | 325.5 | 1384.9 | 1556.6 | 369.3 | 539.4 | 471.0 | 199.1 | 321.7 | 556.5 | 574.6 |
| សមតុល្យជាទូទៅ | -706.0 | -915.6 | -543.6 | -1007.8 | -248.7 | -813.7 | -954.2 | -207.3 | -426.6 | -242.9 | -579.4 | -22.5 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1127.0 | 1360.7 | 741.5 | 2055.1 | -2498.3 | 746.0 | 409.1 | 419.3 | -36.8 | -460.9 | -800.5 | -1338.4 |
| ហិរញ្ញប្បទានក្នុងស្រុក | -396.0 | -445.1 | -185.8 | -127 | 1746.1 | 194.1 | 343.3 | -21.6 | 544.4 | 576.9 | 272.9 | 985.0 |

*Source: MEF website.*

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៥-១២

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 Q3 | Q4 | 2011 Q1 | Q2 | Q3 | Q4 | 2012 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 5.8 | 4.7 | 5.8 | 19.7 | -0.7 | 1.8 | 3.3 | 3.6 | 6.3 | 6.7 | 4.9 | 5.5 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 8.6 | 6.4 | 9.9 | 33.1 | -0.3 | 1.9 | 4.1 | 3.9 | 7.6 | 8.2 | 6.2 | 6.9 |
| - ដឹកជញ្ជូន | 11.4 | 9.1 | 5.8 | 19.4 | -10.7 | 3.2 | 3.1 | 5.0 | 7.3 | 8.8 | 6.3 | 7.8 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4119.7 | 4119.0 | 4062.7 | 4058.2 | 4140.5 | 4236.7 | 4122.6 | 4041.9 | 4044.9 | 4095.7 | 4071.9 | 4046.0 |
| រៀលក្នុង ១ បាតថៃ | 102.6 | 108.7 | 122.8 | 123.5 | 121.1 | 138.3 | 137.3 | 132.7 | 133.8 | 135.2 | 131.1 | 130.2 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.8 | 25.1 | 25.0 | 24.8 | 23.4 | 21.4 | 21.1 | 19.9 | 19.6 | 19.8 | 19.4 | 19.3 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 54.0 | 70.6 | 83.2 | 105.9 | 113.1 | 147.8 | 165.7 | 147.9 | 181.5 | 204.6 | 203.8 | 204.1 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 2633.0 | 3140.0 | 3262.3 | 4555.2 | 3170.9 | 3936.6 | 4066.1 | 4427.2 | 4784.6 | 4924.5 | 4908.3 | 5120.2 |
| ថ្លៃសាំង (រៀល/លីត្រ) | 3442.0 | 4004.0 | 4005.0 | 4750.8 | 3593.1 | 4415.5 | 4535.2 | 4750.1 | 5065.5 | 5248.4 | 5113.8 | 5395.8 |

*Sources: NIS, NBC and CDRI*

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៥-១១ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 Q2 | Q3 | Q4 | 2011 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 5475.0 | 7224.0 | 10,735.0 | 10,345.0 | 14,655.0 | 12,610.9 | 16,903.0 | 16,697.9 | 17,079.1 | 18099.9 | 17,695.2 | 17,893.9 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -450.0 | -282.0 | 576.0 | 1513.3 | 1573.0 | 1785.3 | 1984.8 | 2778.9 | 3199.2 | 3907.7 | 4961.6 | 5760.8 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -421.0 | -953.0 | -1816.0 | -2987.0 | -2252.0 | -2362.7 | -2120.4 | -2126.6 | -2252.7 | -2184.2 | -1925.8 | -2123.1 |
| ឥណទានដល់ផ្នែកឯកជន | 2394.0 | 3630.0 | 6386.0 | 9894.0 | 10,532.0 | 11,859.1 | 12,479.8 | 13,331.2 | 13,909.0 | 15,290.6 | 16,385.7 | 17,552.8 |
| រូបិយវត្ថុទូទៅ M2 | 5025.0 | 6942.0 | 11,311.0 | 11,858.0 | 16,228.0 | 18,267.1 | 18,887.8 | 19,476.8 | 20,278.3 | 22,007.6 | 22,656.8 | 23,654.7 |
| រូបិយវត្ថុ M1 | 1323.0 | 1658.0 | 2052.0 | 2399.0 | 3120.0 | 3115.1 | 3061.7 | 3220.9 | 3497.2 | 3539.8 | 3681.3 | 3956.2 |
| រូបិយវត្ថុផ្សេងៗ | 3702.0 | 5285.0 | 9259.0 | 9459.0 | 13,108.0 | 15,152.0 | 15,826.1 | 16,255.9 | 16,781.1 | 18,467.8 | 18,975.5 | 19,698.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 16.1 | 38.1 | 62.9 | 4.8 | 36.9 | 31.8 | 26.7 | 20.0 | 17.7 | 20.5 | 20.0 | 21.5 |
| រូបិយវត្ថុ M1 | 14.7 | 25.3 | 23.8 | 16.9 | 30.1 | 15.6 | 10.4 | 3.2 | 11.1 | 13.6 | 20.2 | 22.8 |
| រូបិយវត្ថុផ្សេងៗ | 16.6 | 42.8 | 75.2 | 2.2 | 38.6 | 35.7 | 30.4 | 24.0 | 19.1 | 21.9 | 19.9 | 21.2 |

*Source: National Bank of Cambodia*

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលកររងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2007 | 2008 | 2009 | 2010 | 2011 ឧសភា | សីហា | វិច្ឆិកា | 2012 កុម្ភៈ | ឧសភា | 2011 វិច្ឆិកា | 2012 កុម្ភៈ | ឧសភា |
| អ្នកធាក់ស៊ីក្លូ | 8075 | 12,628 | 8091 | 9055 | 8292 | 9783 | 9348 | 9380 | 10686 | 6.7 | -11.8 | 28.9 |
| អ្នកលីសែង | 8588 | 9005 | 9549 | 9964 | 9861 | 10,465 | 11,554 | 10,804 | 12,713 | 16.0 | -3.4 | 28.9 |
| អ្នកលក់បន្លែតូចតាច | 8220 | 9926 | 8273 | 8266 | 8599 | 8405 | 7116 | 12292 | 9901 | -19.3 | 34.4 | 15.1 |
| អ្នករើសអេតចាយ | 5422 | 4652 | 5857 | 6698 | 8661 | 7557 | 10,347 | 7986 | 8266 | 56.1 | 15.2 | -4.6 |
| អ្នកបម្រើតុភោជនីយដ្ឋាន* | 4482 | 4327 | 4646 | 5607 | 6066 | 5410 | 6271 | 6179 | 6261 | 15.1 | 0.4 | 3.2 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5516 | 8697 | 6197 | 5691 | 5984 | 7345 | 4577 | 4690 | 6431 | -6.8 | -2.4 | 7.5 |
| កម្មកររោងចក្រកាត់ដេរ | 7568 | 6554 | 7085 | 7746 | 7950 | 8687 | 8620 | 8555 | 8391 | 8.5 | 2.9 | 5.6 |
| អ្នករត់ម៉ូតូឌុប | 10,634 | 15,691 | 10,685 | 10,623 | 10,630 | 11,146 | 12,971 | 12,256 | 13,616 | 26.2 | 7.1 | 28.1 |
| កម្មករសំណង់គ្មានជំនាញ | 6155 | 8779 | 8343 | 8790 | 9415 | 10,526 | 9914 | 10,658 | 11,589 | 2.9 | -5.6 | 23.1 |
| កម្មករសំណង់មានជំនាញ | 11,154 | 12,710 | 12,487 | 11,952 | 12,368 | 12,676 | 15,013 | 13,824 | 12,847 | 23.9 | 10.7 | 3.9 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers, unskilled construction workers and skilled construction workers began in February 2000.*
*Source: CDRI*

*តពីទំព័រ ១៤* **អភិបាលកិច្ចទីប្រជុំជន...**

2012) ឬការប្រើប្រាស់សិទ្ធិអំណាច (Moncrieff 2001)។ យ៉ាងហោចណាស់មានកត្តាបី ដែលប្រជាជនគួរចាប់ឲ្យមន្ត្រីជាប់ឆ្នោតមានគណនេយ្យភាព លើសកម្មភាពផ្សេងៗរបស់ខ្លួនៈ (១) ប្រជាជនអាចប្រើប្រាស់សំឡេងឆ្នោតយ៉ាងសក្តិសិទ្ធិ ដើម្បីផ្តល់រង្វាន់ ឬដាក់ទណ្ឌកម្ម ចំពោះការអនុវត្តជាទូទៅ ឬជាក់លាក់របស់មន្ត្រី (២) ប្រជាពលរដ្ឋអាចបង្កើតឲ្យមានចម្លើយតបចំពោះតម្រូវការរួមរបស់ខ្លួន ពីសំណាក់អាជ្ញាធរមូលដ្ឋាន និង (៣) ប្រជាពលរដ្ឋ អាចមានទំនុកចិត្តបានថាខ្លួនទទួលបានចំណាត់ការប្រកបដោយយុត្តិធម៌ និងសមធម៌ ពីសំណាក់ទីភ្នាក់ងារសាធារណៈនៅកម្រិតមូលដ្ឋាន (Grindle 2011)។ នៅក្នុងវាក្យស័ព្ទនៃវិមជ្ឈការបែបប្រជាធិបតេយ្យនៅកម្ពុជា ពាក្យនេះសំដៅដល់ គណនេយ្យភាពបីប្រភេទខុសៗគ្នាគឺៈ គណនេយ្យភាពពីក្រោមទៅលើ តាមខ្សែបណ្តោយ និង ពីលើចុះក្រោម (Hughes & Devas 2007; Kim 2012; Kim & Ojendal 2007)។

ការឆ្លើយតប សំដៅដល់សមត្ថភាពរបស់អាជ្ញាធរក្នុងការបំពេញតាមការសន្យារបស់ខ្លួន (មិនមែនគ្រាន់តែបង្កើនការរំពឹងទុករបស់ប្រជាពលរដ្ឋអ្នកបោះឆ្នោតនោះទេ)។ ការឆ្លើយតបជាលទ្ធភាពក្នុងការបំពេញតាមសំណើរបស់ប្រជាជន ដូចជាលទ្ធផលជាក់ស្តែង និងសេវាកម្មនៅមូលដ្ឋានជាដើម។ ដូច្នេះវាជាការទទួលខុសត្រូវចំពោះផលប្រយោជន៍ក្នុងមូលដ្ឋាន ដែលនៅកម្ពុជា វាតម្រូវឲ្យមានការយល់ដឹងពីស្ថានភាពនៅមូលដ្ឋាន (Kim 2012)។ Manor បានកំណត់ការអនុវត្តទំនួលខុសត្រូវជាបីយ៉ាងៈ (១)ល្បឿននៃការឆ្លើយតបតាមធម្មតាតែងកើនឡើង ព្រោះក្រុមប្រឹក្សាជាប់ឆ្នោតនៅកម្រិតទាប គឺមានអំណាចឯករាជ្យគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាយ៉ាងលឿន ក៏ដូចជាសំណូមពរផ្សេងៗរបស់ប្រជាជន (២) បរិមាណនៃការឆ្លើយតប ក៏តែងកើនឡើងដែរ ព្រោះក្រុមប្រឹក្សាទំនងផ្តោតលើគម្រោងតូចៗ ច្រើនជាងគម្រោងធំៗ និង (៣) គុណភាពនៃការឆ្លើយតប តែងល្អប្រសើរឡើង ប្រសិនបើគុណភាពនោះត្រូវវាស់វែងទៅតាមកម្រិតស៊ីគ្នាល្អរវាងចម្លើយតបរបស់រដ្ឋាភិបាល និងតំរូវការរបស់ប្រជាជន។

## សន្និដ្ឋាន

អត្ថបទនេះរកឃើញថា ភាគច្រើន អភិបាលកិច្ចតំបន់ទីក្រុងមិនសូវទទួលបានការយកចិត្តទុកដាក់ទេ នៅក្នុងក្របខ័ណ្ឌវិមជ្ឈការបែបប្រជាធិបតេយ្យជារួមនៅកម្ពុជា ទាំងខាងផ្នែកគោលនយោបាយ និងផ្នែកស្រាវជ្រាវ។ ដោយសារនគរូបនីយកម្មកម្ពុជាកំពុងលូតលាស់ទៅមុខយ៉ាងលឿន ដូច្នេះគួរមានជាបន្ទាន់នូវគោលនយោបាយវិមជ្ឈការមួយដែលបានគិតគូរល្អដល់ ភាពខុសប្លែកគ្នាខាងទីតាំងភូមិសាស្រ្ត លំហកន្លែង និងលក្ខខណ្ឌសេដ្ឋកិច្ច-សង្គមកិច្ច។ នគរូបនីយកម្មនៅកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយ ហេតុនេះនៅមានលទ្ធភាពច្រើន ដើម្បីធានាឲ្យអភិបាលកិច្ចទីប្រជុំជនទទួលបានជោគជ័យ។ ដូច្នេះឥឡូវនេះ គេគួរបង្កើនការយកចិត្តទុកដាក់លើ ការបណ្តុះបណ្តាល និងបំពាក់បំប៉នអាជ្ញាធរមូលដ្ឋាននៅតំបន់ទីប្រជុំជនឲ្យបានកាន់តែប្រសើរ ព្រមទាំងផ្តល់ឧបករណ៍ និងធនធានឲ្យបានសមស្រប ដើម្បីដោះស្រាយបញ្ហាដែល តែងកើតមាននៅក្នុងទីក្រុងធំៗ ដូចជា ការស្ទះចរាចរណ៍ ការបំពុលបរិស្ថាន និងសំណង់អនាធិបតេយ្យជាដើម។ ដោយមានការយកចិត្តទុកដាក់ពីបញ្ហាលំហនិងទីតាំង គម្រោងអភិបាលកិច្ចតំបន់ទីប្រជុំជននេះ គឺជាគំនិតផ្តួចផ្តើមតូចមួយ ដើម្បីរួមចំណែកបង្កើនចំណេះដឹង និងផ្តល់ព័ត៌មានដល់ការជជែកវែកញែកអំពី កំណែទម្រង់វិមជ្ឈការនៅកម្ពុជា ទាក់ទងនឹងភាពបន្ទាន់ ភាពសម្បូរបែប និង ចម្លើយតបខាងគោលនយោបាយ។

## ឯកសារយោង


Benghong, S.K. (2006), “Cambodia” in B. Roberts & T. Kanaley (eds.), *Urbanisation and Sustainability in Asia: Case Studies of Good Practice* (Manila: Asia Development Bank) pp.71-100

Blunt, P., & Turner, M. (2005),”Decentralization, Democracy and Development in a Post-Conflict Society: Commune Councils in Cambodia”, *Public Administration and Development*, Vol. 25, pp. 75-87

Chheat S., Lun P., Kim S., Heng S., Sok S. & Chhoun N. (2011), *A Baseline Survey of Sub-national Government: Towards a Better Understanding of Decentralisation and Deconcentration in Cambodia,* Speical Issue 12 (Phnom Penh: CDRI)

Devas, N. (2004), *Urban Governance, Voice and Poverty in the Developing World* (London: Earthscan)

Grindle, M. S. (2011, *Sanctions, Benefits and Rights: Three Faces of Accountability,* Working Paper 4 (Visby, Sweden:ICLD)

Gutkind, P.C. (1974), *Urban Anthropology: Perspectives on ‘Third World’ Urbanization and Urbanism* (New York: Barnes and Noble Books)

Hughes, C. & N. Devas (2007), *Review of the Draft Law on Administration and Management of the Capital, Province, Municipality, District, Khan* (unpublished)

Kaufman, D., F. Leautier & M. Mastruzzi (2005), *Governance and the City: An Empirical Exploration into Global Determinants of Urban Governance* , Policy Research Working Paper 3712 (Washington, DC: World Bank Institute)

Kim, N. & R. Henke (2005), *Commune Councils in Cambodia: A National Survey on their Functions and Performance, with a Special Focus on Conflict Resolution* (Phnom Penh: Asia Foundation)


ឯកសារយោងមួយចំនួនទៀត មានចុះនៅក្នុងអត្ថបទជាភាសាអង់គ្លេស

*តពីទំព័រ ២៤* **ព័ត៌មានថ្មីៗ...**

(ERIA) សម្រាប់ការសិក្សារបស់ ERIA ស្ដីពីការឈានទៅកាន់គំរូអភិវឌ្ឍន៍ថ្មីមួយនៃអាស៊ីបូព៌ា៖ តួនាទីនៃគោលនយោបាយក្នុងស្រុក និងសហប្រតិបត្តិការក្នុងតំបន់។ ក្នុងកិច្ចប្រជុំនោះ វិទ្យាស្ថាន CDRI បានរួមចំណែកក្នុងប្រធានបទ ការស្វែងរកវិធីសាស្ត្រអភិវឌ្ឍន៍ថ្មី៖ តើប្រទេសតូចៗដែលមានការអភិវឌ្ឍសេដ្ឋកិច្ចតិចក្នុងអាស៊ាន ត្រូវការអ្វីពីវិធីសាស្ត្រថ្មី? ហេតុអ្វី?

## ការស្រាវជ្រាវ

### កម្មវិធីអភិបាលកិច្ចប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ (DGPSR)

កម្មវិធីនេះ កំពុងអនុវត្តគម្រោងស្រាវជ្រាវ ៧ ដែលទទួលបានហិរញ្ញប្បទានចម្បងពី Sida។ កម្រងសំណួរពាក់កណ្ដាលរៀបរយសម្រាប់ការសិក្សាពី "ការផ្លាស់ប្ដូរសង្គមឆ្លងតាមការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (D&D)៖ ផលប៉ះពាល់នៃទំនាក់ទំនងជាបដិការរវាងរដ្ឋនិងសង្គមនៅកម្ពុជា"បានកែសម្រួលរួចហើយ។ អត្ថបទលើគម្រោង "អភិបាលកិច្ចតំបន់ទីក្រុងនៅកម្ពុជាក្រោយធ្វើវិមជ្ឈការ" បានបញ្ចប់ និងធ្វើជាបទបង្ហាញក្នុងវិទ្យាស្ថាន CDRI ដើម្បីសុំយោបល់កែលំអ និងបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា។ សម្ភាសន៍ជាដំបូងៗ បានអនុវត្តឡើងនៅកម្រិតជាតិ និងកម្រិតមូលដ្ឋាន សម្រាប់ការសិក្សាពី "អភិបាលកិច្ចទឹកសម្រាប់កសិកម្ម៖ វិមជ្ឈការ អភិបាលកិច្ចច្រើនកម្រិត និងសហគមន៍មូលដ្ឋាននៅអាងទន្លេសាប" ដោយបានទទួលមូលនិធិមួយភាគពីកម្មវិធីក្រុមស្រាវជ្រាវ M-Power-CPWF នៃវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី។ ក្រុមស្រាវជ្រាវគម្រោង"អនាម័យ និងទឹកនៅតំបន់ជនបទ៖ បញ្ហាប្រឈម និងកាលានុវត្តភាព" បានបញ្ចប់ការកែសម្រួលក្របខ័ណ្ឌទស្សនទាន និងកំពុងបង្កើតកម្រងសំណួរពាក់កណ្ដាលរៀបរយ។ សម្រាប់គម្រោង "វិមជ្ឈការបែបប្រជាធិបតេយ្យ និងយេនឌ័រ៖ ការវិភាគពីយេនឌ័រនៅក្នុងគណបក្សនយោបាយនៅកម្ពុជា" ក្រុមស្រាវជ្រាវបានបញ្ចប់ការ ចុះសិក្សាដល់កន្លែងក្នុងបួនខេត្ត និងកំពុងវិភាគទិន្នន័យ។

កម្មវិធី DGPSR ទើបចាប់ផ្ដើមអនុវត្តគម្រោងពីរ។ គម្រោង "រឿងល្អទាំងអស់ មិនសុទ្ធតែដើរស្របគ្នាឡើយ៖ ការវិភាគពីភាពផ្ទុយគ្នារវាង ការកសាងសន្តិភាព និងប្រជាធិបតេយ្យភាវូបនីយកម្ម" កំពុងរង់ចាំការសម្រេចលើកិច្ចសន្យាឲ្យស្រាវជ្រាវ។ គម្រោងនេះគ្រោងអនុវត្តក្រោមកិច្ចសហការជាដៃគូជាមួយ សាកលវិទ្យាល័យ Gothenburg ដើម្បីកំណត់ពីរបៀប និងមូលហេតុដែលទំនាស់នានាផុសឡើង (ក្នុងរយៈពេលខ្លី និងវែង) បន្ទាប់ពីមាន ឬក៏អាចកើតឡើងពីអន្តរាគមន៍ខាងកសាងសន្តិភាព។ក្រុមស្រាវជ្រាវគម្រោង"សមត្ថភាពរដ្ឋដើម្បីជួយទ្រទ្រង់ដល់ការគ្រប់គ្រងកម្លាំងពលកម្មនៅកម្ពុជា" បានផ្ដួចផ្ដើមធ្វើការសិក្សាតាមដានបន្តមួយអំពីសមត្ថភាពរដ្ឋ ហើយបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលរចនារៀបចំការសិក្សា។

### កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ (ETRC)

គម្រោង "អង្កេតពលករងាយរងគ្រោះ" និង "អង្កេតថ្លៃទំនិញតាមខេត្ត" កំពុងជឿនលឿនទៅមុខយ៉ាងល្អ។ គម្រោងសិក្សាដទៃទៀត មាន (១) គម្រោងស្រាវជ្រាវរយៈពេលបីឆ្នាំស្ដីពី "ការកសាង និងពង្រឹងចីរភាព GMS-DAN ឆ្នាំ២០១១-១៤៖ កិច្ចសហការស្រាវជ្រាវលើ គោលនយោបាយពាក់ព័ន្ធនឹងកំណើនសម្រាប់គ្រប់គ្នា និងសមាហរណកម្មកម្រិតអនុតំបន់នៅក្នុង GMS" (២) គម្រោងរយៈពេល៥ឆ្នាំស្ដីពី "កំណើនសម្រាប់គ្រប់គ្នា" ដែលផ្ដោតលើកំណើនខ្ពស់មានចីរភាព (៣) "កំណើនសេដ្ឋកិច្ច វិសមភាព និងការកាត់បន្ថយភាពក្រីក្រ" (៤) "កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ SMEs" (៥) "កំណើនសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការកាត់បន្ថយភាពក្រីក្រ និង (៦) "វិធីដើម្បីអាចសម្រេចបានកំណើនសម្រាប់គ្រប់គ្នា"។

របាយការណ៍ព្រាងទី១ ស្ដីពី "តើមានឧបសគ្គអ្វីខ្លះចំពោះកំណើនសម្រាប់គ្រប់គ្នានៅកម្ពុជា?"និង"កញ្ចប់ឧស្សាហកម្មសមាគមអាជីវកម្ម និងផលិតភាព SME៖ ភស្តុតាងបានពីអង្កេត សហគ្រាសនៅកម្ពុជា" បានផ្ញើទៅឲ្យ ARTNeT រួចហើយ ដើម្បីសុំយោបល់បន្ថែម។ របាយការណ៍ចុងក្រោយស្ដីពី "ការវាយតម្លៃរហ័សពីផលប៉ះពាល់នៃការឡើងថ្លៃស្បៀងអាហារទៅលើជនក្រីក្រ និងក្រុមងាយរងគ្រោះនៅកម្ពុជា" បានផ្ញើទៅឲ្យ NGO Forum ហើយលទ្ធផលស្រាវជ្រាវសំខាន់ៗ បានយកទៅធ្វើបទបង្ហាញក្នុងការប្រជុំសមាជិកប្រចាំត្រីមាស កាលពីថ្ងៃទី២៧ មេសា។ សិក្ខាសាលាស្រាវជ្រាវលើកទី៣ ដើម្បីពិភាក្សាពីលទ្ធផលស្រាវជ្រាវសំខាន់ៗ នៃគម្រោងវិបត្តិហិរញ្ញវត្ថុសាកល និងភាពងាយរងគ្រោះនៅកម្ពុជា" ដែលទទួលហិរញ្ញប្បទានពី IDRC បានធ្វើរួចរាល់ កាលពីថ្ងៃទី ៨ មិថុនា។

ក្រុមស្រាវជ្រាវកម្មវិធី ETRC កំពុងបន្តចងក្រងទិន្នន័យ និងផលិតឯកសារ "របាយការណ៍ថ្មីៗស្ដីពីសេដ្ឋកិច្ចកម្ពុជា"។ ទំព័រខាងមុខសម្រាប់សៀវភៅ"ចំណាកស្រុកកម្លាំងពលកម្មក្នុងមហាអនុតំបន់មេគង្គ (DAN 6)" បានទទួលការយល់ព្រមហើយសំណៅចុងក្រោយកំពុងចងក្រងដាក់តាមលំដាប់លំដោយ។

អត្ថបទព្រាងសម្រាប់គម្រោង "ផលប៉ះពាល់នៃប្រទេសចិន ទៅលើភាពក្រីក្រក្នុងមហាអនុតំបន់មេគង្គ (DAN 8)" "ការរួចរស់ពីវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល៖ បទពិសោធន៍កម្ពុជា" និង "គោលនយោបាយដីធ្លី និងការអនុវត្តនៅកម្ពុជា" កំពុងរៀបចំបោះពុម្ព។

### កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន (NRE)

កម្មវិធីនេះ កំពុងអនុវត្តគម្រោងស្រាវជ្រាវ ៦។ របាយការណ៍ព្រាងថ្នាក់ជាតិ ស្ដីពី "ការពិនិត្យតាមដានផលប៉ះពាល់សង្គម និងអង្កេតគោលដើម្បីវាយតម្លៃភាពងាយរងគ្រោះ" កំពុងពិនិត្យឡើងវិញធៀបនឹងរបាយការណ៍កម្រិតតំបន់។ គម្រោងនេះ អនុវត្តឡើងដើម្បីជួយទ្រទ្រង់ដល់ការសិក្សារបស់គណៈកម្មការទន្លេមេគង្គ ស្ដីពីបម្រែបម្រួលអាកាសធាតុ និងគំនិតផ្ដួចផ្ដើមបន្សាំខ្លួន។ ក្រុមស្រាវជ្រាវកម្មវិធីនេះ កំពុងវិភាគទិន្នន័យប្រភពទី២ សម្រាប់ការសិក្សាស្ដីពី "យេនឌ័រ និងអភិបាលកិច្ចទឹក៖ ការគ្រប់គ្រង និងអភិវឌ្ឍធារាសាស្ត្រក្នុងបរិបទនៃការផ្លាស់ប្ដូរអាកាសធាតុ" ដែលជាផ្នែកមួយនៃកម្មវិធីការផ្លាស់ប្ដូរអាកាសធាតុ ការបន្សាំខ្លួន និងការចិញ្ចឹមជីវិតនៅក្នុងគំនិតផ្ដួចផ្ដើមសម្រេចឲ្យបានកំណើនសម្រាប់គ្រប់គ្នា ដែលទ្រទ្រង់ដោយ Sida។ ក្រុមស្រាវជ្រាវគម្រោង "ការពង្រឹងអភិបាលកិច្ចធនធានជលផល (STARGO)" បានចងក្រង និងកែសម្រួលរបាយការណ៍ព្រាងរួចហើយ។ គម្រោងនេះសំដៅលើកកម្ពស់អភិបាលកិច្ចលើ

ធនធានជលផល ដែលកំពុងមានការប្រជែងគ្នា ព្រមទាំងគាំទ្រដល់គម្រោង ក៏ដូចជា អន្តរាគមន៍នានា ដើម្បីជួយកែលំអ អាហាររូបត្ថម្ភ ប្រាក់ចំណូល សុខុមាលភាព និងសន្តិសុខ នៅជុំវិញបឹងទន្លេសាប។

អ្នកស្រាវជ្រាវប្រចាំកម្មវិធី NRE បានចូលរួមក្នុងកិច្ចប្រជុំជាច្រើន ដើម្បីជំរុញការសិក្សាពី "ផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ និងភាពធន់ទ្រាំ៖ ករណីសិក្សាពីការស្រោចស្រព ការប្រើប្រាស់ដី ការប្រែប្រួលរបបទឹកភ្លៀង និងអភិបាលកិច្ចទឹក" ដែលជាគម្រោងស្រាវជ្រាវរួមគ្នា ជាមួយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP)។ ក្រុមស្រាវជ្រាវនេះ ក៏កំពុងសិក្សាលើគម្រោងឆ្លងកម្មវិធីចំនួនពីរផងដែរ។ គម្រោងសិក្សារួមគ្នាជាមួយកម្មវិធីអភិវឌ្ឍសង្គម (SD) ស្តីពី "ការស្រាវជ្រាវពីហេតុការណ៍សំខាន់ៗ៖ ការចរចាលើបញ្ហាយេនឌ័រនៅកម្ពុជា" បានបញ្ចប់ការប្រមូលទិន្នន័យជុំទី១ និងកំពុងដំណើរការកត់ត្រាជាលាយលក្ខណ៍អក្សរនិងបកប្រែការថតសម្លេងបទសម្ភាសន៍។ គម្រោងសិក្សារួមគ្នាជាមួយ កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ (PARD) ស្តីពី "ការវាយតម្លៃផលប៉ះពាល់នៃ គម្រោងផ្តល់មូលនិធិដោយ CARF" កំពុងពិនិត្យឡើងវិញពីការអនុវត្តគម្រោង និងវាយតម្លៃលើវិធីសាស្ត្រស្រាវជ្រាវ។

សំណើគម្រោង "ធនធានទឹក និងការបន្សាំខ្លួននឹងការផ្លាស់ប្តូរអាកាសធាតុ" បានជោគជ័យឆ្លងផុតដំណាក់កាលជម្រុះ ហើយបច្ចុប្បន្នក្រុមស្រាវជ្រាវ កំពុងឆ្លើយតបនឹងយោបល់នានា ទទួលបានពី IDRC។

**កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ** (PARD)

ក្រុមស្រាវជ្រាវគម្រោង "ការវាយតម្លៃពីផលប្រយោជន៍នៃអង្គការកសិករ ចំពោះសន្តិសុខស្បៀងរបស់ជនក្រីក្រនៅជនបទ" បានចងក្រង និងបញ្ជូនរបាយការណ៍ចុងក្រោយរួចរាល់ហើយ។ លទ្ធផលស្រាវជ្រាវសំខាន់ៗ បានធ្វើបទបង្ហាញជូនដល់ធនាគារពិភពលោក និង AusAID។

គម្រោងស្រាវជ្រាវចំនួនបួន កំពុងដំណើរការទៅមុខ។ របាយការណ៍ព្រាងលើកទី៤ សម្រាប់គម្រោង "ការលើកកម្ពស់សមភាពយេនឌ័រនៅទីផ្សារពលកម្ម ដើម្បីជំរុញកំណើនសម្រាប់គ្រប់គ្នា" បានធ្វើជូន ADB ដើម្បីសុំមតិត្រឡប់។ សម្រាប់ការសិក្សាពី "ការរួមចំណែកនៃសេវាកម្មក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងការលើកកម្ពស់ ទំនាក់ទំនងខាងឧស្សាហកម្មនៅកម្ពុជា៖ ករណីរោងចក្រកាត់ដេរ" ទិន្នន័យគឺបានប្រមូលសព្វគ្រប់ រីឯលទ្ធផលស្រាវជ្រាវបឋម ក៏បានធ្វើជាបទបង្ហាញជូនដល់សហព័ន្ធក្រុមប្រឹក្សាអាជ្ញាកណ្តាលហើយដែរ។ លទ្ធផលស្រាវជ្រាវបឋមសម្រាប់គម្រោង "ការកសាងគោលនយោបាយកសិកម្មសម្រាប់ប្រព័ន្ធកសិកម្មផ្អែកលើដំណាំស្រូវនៅកម្ពុជា និងឡាវ" នឹងធ្វើបទបង្ហាញនៅឡាវ នៅថ្ងៃទី១៤ កក្កដា ហើយក្រុមស្រាវជ្រាវកំពុងចងក្រងរបាយការណ៍ព្រាងទី១។ ការសិក្សាឯកសារមានស្រាប់ សម្រាប់គម្រោងទទួលបានហិរញ្ញប្បទានពី Sida ស្តីពី "ផលប៉ះពាល់នៃការធ្វើកសិកម្ម តាមកិច្ចសន្យាទៅលើជីវភាពរបស់ម្ចាស់ដីតូចៗ" កំពុងដំណើរការទៅមុខ។

កម្មវិធីនេះ បានចាប់ផ្តើមការងារលើគម្រោងថ្មីបី។ សម្រាប់គម្រោង "ការវាយតម្លៃផលប៉ះពាល់នៃ គម្រោងផ្តល់មូលនិធិដោយ CARF" កិច្ចសន្យាយល់ព្រមឲ្យអនុវត្ត បានចុះហត្ថលេខារួចរាល់ ហើយក្រុមស្រាវជ្រាវ កំពុងចងក្រងរបាយការណ៍កសាងគោលគំនិត។ របាយការណ៍កសាងគោលគំនិតសម្រាប់គម្រោង "ការសិក្សាតាមដានបន្ទាត់កណ្តាលអាណត្តិ និងនៅចុងអាណត្តិពីតម្រូវការរបស់សហព័ន្ធក្រុមប្រឹក្សាអាជ្ញាកណ្តាល លើផ្នែកអភិបាលកិច្ចល្អ" បានផ្ញើជូនម្ចាស់ជំនួយរួចរាល់ ហើយក្រុមស្រាវជ្រាវកំពុងរៀបចំប្រមូលទិន្នន័យ។ ការសិក្សាពី "ការវាយតម្លៃមូលដ្ឋានលើគម្រោង HARVEST" ដែលទទួលហិរញ្ញប្បទានពី USAID-FINTRAC កំពុងដំណើរការរៀបចំវិធីសាស្ត្រស្រាវជ្រាវ និងបង្កើតកម្រងសំណួរសម្រាប់អង្កេត។

**កម្មវិធីអភិវឌ្ឍន៍សង្គម** (SD)

ក្រុមស្រាវជ្រាវប្រចាំកម្មវិធីនេះ កំពុងអនុវត្តគម្រោងស្រាវជ្រាវប្រាំមួយ ក្នុងនោះមានបីគម្រោង ជាចំណែកតូចៗនៃក្រុមកម្មវិធីសិក្សារយៈពេលប្រាំមួយឆ្នាំ ស្តីពីការកសាងប្រព័ន្ធសុខាភិបាលអំណោយផលដល់ជនក្រីក្រ ក្នុងពេលកសាងប្រទេសឡើងវិញ បន្ទាប់ពីបានបញ្ចប់ទំនាស់ ឬហៅកាត់ថា "REBUILD" ដែលផ្តល់មូលនិធិដោយ DFID។ ដោយទទួលបានការយល់ព្រមពី គណៈកម្មាធិការក្រុមសីលធម៌ជាតិសម្រាប់ការស្រាវជ្រាវផ្នែកសុខភាព សព្វថ្ងៃមានគម្រោងសិក្សាពីរកំពុងដំណើរការទៅមុខ គឺ ១) គម្រោងសិក្សាពី "ផលប៉ះពាល់នៃការផ្លាស់ប្តូរ គោលនយោបាយផ្តល់ហិរញ្ញប្បទានផ្នែកសុខាភិបាលទៅលើលំនាំចាយវាយលើការថែទាំសុខភាព របស់គ្រួសារក្រីក្រនៅជនបទកម្ពុជា៖ ការវិភាគពីចំណាយគ្រួសារលើការថែទាំសុខភាព" និង ២) "គោលនយោបាយទាក់ទាញ និងរក្សាបុគ្គលិកសុខាភិបាលឲ្យធ្វើការនៅតំបន់ជនបទ៖ ការពិនិត្យឡើងវិញពីកត្តាជំរុញផ្នែកគោលនយោបាយ ការអនុវត្ត និងប្រសិទ្ធភាពគោលនយោបាយ ក្រោយការបញ្ចប់ទំនាស់នៅកម្ពុជា។ បច្ចុប្បន្ន ក្រុមស្រាវជ្រាវកំពុងស្នើសុំការយល់ព្រមលើផ្នែកសីលធម៌ ដើម្បីអនុវត្តសមាសភាគទី៣៖ "ដំណើរការផ្លាស់ប្តូរនៃការរៀបចំកិច្ចសន្យានៅកម្ពុជា"។

ការសិក្សាដល់កន្លែងសម្រាប់គម្រោង "អភិបាលកិច្ចសម្រាប់ការអប់រំថ្នាក់ឧត្តមនៅកម្ពុជា" ដែលផ្តល់មូលនិធិដោយ Sida កំពុងដំណើរការទៅមុខ។ គម្រោង "ការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្មនៅកម្ពុជា" ដែលទទួលមូលនិធិពី Sida ដែរ កំពុងស្ថិតក្នុងដំណាក់កាលរចនារៀបចំ។ សម្រាប់គម្រោង "ការអង្កេតស្រាវជ្រាវពីហេតុការណ៍សំខាន់ៗ៖ ការចរចាលើបញ្ហាយេនឌ័រនៅកម្ពុជា" ដែលទទួលហិរញ្ញប្បទានពី GIZ និងជាផ្នែកមួយនៃការស្រាវជ្រាវវាយតម្លៃពីប្រព័ន្ធមេ នៃគម្រោងសហប្រតិបត្តិការបច្ចេកទេស MoWA-GIZ ស្តីពី "លទ្ធភាពទទួលបានយុត្តិធម៌សម្រាប់នារី"។ ក្រុមស្រាវជ្រាវ បានបញ្ចប់ការប្រមូលទិន្នន័យតាមការធ្វើសម្ភាសន៍ក្នុងជំហានទី១ និងកំពុងពិនិត្យឡើងវិញលើឯកសារកត់ត្រាពីសម្ភាសន៍។ ការជឿនលឿនគម្រោងនេះ បានយកទៅរាយការណ៍ក្នុងកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិលើកទី៦ កាលពីថ្ងៃទី១១ មិថុនា។

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

អត្ថបទសង្ខេបចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១២ ដែលបោះពុម្ពផ្សាយជាភាសាខ្មែរ និងអង់គ្លេស និងមានអធិប្បាយពីបញ្ហាសំខាន់ៗ និងអាទិភាពខាងគោលនយោបាយ ដែលទទួលបានពីសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១២ នោះ គឺបានផ្សព្វផ្សាយចេញដំណាលគ្នានឹងកិច្ចប្រជុំកំពូលអាស៊ាន ដែលមានប្រទេសកម្ពុជាជាប្រធាន និងបានរៀបចំឡើងនៅទីក្រុងភ្នំពេញកាលពីដើមខែមេសា ២០១២។ ឯកសារសង្ខេបចក្ខុវិស័យប្រទេសកម្ពុជានេះ អាចរកបាននៅក្នុងគេហទំព័ររបស់ CDRI www.cdri.org.kh។ នៅថ្ងៃទី៥ មេសា វិទ្យាស្ថានយុទ្ធសាស្ត្រ និងភាពជាអ្នកដឹកនាំអាស៊ី (Asian Strategy and Leadership Institute: ASLI) របស់ប្រទេសម៉ាឡេស៊ី បានបើកវេទិកាប្រជុំភាពជាអ្នកដឹកនាំអាស៊ានលើកទី៩ នៅភ្នំពេញ បន្ទាប់ពីកិច្ចប្រជុំកំពូលអាស៊ាន។ ក្នុងវេទិកានោះ នាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI ជាអ្នកសម្របសម្រួលវគ្គស្ដីពី ទំនាក់ទំនងប្រជាជនតាមរយៈការអប់រំ វប្បធម៌ ទេសចរណ៍ និងចលនាមនុស្ស។

នៅខែឧសភា វិទ្យាស្ថាន CDRI និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) បានបើកកិច្ចប្រជុំពិនិត្យបូកសរុបប្រចាំឆ្នាំលើជំនួយហិរញ្ញវត្ថុឆ្នាំ២០១១-១៦ របស់ Sida សម្រាប់ទាំងផ្នែកស្រាវជ្រាវ និងផ្នែកប្រតិបត្តិការ។ ការប្រជុំនេះបានពិនិត្យពីសកម្មភាពទូទៅ ធៀបនឹងផែនការយុទ្ធសាស្ត្រឆ្នាំ២០១១-១៥ របស់វិទ្យាស្ថាន CDRI ព្រមទាំងក្របខ័ណ្ឌវាយតម្លៃលទ្ធផលជាក់លាក់ ដែលបានព្រមព្រៀងគ្នារវាង CDRI និង Sida ដោយផ្ដោតលើការស្រាវជ្រាវស្ដីពី អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ កំណើនសម្រាប់គ្រប់គ្នា ការផ្លាស់ប្ដូរអាកាសធាតុ និងការអប់រំកម្រិតឧត្ដមសិក្សា និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ។ ការត្រួតពិនិត្យពាក់កណ្ដាលអាណត្តិ គ្រោងធ្វើឡើងនៅ ចុងឆ្នាំ២០១៣។ ការប្រជុំ ក៏បានពិភាក្សាពីយុទ្ធសាស្ត្រផ្សេងៗ ដើម្បីជំរុញជាមួយនឹងដៃគូអភិវឌ្ឍន៍ដទៃទៀត នូវគំរូនៃភាពជាដៃគូរយៈពេលវែង រវាង CDRI និង Sida សម្រាប់ការស្រាវជ្រាវខាងគោលនយោបាយ ការអភិវឌ្ឍសមត្ថភាព និងការពង្រឹងស្ថាប័ន។

នៅខែឧសភា នេះដែរ ឯកឧត្ដម ហង់ ជួន ណារ៉ុន អតីតប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថាន CDRI និងបច្ចុប្បន្នជាប្រធានគណៈកម្មាធិការដឹកនាំការងារ នៃវេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជាដំណាក់កាលទី២ ឆ្នាំ២០១២-១៥ បានទទួលធ្វើជាប្រធានសិក្ខាសាលាចាប់ដំណើរការដំណាក់កាលទី២ នេះ។ DRF គឺជាកិច្ចសហការជាដៃគូរវាងវិទ្យាស្ថាន CDRI សមាគមន៍សេដ្ឋកិច្ចកម្ពុជា វិទ្យាស្ថានសិក្សាស្រាវជ្រាវ វិទ្យាស្ថានជាតិសុខភាពសាធារណៈ ឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ សាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្រោមការឧបត្ថម្ភគាំទ្រពី IDRC។ ក្នុងដំណាក់កាលទី២នេះ ក្រុមចាប់អារម្មណ៍ខាងការស្រាវជ្រាវ នឹងផ្ដោតលើកំណើនសេដ្ឋកិច្ច និងភាពសម្រាប់គ្រប់គ្នា កម្ពុជា និងតំបន់របស់ខ្លួន អភិបាលកិច្ចធនធានធម្មជាតិ ការអភិវឌ្ឍកសិកម្ម និងការអប់រំ និងសុខភាព។

ដោយមានការអញ្ជើញពីក្រុមហ៊ុនសារព័ត៌មាន Asia Business Daily មានទីស្នាក់ការនៅក្រុងសេអ៊ូលនោះ នៅដើមខែមិថុនា នាយកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI បានអញ្ជើញចូលរួមក្នុងវេទិកាហិរញ្ញវត្ថុសេអ៊ូល-អាស៊ាន និងបានធ្វើជាវាគ្មិនលើប្រធានបទ ការអភិវឌ្ឍហិរញ្ញវត្ថុអាស៊ានតាម ទស្សនវិស័យពិភពលោក។

នៅថ្ងៃទី២៥-២៦ ខែមិថុនា លោកនាយកប្រតិបត្តិ CDRI បានចូលរួមសិក្ខាសិលានៅទីក្រុងប៉េកាំង ដែលទទួលរៀបចំរួមគ្នាដោយសាស្ត្រាចារ្យ Zhang Yunling ប្រធានផ្នែកការសិក្សាអន្តរជាតិនៃបណ្ឌិតសភាវិទ្យាសាស្ត្រសង្គមនៃប្រទេសចិន (CASS) និងវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌

*(តទៅទំព័រ ២២)*

ឯកសារបោះពុម្ពផ្សាយរបស់
*វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

**ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា**

**ឆ្នាំទី១៦ លេខ២ ខែមេសា-មិថុនា ឆ្នាំ២០១២**

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្ដល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្ដល់ជូននូវមូលវិចារឯករាជ្យស្ដីពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខា អាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន ។ អ្នកនិពន្ធ ត្រូវទាក់ទង វបសអ មុននឹងផ្ដល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

**វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
(៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@cdri.org.kh
website: http://www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសំរួល: យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា និង ម៉ែន ច័ន្ទធីតា
ជំនួយការកែសំរួល: ខេង សេង និង អ៊ឹង សុជាតិ
សហគ្រាសបោះពុម្ព ព្រីនម៉ាស្ទ័រ ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០១២ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

គំនិត ការលើកពីហេតុការណ៍ និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្ដល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រ: http://www.cdri.org.kh